**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការធានាកាតព្វកិច្ចតាមច្បាប់ ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ឈុំ មុនីសុជាតា**

**ខ. ឆេង សុខលាង**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ម៉ួយ ធីតា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី២២ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ឈុំ មុនីសុជាតា** និង ខ្ញុំបាទ **ឆេង សុខលាង** សូមសម្តែងនូវការគោរព និងរឭកដឹងគុណដ៏ខ្ពង់ខ្ពស់ជូនចំពោះ៖

១. លោកឪពុកអ្នកម្តាយ ដែលបានចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅយើងខ្ញុំប្រកបដោយព្រហ្មវិហារធម៌។ លោកបានជួយផ្គត់ផ្គង់ទំនុកបម្រុង ផ្តល់ឱកាសសិក្សារៀនសូត្រតាំងពីបឋមវ័យ និងលើកទឹកចិត្តយើងខ្ញុំគ្រប់ពេលវេលារហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

២. ឯកឧត្តមសាកលវិទ្យាការ និងគណៈគ្រប់គ្រងសាកលវិទ្យាល័យ លោក លោកស្រីដែលជាសាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយសម្របសម្រួល ផ្តល់ភាពងាយស្រួលដល់ការសិក្សាក្រេបជញ្ជក់យកចំណេះដឹងផ្នែកនីតិសាស្ត្រ និងបំណិនជីវិតផ្សេងៗក្នុងរយៈពេលបួនឆ្នាំនៃការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំ។

៣. លោកស្រី **ម៉ួយ ធីតា** ព្រឹទ្ធបុរសរងមហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាសាស្ត្រាណែនាំសារណាមួយនេះ ដែលលោកស្រីសាស្ត្រាចារ្យបានចំណាយពេលវេលាយ៉ាងច្រើនក្នុងការផ្តល់ជាមតិយោបល់ និងបានជួយពិនិត្យណែនាំលើកិច្ចការរបស់យើងខ្ញុំ រហូតដល់បានទទួលនូវសមិទ្ធិផលមួយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំសូមឱនកាយគោរពដោយសេចក្តីដឹងគុណដល់អ្នកមានគុណដែលបានរៀបរាប់ខាងលើ សូមឱ្យលោកជួបតែពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ប្រតិបត្តិការដែលមានកិច្ចធានា ជាសញ្ញាណមួយដែលមិនទាន់ត្រូវបានសិក្សាយ៉ាងទូលំទូលាយនោះទេក្នុងបរិបទនៃព្រះរាជាណាចក្រកម្ពុជាយើង។ ការសម្រេចយកប្រធានបទនេះមកសិក្សា បណ្តាលមកពីការមើលឃើញនូវចំណុចខ្វះខាតដែលមាននៅក្នុងការអនុវត្តនូវប្រតិបត្តិការនេះ ទាំងដែលសញ្ញាណនេះជាសញ្ញាណមួយមានលក្ខណៈទំនើប និងបម្រើឱ្យការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចបានមួយចំណែកធំ។ បញ្ហាដែលយើងខ្ញុំរកឃើញនៅក្នុងការសិក្សាអំពីប្រតិបត្តិការដែលមានកិច្ចធានា គឺពាក់ព័ន្ធនឹងការអនុវត្តប្រាតិភោគលើចលនវត្ថុតាមរយៈក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក៏ដូចជាការអនុវត្តសិទ្ធិតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាផងដែរ។

អំឡុងពេលតាក់តែងអត្ថបទនេះឡើងមក យើងខ្ញុំជួបប្រទះនឹងការលំបាកជាច្រើន ព្រោះប្រធានបទនេះជាប្រធានបទដែលថ្មី ហើយសញ្ញាណនៃប្រធានបទនេះទៀតសោតមិនសូវមានអ្នកជំនាញដើម្បីផ្តល់ជាមតិយោបល់ឡើយ។ ការតាក់តែងគឺពឹងផ្អែកស្ទើរទាំងស្រុងលើការអានអត្ថបទនានាដែលពាក់ព័ន្ធជាជំនួយស្មារតី។ អត្ថបទទាំងនោះ មានមួយចំនួនជាភាសាខ្មែរដែលត្រូវបានតាក់តែង ឬប្រែសម្រួលដោយក្រុមការងារតាក់តែងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានៃក្រសួងពាណិជ្ជកម្ម។ ក្រៅពីនោះ មានអត្ថបទជាច្រើនសរសេរជាភាសាបរទេស ដែលរៀបរាប់ពីសញ្ញាណទូទៅនៃប្រតិបត្តិការដែលមានកិច្ចធានា និងសញ្ញាណនៃការអនុវត្តនៅសហរដ្ឋអាមេរិកដែលជាប្រភពដើមនៃប្រតិបត្តិនេះ។ ការសិក្សាលើអត្ថបទបរទេសទាំងនេះ ដើម្បីជាជំនួយស្មារតីព្រោះការអនុវត្តមានលក្ខណៈប្រហាក់ប្រហែលគ្នា តែមិនអាចធ្វើការបកស្រាយដូចគ្នាទាំងស្រុងទេ ហេតុនេះហើយ ការលំបាកក្នុងការបកស្រាយនៅតែកើតមាន។

ជាចុងបញ្ចប់ យើងខ្ញុំសង្ឃឹមជឿជាក់ថា ស្នាដៃមួយនេះនឹងបានចូលរួមចំណែកក្នុងការសិក្សាអំពីប្រតិបត្តិការដែលមានកិច្ចធានានេះទៅថ្ងៃអនាគត។ យើងខ្ញុំ សូមមេត្តាខន្តីអភ័យទោសចំពោះរាល់កំហុសឆ្គងក្នុងការតាក់តែងនេះ ហើយក៏សូមទទួលស្វាគមន៍នូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់អ្នកស្រាវជ្រាវគ្រប់រូប ដើម្បីជាបច្ច័យក្នុងការកែលម្អសមិទ្ធិផលមួយនេះឱ្យកាន់តែប្រសើរឡើងថែមមួយកម្រិតទៀត។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា**

**ផ្នែកទី១ មូលហេតុនៃការបង្កើតច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា** ........................................ ៣

កថាខណ្ឌទី១ ការចូលជាសមាជិកអង្គការអន្តរជាតិនានា ........................................ ៤

កថាខណ្ឌទី២ ការរីកចម្រើនក្នុងវិស័យហិរញ្ញវត្ថុ ........................................ ៤

**ផ្នែកទី២ គោលបំណងនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា** ........................................ ៥

កថាខណ្ឌទី១ ការជំរុញសកម្មភាពសេដ្ឋកិច្ចតាមផ្លូវច្បាប់ ........................................ ៥

កថាខណ្ឌទី២ ការពង្រីកវិសាលភាពនៃទ្រព្យធានា ........................................ ៧

**ជំពូកទី២**

**ការបង្កើត និងអានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា**

**ផ្នែកទី១ ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា** ........................................ ១០

កថាខណ្ឌទី ១ លក្ខខណ្ឌក្នុងការបង្កើត ........................................ ១០

កថាខណ្ឌទី២ កម្មវត្ថុនៃទ្រព្យធានា ........................................ ១៣

**ផ្នែកទី ២ អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា** ........................................ ២០

កថាខណ្ឌទី១ វិធីក្នុងការធ្វើសុក្រឹតកម្ម ........................................ ២០

កថាខណ្ឌទី ២ អាទិភាពនៃសុក្រឹតកម្ម ........................................ ២៨

## ជំពូកទី៣
## ការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានា

**ផ្នែកទី១ សិទ្ធិក្នុងការឃាត់ទុក កាន់កាប់ និងប្រមូលទ្រព្យធានា** ........ ៣៤

កថាខណ្ឌទី ១ សិទ្ធិក្នុងការឃាត់ទុក ........ ៣៥

កថាខណ្ឌទី ២ សិទ្ធិក្នុងការកាន់កាប់ទ្រព្យធានា ........ ៣៥

កថាខណ្ឌទី៣ សិទ្ធិក្នុងការប្រមូលទ្រព្យធានា ........ ៣៦

**ផ្នែកទី២ សិទ្ធិក្នុងការជម្រះចោលទ្រព្យធានា** ........ ៣៧

កថាខណ្ឌទី១ ការជម្រះចោលទ្រព្យធានា និងការលោះទ្រព្យធានា ........ ៣៧

កថាខណ្ឌទី២ ភាពស្របច្បាប់ក្នុងការអនុសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ........ ៣៩

**សេចក្តីសន្និដ្ឋាន** ........ ៤២

**អនុសាសន៍** ........ ៤៦

**គន្ថនិទ្ទេស**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

គោលបំណងបឋមនៃប្រតិបត្តិការដែលមានកិច្ចធានា គឺលើកស្ទួយសកម្មភាពសេដ្ឋកិច្ច។ ការលើកកម្ពស់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍប្រទេស ជាពិសេសនៅក្នុងបរិបទនៃសកលភាវូបនីយកម្ម ដែលពោរពេញទៅដោយការប្រកួតប្រជែងនេះ។ វិធីមួយក្នុងការជំរុញកំណើនសេដ្ឋកិច្ច គឺការបង្កើតប្រាតិភោគ ហើយសញ្ញាណនេះមិនមែនជាសញ្ញាណថ្មីនោះទេសម្រាប់កម្ពុជា ព្រោះថាវត្តមាននៃកិច្ចសន្យាប្រាតិភោគមានយូរណាស់មក ហើយនៅក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែហេតុអ្វីបានជាមានការអះអាងថាច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានឹងជួយឱ្យជំរុញការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការផ្តល់ប្រាតិភោគទៅវិញ ហើយថាតើច្បាប់នេះមានយន្តការបែបណាសម្រាប់ការអនុវត្តដ៏មានប្រសិទ្ធិភាពនោះ? ប្រតិបត្តិការដែលមានកិច្ចធានាត្រូវបានបង្កើតឡើងដំបូងនៅសហរដ្ឋអាមេរិច ដោយចែងក្នុងមាត្រា ៩នៃក្រមឯកភាពពាណិជ្ជកម្ម (THE UNIFORM COMMERCAIL CODE)។ ច្បាប់នេះត្រូវបានយកមកកែសម្រួល និងប្រកាសឱ្យប្រើនៅប្រទេសកម្ពុជាក្នុងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧ ដូច្នេះយើងអាចនិយាយបានថា វាជាច្បាប់ថ្មីសំរាប់បរិបទប្រទេសកម្ពុជាដែលយើងត្រូវធ្វើការស្វែងយល់បន្ថែមពីអត្ថន័យ និងការវិវត្តខ្លួនរបស់វាក្នុងរយៈពេលជិត ១០ឆ្នាំក្រោយការដាក់ឱ្យប្រើប្រាស់។ វាអាចនិយាយបានថាជាប្រព័ន្ធទំនើបថ្មីមួយដែលជួយសម្រួលដល់ការប្រើប្រាស់ចលនវត្ថុក្នុងការធានាបំណុល។ ជាក់ស្តែងគោលដៅចម្បងនៃការបង្កើតច្បាប់នេះឡើងនៅកម្ពុជា គឺសំដៅអភិវឌ្ឍសកម្មភាពហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដោយផ្តល់វិធានដែលមានលក្ខណៈងាយស្រួលដល់ការអនុវត្តសិទ្ធិ និងកាតព្វកិច្ច របស់ភាគីកូនបំណុល និងម្ចាស់បំណុល។ ក្រៅពីនេះការបង្កើតច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក៏មានគោលដៅជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ តាមរយៈការប្រើប្រាស់ចលនវត្ថុដើម្បីដាក់ធានាបំណុលដែលជួយដល់អ្នកដែលគ្មានអចលនវត្ថុ អាចស្វែងរកដើមទុន(ហិរញ្ញប្បទាន) ដើម្បីបើក ឬពង្រីកអាជីវកម្មផងដែរ។ ដោយហេតុថា ប្រភពឥណទានមានកម្រិតចំពោះកិច្ចដែលធានាដោយបុគ្គល ដោយការបញ្ចាំអចលនវត្ថុ វាមិនគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការអាជីវកម្មទេ ប្រសិនបើមានតែការធានាដោយបុគ្គល និងការធានាដោយអចលនវត្ថុ ពីព្រោះកម្មសិទ្ធិដីធ្លីមានភាពចង្អៀត។ ដូច្នេះច្បាប់នេះបានផ្តល់ឱ្យនូវមធ្យោបាយនៃការប្រើប្រាស់ចលនវត្ថុ ដូចជាទំនិញជាដើម យកទៅដាក់ធានាបំណុល ដើម្បីជំរុញដល់ឥណទានអាជីវកម្មឱ្យអភិវឌ្ឍបានលឿន។ ប្រតិបត្តិការនេះអាចហៅបានថា ហិរញ្ញប្បទានចលនវត្ថុ ដែលអនុញ្ញាតឱ្យបុគ្គលកាន់តែច្រើនអាចចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច។

ការដាក់ប្រាតិភោគលើចលនវត្ថុនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ត្រូវបានគ្រប់គ្រងដោយសញ្ញាណគតិយុត្តពីរគឺ ក្រមរដ្ឋប្បវេណី ដែលជាច្បាប់សារធាតុ និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដែលជាបទប្បញ្ញត្តិពិសេស។ សំណួរដែលច្រើនតែចោទឡើងនៅពេលអនុវត្ត គឺវិសាលភាពនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងអាទិភាពនៃការអនុវត្តរវាងបទដ្ឋានគតិយុត្តទាំងពីរ។ ទោះជាយ៉ាងណាក៏ដោយ ការសិក្សានៅពេលនេះគឺនឹងផ្តោតសំខាន់តែទៅលើច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាតែប៉ុណ្ណោះ ឯសញ្ញាណនៃក្រមរដ្ឋប្បវេណី គឺមិនត្រូវបានលើកយកមកសិក្សាលម្អិតនោះទេ ពោលគឺសិក្សាតែចំណុចណាដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាតែប៉ុណ្ណោះ។

ដើម្បីធ្វើការសិក្សាលើបញ្ហាគតិយុត្តទាំងអស់នេះ យើងខ្ញុំសូមជ្រើសយកការស្រាវជ្រាវតាមរយៈឯកសារដែលមានដូចជា៖

- ការសិក្សាលើមាត្រាច្បាប់នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា
- អត្ថបទជំនួយស្មារតីជាភាសាជាតិ និងភាសាបរទេសពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ដោយហេតុថាប្រធានបទនេះជាប្រធានបទដែលមានសញ្ញាណគតិយុត្តពិសេស យើងខ្ញុំសូមធ្វើការបែងចែកការសិក្សាលើប្រធានបទនេះជាបីជំពូកគឺ សញ្ញាណទូទៅនៃប្រតិបត្តិការដែលមានកិច្ចធានា (ជំពូកទី១) ការបង្កើត និងអានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា (ជំពូកទី២) និងការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានា (ជំពូកទី៣)។

# ជំពូកទី១
# សញ្ញាណទូទៅនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ជាទូទៅ ប្រតិបត្តិការនីមួយៗមានសញ្ញាណគតិយុត្តផ្សេងៗពីគ្នា ចំណែកឯប្រតិបត្តិការដែលមានកិច្ចធានាក៏មិនខុសអ្វីពីប្រតិបត្តិការដទៃទៀតដែរ ពោលគឺវាមានលក្ខណៈពិសេសជារបស់ខ្លួនឯង។ ហេតុនេះហើយនៅក្នុងជំពូកនេះ យើងនឹងធ្វើការសិក្សាទៅលើមូលហេតុ និងវត្ថុបំណងនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា ដើម្បីស្វែងយល់អំពីមូលដ្ឋានគ្រឹះនៃប្រតិបត្តិការនេះ ទុកជាបច្ច័យសម្រាប់ការសិក្សាលម្អិតអំពីប្រតិបត្តិការដែលមានកិច្ចធានា នៅក្នុងជំពូកជាបន្តទៅទៀត។

## ផ្នែកទី១ មូលហេតុនៃការបង្កើតច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ក្រោយពីទទួលបានសន្តិភាពពេញលេញនៅឆ្នាំ១៩៩៣មក កម្ពុជាបានយកការអភិវឌ្ឍផ្នែកសេដ្ឋកិច្ចធ្វើជាស្នូលនាករក្នុងការអភិវឌ្ឍប្រទេស ក៏ប៉ុន្តែកម្ពុជានៅតែស្ថិតនៅក្នុងចំណាត់ថ្នាក់ប្រទេសដែលកំពុងអភិវឌ្ឍនៅឡើយ ធ្វើឱ្យប្រព័ន្ធគតិយុត្តរបស់យើងមិនសូវជាមានភាពសម្បូរបែបដូចបណ្តាប្រទេសអភិវឌ្ឍនោះទេ។ ដោយហេតុដូច្នេះហើយទើប ប្រព័ន្ធនៃការតាក់តែងក៏ដូចជាការអនុវត្តច្បាប់របស់យើង បានទទួលឥទ្ធិពលពីបណ្តាប្រទេសមួយចំនួនដែលមានភាពចំណាស់លើប្រព័ន្ធគតិយុត្តដើម្បីជាការសម្របសម្រួលដល់ការអនុវត្តនៅក្នុងប្រទេស។ ទោះបីជាបែបនេះក៏ដោយ ក៏ប្រព័ន្ធច្បាប់ដែលមានឥទ្ធិពលយ៉ាងខ្លាំងមកលើប្រទេសកម្ពុជាយើង គឺប្រព័ន្ធច្បាប់ស៊ីវិលដែលជាប្រព័ន្ធច្បាប់មានទំនោរទៅកាន់ការតាក់តែងជាអត្ថបទសរសេរ។ ដោយឡែក ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាវិញ ជាច្បាប់ពិសេសដែលមានកំណើតនៅក្នុងប្រព័ន្ធច្បាប់ខមមិន (Common Law) ឬអាចនិយាយដោយចំពោះថា កើតចេញពីក្រមឯកភាពពាណិជ្ជកម្ម របស់សហរដ្ឋអាមេរិក ដែលត្រូវបានគេស្គាល់ថាជាប្រទេសប្រកាន់ប្រព័ន្ធច្បាប់ខមមិន និងមានលក្ខណៈជឿនលឿន។ ប៉ុន្តែនេះមិនមែនជារឿងដែលចម្លែកនោះទេ ព្រោះបណ្តាប្រទេសជាច្រើនលើពិភពលោក មិនថាជាប្រទេសដែលប្រើប្រាស់ច្បាប់ស៊ីវិល ឬប្រព័ន្ធច្បាប់ខមមិននោះទេ គឺយកគម្រូតាម UCCដូចគ្នា ដោយសារមានហេតុជំរុញទៅតាមប្រទេសនីមួយៗ[1]។ ដោយឡែកករណីប្រទេសកម្ពុជាវិញ មូលហេតុដែលជំរុញឱ្យបង្កើតច្បាប់នេះក៏មានច្រើនយ៉ាងផងដែរ ដូចជាការចូលជាសមាជិកនៃ

---

[1] ធនាគារពិភពលោក, *Secured Transactions Systems and Collateral Registries* (សហរដ្ឋអាមេរិក, ២០១០), ៦-១៣

អង្គការអន្តរជាតិនានា ជាពិសេសអង្គការពាណិជ្ជកម្មពិភពលោក និងការរីកចម្រើនលើវិស័យហិរញ្ញប្បវត្ថុ។

## កថាខណ្ឌទី១ ការចូលជាសមាជិកអង្គការអន្តរជាតិនានា

ការចូលខ្លួនជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងអង្គការដទៃទៀតបន្ទាប់ពីទទួលបានសុខសន្តិភាពពីភ្លើងសង្គ្រាមមក ជំរុញឱ្យកម្ពុជាទទួលស្គាល់នូវសន្ធិសញ្ញាអន្តរជាតិជាច្រើនដើម្បីបំពេញលក្ខខណ្ឌជាសមាជិក ក៏ដូចជាបំពេញនូវចំណុចខ្វះចន្លោះផ្នែកលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា ដែលក្នុងចំណោមនោះ កាតព្វកិច្ចនៃសមាជិកភាពរបស់អង្គការពាណិជ្ជកម្មអន្តរជាតិបានតម្រូវឱ្យមានការបង្កើតនូវលិខិតបទដ្ឋានគតិយុត្តបន្ថែម ដើម្បីគ្រប់គ្រងទំនាក់ទំនងពាណិជ្ជកម្មជាតិ និងអន្តរជាតិ ដែលនឹងធ្វើ ឬកំពុងធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់មួយដែលបានសិក្សា និងរៀបរៀងតាក់តែងនោះគឺច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាចំពោះមុខនេះ។ ក្រៅពីការបង្កើតដោយផ្អែកលើលក្ខខណ្ឌនៃសមាជិកភាពរបស់អង្គការពាណិជ្ជកម្មអន្តរជាតិហើយនោះ ការជំរុញពីដៃគូសហប្រតិបត្តិអន្តរជាតិនានា ក៏បានជួយកម្ពុជាក្នុងការបង្កើតច្បាប់ក្នុងការគ្រប់គ្រងប្រតិបត្តិការបែបទំនើបមួយនេះផងដែរ។ ក្នុងចំណោមដៃគូទាំងអស់ ធនាគារអភិវឌ្ឍអាស៊ី(ADB) បានបំពេញបេសកកម្មជាអ្នកផ្តល់នូវជំនួយបច្ចេកទេសក៏ដូចជាផ្នែកថវិកាដើម្បីតាក់តែងសេចក្តីព្រាងច្បាប់នេះឡើងមក ដោយយកគម្រូតាមក្រមឯកភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកត្រង់មាត្រា៩[2]។

## កថាខណ្ឌទី២ ការរីកចម្រើនក្នុងវិស័យហិរញ្ញវត្ថុ

បន្ថែមពីលើការជំរុញពីដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិនានាហើយនោះ ការអភិវឌ្ឍលើវិស័យហិរញ្ញវត្ថុក៏ជាមូលហេតុមួយដែលនាំឱ្យមានការបង្កើតនូវច្បាប់នេះឡើងមកផងដែរ។ ការរីកចម្រើនលើវិស័យហិរញ្ញវត្ថុ បាននាំឱ្យមានប្រតិបត្តិការផ្នែកហិរញ្ញវត្ថុជាច្រើនបានត្រូវកើតឡើងមកដំណាលគ្នា ហើយច្បាប់សម្រាប់គ្រប់គ្រងលើប្រតិបត្តិការទាំងអស់នោះនៅមានភាពទន់ខ្សោយ ឬមិនមានច្បាប់គ្រប់គ្រងតែម្តង។ ដោយសារតែមានការព្រួយបារម្ភពីចីរភាពនៃការអភិវឌ្ឍលើប្រព័ន្ធធនាគារក៏ដូចជាប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា រាជរដ្ឋាបាលក៏បានរៀបចំតាក់តែងច្បាប់ស្តីពីប្រតិបត្តិការ

[2] មាត្រា៩នៃក្រមពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកនេះ មានលក្ខណៈទូលំទូលាយ មិនមែនមានគោលគំនិតត្រឹមតែមួយចំណុច ឬមួយមាត្រាដូចជាមាត្រាច្បាប់ធម្មតានោះទេ។ ជាក់ស្តែងមាត្រានេះជាគោលគំនិតនៃអត្ថបទច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានារបស់កម្ពុជាទាំងស្រុងតែម្តង។

ដែលមានកិច្ចធានាឡើងមកក្នុងគោលបំណង ដើម្បីសម្របសម្រួលលើបញ្ហាដែលនឹងអាចប្រឈមនៅពេលអនាគត។

ការបោះជំហានលើឆាកអន្តរជាតិ បានជំរុញឱ្យប្រព័ន្ធហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេសសេលើការការផ្តល់ហិរញ្ញប្បទានដែលកាន់តែមានច្រើនបែបសណ្ឋានដែលជាប្រភេទនៃហិរញ្ញប្បទានតាមបែបប្រព័ន្ធទំនើប។ ហិរញ្ញប្បទានទាំងអស់នោះរួមមានហិរញ្ញប្បទានឧបករណ៍ ហិរញ្ញប្បទានសារពើភណ្ឌ ហិរញ្ញប្បទានគណនីដែលត្រូវទទួល ហិរញ្ញប្បទានគណនី ហិរញ្ញប្បទានកែលំអសំណង់អាគារ ហិរញ្ញប្បទានកែលំអដីធ្លី ហិរញ្ញប្បទានកសិផលនិងសត្វពាហនៈ ហិរញ្ញប្បទានទំនិញប្រើប្រាស់ជាដើម។ ដូចបានបញ្ជាក់ពីខាងដើមថា ហិរញ្ញប្បទានទាំងនេះ ជាប្រភេទហិរញ្ញប្បទានតាមបែបទំនើប ដែលច្បាប់កម្ពុជាពីមុនមិនមានដែនអនុវត្តទៅលើវានោះទេ ហេតុនេះហើយទើបការបង្កើតច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានតួនាទីសំខាន់ក្នុងការជំរុញសកម្មភាពហិរញ្ញវត្ថុទាំងនេះ ដោយបង្កើតនូវគោលការណ៍ច្បាប់សម្រាប់គ្រប់គ្រងលើប្រតិបត្តិការទាំងអស់នោះ។

## ផ្នែកទី២ គោលបំណងនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

### កថាខណ្ឌទី១ ការជំរុញសកម្មភាពសេដ្ឋកិច្ចតាមផ្លូវច្បាប់

ការណ៍ដែលច្បាប់នេះត្រូវបានទទួលស្គាល់ថា បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការជំរុញសកម្មភាពសេដ្ឋកិច្ចនោះ ក៏ព្រោះតែវិសាលភាពយ៉ាងទូលាយនៃកម្មវត្ថុដែលយកមកធានាកាតព្វកិច្ច និងប្រភេទនៃប្រតិបត្តិការហិរញ្ញប្បទានថ្មីៗដែលត្រូវបានធានាដោយច្បាប់ទំនើបមួយនេះ។

នៅក្នុងច្បាប់នេះទៀតសោតអ្នកនីតិនិពន្ធបានប្រើប្រាស់ យុទ្ធសាស្ត្រចំនួន៤ ដែលធានាថាច្បាប់នេះអាចបម្រើផលប្រយោជន៍ពិតប្រាកដដល់វិស័យពាណិជ្ជកម្ម និងតម្រូវការរបស់ពាណិជ្ជករព្រមទាំងពង្រីកលទ្ធភាពនៃការប្រើប្រាស់ឥណទានអាជីវកម្ម។ យុត្តិសាស្ត្រដែលបានប្រើប្រាស់នៅក្នុងប្រតិបត្តិការនេះមានដូចជា៖ ប្រើប្រាស់វិធានសាមញ្ញជាងច្បាប់សារធាតុទូទៅ(ក្រមរដ្ឋប្បវេណី) បញ្ជាក់ច្បាស់លាស់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យា ផ្តល់បច្ចេកទេសថ្មីស្តីពីការតម្កល់ និង បង្កើនប្រសិទ្ធិភាពក្នុងវិស័យប្រាតិភោគ[3]។

---

[3] ក្រសួងពាណិជ្ជកម្ម, *ឯកសារបណ្តុះបណ្តាល ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា*, ១៥-១៦

**១. វិធានសាមញ្ញសំរាប់បង្កើតសិទ្ធិប្រាតិភោគ**

នៅក្នុងវិស័យពាណិជ្ជកម្ម ពេលវេលាត្រូវបានក្រុមពាណិជ្ជករចាត់ទុកថាជាមាសប្រាក់ដ៏មានតម្លៃ។ ពួកគេមិនចូលចិត្តប្រើប្រាស់ពេលវេលាច្រើន ឬនីតិវិធីបែបបទវែងឆ្ងាយ ព្រមទាំងមានការចំណាយច្រើន និងប៉ះពាល់ដល់អាជីវកម្មរបស់ពួកគេនោះទេ។ ដូច្នេះហើយច្បាប់នេះ បានកំណត់នូវវិធានសាមញ្ញមួយចំនួន ស្តីពីការបង្កើតសិទ្ធិប្រាតិភោគលើចលនទ្រព្យគ្រប់ប្រភេទដូចជា៖

- ប្រើប្រាស់នីតិវិធីសាមញ្ញក្នុងការបង្កើតសិទ្ធិប្រាតិភោគ។ ពាក្យពេជន៍ដែលប្រើប្រាស់មិនចាំបាច់ពិសេស ព្រមទាំងមិនចាំបាច់បំពេញរូបមន្តពិសេសឡើយ នៅក្នុងកិច្ចព្រមព្រៀងប្រាតិភោគ។
- បុគ្គលគ្រប់រូបអាចផ្តល់ ឬ ទទួលយកសិទ្ធិប្រាតិភោគលើចលនវត្ថុបាន។
- ទ្រព្យធានាចលនវត្ថុគ្រប់ប្រភេទ រាប់ទាំងទ្រព្យរូបិយ និងទ្រព្យអរូបិយ (ភាគហ៊ុនក្នុងក្រុមហ៊ុន, សិទ្ធិអ្នកនិពន្ធជាដើម) ដែលមាននៅពេលបច្ចុប្បន្ន ឬនឹងមាននាពេលអនាគត។
- កិច្ចព្រមព្រៀងប្រាតិភោគតែមួយអាចបង្កើត សិទ្ធិប្រាតិភោគលើទ្រព្យធានាដែលនឹងកើតមាននៅពេលអនាគត នាំឱ្យកាត់បន្ថយការចំណាយច្រើនលើការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងជាថ្មី និង គោរពតាមលក្ខខណ្ឌច្បាប់ផ្សេងៗ។
- កាត់បន្ថយឧបសគ្គក្នុងការទទួលបានឥណទានអាជីវកម្ម។

**២. ការបញ្ជាក់ច្បាស់លាស់ពីសិទ្ធិ និង ភាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យា**

ហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ គឺពិតជាសំខាន់នៅក្នុងវិស័យពាណិជ្ជកម្ម ដោយសារតែដើម្បីទាក់ទាញអ្នកវិនិយោគ យើងត្រូវធ្វើយ៉ាងណាពង្រឹងនូវវិស័យច្បាប់ និងយុត្តាធិការឱ្យមានភាពរឹងមាំជាមុនសិន ដើម្បីបង្កើនទំនុកចិត្តដល់អ្នកវិនិយោគទុន ក្នុងការប្រកបអាជីវកម្មរបស់ពួកគេ។ លើសពីនេះទៅទៀត វិធានច្បាប់ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីសិទ្ធិ និងករណីកិច្ចរបស់ភាគីនីមួយៗដើម្បីឱ្យពួកគេបានដឹងពីសិទ្ធិនិងកាតព្វកិច្ចមុននឹងចាប់ផ្តើមប្រតិបត្តិការដោយសុវត្ថិភាព។ ជាក់ស្តែងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ក៏បានចែងយ៉ាងច្បាស់ផងដែរពីករណីទាំងអស់នេះដូចជា៖

- ផ្តល់ឱ្យនូវឥណទាយកយល់ដឹងពីសិទ្ធិរបស់ពួកគេ ទល់ទៅនឹងកូនបំណុល ឬឥណទាយកដទៃទៀតមុននឹងមានវិវាទ ដែលផ្តល់លទ្ធភាពក្នុងការផ្តល់ឥណទានកាន់តែកើនឡើង។
- ផ្តល់ឱ្យនូវការប្រើប្រាស់ចលនវត្ថុក្នុងការធានាបំណុល ឱ្យអស់ពីសក្តានុពលរបស់វា។
- ផ្តល់ឱ្យនូវរូបមន្តថ្មីក្នុងការដោះស្រាយការទាមទារប្រជែងលើទ្រព្យតែមួយ ដោយលុបចោលនូវភាពខុសគ្នានៃរូបមន្តច្បាប់ទាំងឡាយ។

- ផ្តល់លទ្ធភាពដល់ឥណទាយក្នុងការវាយតម្លៃពីហានិភ័យរបស់ពួកគេជាមុន និងអាចរកវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងអស់នោះ ក្នុងគោលដៅបង្កើនលទ្ធភាពឥណទានរបស់ពួកគេ។

**៣. ផ្តល់បច្ចេកទេសថ្មីស្តីពីការតម្កល់**

ការិយាល័យតម្កល់ ជាការិយាល័យដែលទទួលបន្ទុកចាត់ចែងការតម្កល់តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ នៅក្នុងប្រព័ន្ធច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានផ្តល់ឱ្យនូវការតម្កល់លិខិតជូនដំណឹងដែលជាយុទ្ធសាស្ត្រមួយជួយជំរុញឱ្យកាន់តែមានប្រសិទ្ធិភាពក្នុងវិស័យឥណទាន ដូចជា៖

- ផ្តល់ភាពងាយស្រួល ឆាប់រហ័ស ច្បាស់លាស់ និងចំណាយតិចដល់អ្នកឱ្យខ្ចី ក្នុងការកំណត់ថាតើមានការទាមទារដទៃទៀតលើទ្រព្យធានាដែរឬទេ។
- ចៀសពីការតម្កល់បែបប្រពៃណី និងចំណាយក្រៅផ្លូវការ និងការិយាល័យធិបតេយ្យ (អំពើពុករលួយ)។
- ការតម្កល់អាចធ្វើទៅបានតាមរយៈប្រព័ន្ធអ៊ីនធើណែតភ្លាមៗ នៅកន្លែងឥណទាយកតែម្តង។
- លិខិតជូនដំណឹងមានលក្ខណៈសាមញ្ញដែលគ្រាន់តែប្រាប់ពីអត្តសញ្ញាណ និងអធិប្បាយពីទ្រព្យធានាឱ្យបានសមស្របតែប៉ុណ្ណោះ។

**៤. ការបង្កើនប្រសិទ្ធិភាពក្នុងវិស័យប្រាតិភោគ**

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ពង្រឹងនីតិវិធីអនុវត្ត ដោយធានានូវសិទ្ធិរបស់ឥណទាយកក្នុងការកាន់កាប់ទ្រព្យធានាក្នុងករណីកូនបំណុលមិនអនុវត្តន៍កាតព្វកិច្ច ហើយធានាឱ្យឥណទាយកមានលទ្ធភាពលក់ទ្រព្យធានា តាមនីតិវិធីស្របច្បាប់ដើម្បីយកប្រាក់ទៅទូទាត់បំណុលដែលមានកិច្ចធានា ដែលយើងនឹងធ្វើការសិក្សានៅជំពូកទី៣។

**កថាខណ្ឌទី២ ការពង្រីកវិសាលភាពនៃទ្រព្យធានា**

បើយើងក្រឡេកមើលទៅលើ របបប្រាតិភោគ ក្នុងប្រព័ន្ធគតិយុត្តរបស់កម្ពុជា យើងអាចបែងចែកជាពីរប្រភេទ គឺ ៖ សិទ្ធិប្រាតិភោគបុគ្គល ដែលជាការធានាកាតព្វកិច្ចដោយបុគ្គល និងសិទ្ធិប្រាតិភោគប្រត្យក្ស ។ យ៉ាងណាមិញនៅក្នុងការប្រើប្រាស់ទ្រព្យធានាប្រភេទនីមួយៗសុទ្ធតែមានគុណសម្បត្តិ និងផលវិបាកអាស្រ័យលើការវិចម្រើននៃសង្គម។

ជាបឋមការធានាកាតព្វកិច្ចអាចធ្វើឡើងដោយមានការធានា ដែលវាជាសញ្ញាណដំបូងគេនៅក្នុងការអនុវត្តបែបគតិយុត្ត។ ការធានាកាតព្វកិច្ច គឺសំដៅទៅលើការធានាដោយបុគ្គលដែលភាគីកូនបំណុលគ្រាន់តែរកតតិយជនណាម្នាក់មកធ្វើកិច្ចជាមួយនឹងម្ចាស់បំណុល ដើម្បីទទួលកាតព្វកិច្ចរួមគ្នាជាមួយកូនបំណុល ពោលគឺករណីដែលកូនបំណុលមិនបំពេញកាតព្វកិច្ចតាមការសន្យានោះទេ ម្ចាស់បំណុលអាចទាមទារឱ្យអ្នកធានានោះអនុវត្តកាតព្វកិច្ចមកឱ្យខ្លួនបាន។ ការធានាតាមរូបភាពនេះផ្តល់ភាពងាយស្រួលដល់ម្ចាស់បំណុល ដោយហេតុថាគេមិនចាំបាច់មានទ្រព្យដើម្បីធានាកាតព្វកិច្ចចំពោះម្ចាស់បំណុលនោះទេ ក៏ប៉ុន្តែផលវិបាកនៃប្រព័ន្ធមួយនេះគឺការដាក់បន្ទុកហានិភ័យទៅលើម្ចាស់បំណុលបន្តិចដោយហេតុថាបើកូនបំណុលមិនអនុវត្តកាតព្វកិច្ច ហើយអ្នកធានាមិនអាចអនុវត្តកាតព្វកិច្ចបានទៀតនោះ តើម្ចាស់បំណុលមានយន្តការបែបណាក្នុងការទទួលបានការសងកាតព្វកិច្ចនោះ។ បញ្ហានេះបាន ផ្តល់នូវការលំបាកក្នុងការផ្តល់នូវកម្ចីដែលមានចំនួនទឹកប្រាក់ច្រើន ព្រោះហានិភ័យខ្ពស់ ដែលធ្វើឱ្យមានការរាំងស្ទះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ឬនិយាយដោយឡែកការវិនិយោគ។

ហេតុនេះហើយបានជាមានការវិវត្តនៅក្នុងប្រព័ន្ធនៃធានាកាតព្វកិច្ច គឺការទទួលយកអចលនវត្ថុដើម្បីធានាកាតព្វកិច្ច។ ប្រាតិភោគលើអចលនវត្ថុបានផ្តល់ទំនុកចិត្តមុតមាំជាងការធានាដោយបុគ្គលសម្រាប់ម្ចាស់បំណុល ព្រោះថាបើកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចបាន ម្ចាស់បំណុលអាចអនុវត្តសិទ្ធិរបស់ខ្លួនតាមផ្លូវតុលាការបាន។ ម្យ៉ាងវិញទៀត ការយកអចលនវត្ថុមកធានាកាតព្វកិច្ចអាចទទួលបានហិរញ្ញប្បទានច្រើនជាងការធានាដោយបុគ្គល ហេតុនេះសកម្មភាពសេដ្ឋកិច្ចក៏មានការកើនឡើងផងដែរ។ ប៉ុន្តែបើទោះបីជាការធានាដោយអចលនវត្ថុបានផ្តល់នូវផលវិជ្ជមានថែមមួយកម្រិតក៏ដោយ ក៏ផលអវិជ្ជមានដែលកើតចេញពីការធានានោះគឺទីមួយមិនមែនគ្រប់កូនបំណុលមានអចលនវត្ថុសម្រាប់ធានាកាតព្វកិច្ចរបស់ពួកគេនោះទេ ព្រោះថាអចលនវត្ថុមានតម្លៃថ្លៃ។ ចំណុចទីពីរនោះគឺការធានាកាតព្វកិច្ចដោយអចលនវត្ថុ ទាមទារឱ្យមានការចុះបញ្ជីដើម្បីបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិតតាំងចំពោះតតិយជន ដែលទាមទារឱ្យមានការឆ្លងកាត់នូវនីតិវិធីមួយចំនួន ហើយការអនុវត្តសិទ្ធិទាមទារឱ្យមានការឆ្លងកាត់នីតិវិធីតុលាការផងដែរ។

ដោយមើលឃើញពីផលវិបាកក្នុងការធានាកាតព្វកិច្ចដោយអចលនវត្ថុបែបនេះហើយ ទើបមានសញ្ញាណនៃការធានាកាតព្វកិច្ចថ្មីមួយត្រូវបានអនុវត្ត គឺការធានាកាតព្វកិច្ចដោយចលនវត្ថុ។ ការយកចលនវត្ថុមកធ្វើជាទ្រព្យធានា បានផ្តល់នូវភាពងាយស្រួលយ៉ាងខ្លាំងដល់កូនបំណុលព្រោះពួកគេអាចចាត់ចែង ដោយសេរីនូវចលនវត្ថុរបស់ពួកគេ ដើម្បីទទួលបានផលប្រយោជន៍នៃហិរញ្ញប្បទាន។ យ៉ាងណាប្រភេទនៃចលនវត្ថុដែលអាចយកមកធានាកាតព្វកិច្ចបាននេះត្រូវបាន

កម្រិតយកតែប្រភេទនៃចលនវត្ថុជាក់លាក់ប៉ុណ្ណោះ ហើយលក្ខខណ្ឌនៃសិទ្ធិតតាំងជាគោលការណ៍ទាមទារឱ្យមានការកាន់កាប់កម្មវត្ថុ ហើយចៀសមិនផុតពីសោហ៊ុយចំណាយផ្សេងៗ ហើយមានហានិភ័យផងដែរបើមានការបាត់បង់។ មួយវិញទៀតប្រភេទនៃចលនវត្ថុដែលអាចក្លាយជាកម្មវត្ថុនៃការធានានេះអាចមានទំហំតូច ដែលនាំឱ្យការធានាមានចំនួនទឹកប្រាក់តិច។ បើសិនជាទ្រព្យធានាជាចលនវត្ថុដែលមានតម្លៃ នោះនឹងមានការចុះបញ្ជីចលនវត្ថុនោះ ដែលមិនចៀសមិនផុតពីការអនុវត្តនូវនីតិវិធីវែងឆ្ងាយនោះទេ។ អ្វីទាំងអស់នេះ មិនមែនជាអ្វីដែលអ្នកជំនួញ ឬក្រុមពាណិជ្ជករចង់បាននោះទេ ព្រោះវាខាតពេលវេលា និងត្រូវចំណាយទឹកប្រាក់ច្រើន។

ក្នុងន័យបំពេញបន្ថែមលើប្រតិបត្តិការខាងលើនេះ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដែលជាច្បាប់មានលក្ខណៈទំនើប ត្រូវបានបង្កើតឡើងក្នុងគោលបំណងសម្របសម្រួលដល់ប្រតិបត្តិការសេដ្ឋកិច្ចឱ្យកាន់តែប្រសើរ ដោយបានពង្រីកវិសាលភាពនៃទ្រព្យធានា។ នៅក្នុងច្បាប់នេះ ទ្រព្យធានាមានតែចលនវត្ថុប៉ុណ្ណោះ ប៉ុន្តែប្រភេទថ្មីៗផ្សេងទៀតនៃទ្រព្យធានាត្រូវបានបង្ហាញឡើង ដើម្បីជាការសម្របសម្រួលផ្នែកសេដ្ឋកិច្ច។ ជាបន្ត ប្រភេទនៃទ្រព្យធានាដែលត្រូវធានានឹងត្រូវធ្វើការបកស្រាយនៅក្នុងចំណុចស្តីអំពីកម្មវត្ថុនៃប្រតិបត្តិការដែលមានកិច្ចធានា ចំណែកឯគុណសម្បត្តិ និងផលវិបាករបស់ប្រព័ន្ធដែលថ្មីសន្លាងនឹងត្រូវបង្ហាញជាបន្តបន្ទាប់នៅក្នុងអត្ថបទស្រាវជ្រាវនេះ។

មកដល់ចំណុចនេះ អ្វីដែលជាសញ្ញាណនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលជាមូលដ្ឋានគ្រឹះក្នុងសិក្សាអំពីប្រតិបត្តិការប្រាតិភោគចលនវត្ថុ តាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាត្រូវបានបង្ហាញដោយរួមមានទាំងគោលបំណង និងការវិវត្តនៃច្បាប់នេះ។ ជំពូកបន្តបន្ទាប់យើងនឹងធ្វើការសិក្សាពីលំហូរនីតិវិធីនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា ព្រមទាំងការអនុវត្តសិទ្ធិតាមច្បាប់នេះផងដែរ។

# ជំពូកទី២
# ការបង្កើត និងអានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា

បន្ទាប់ពីបានធ្វើការស្វែងយល់ពីសញ្ញាណទូទៅ នៃប្រតិបត្តិការដែលមានកិច្ចធានានៅក្នុងជំពូកទី១រួចហើយ ជំពូកទី២នេះយើងនឹងធ្វើការសិក្សាអំពីការបង្កើតប្រតិបត្តិការនេះរួមជាមួយនឹងអានុភាពនៃប្រតិបត្តិការផងដែរ។ ជាបឋម លក្ខខណ្ឌក្នុងការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា និងអានុភាពចំពោះភាគីនឹងត្រូវបានលើកយកមកសិក្សា (ផ្នែកទី១) បន្ទាប់មកទៀតនឹងមានការសិក្សាអំពីសុក្រឹតកម្ម ដែលជាលក្ខខណ្ឌក្នុងការតតាំងជាមួយតតិយជន (ផ្នែកទី២)។

## ផ្នែកទី១ ការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាជាច្បាប់ពិសេស ប៉ុន្តែលក្ខខណ្ឌនៃការបង្កើតប្រតិបត្តិការមិនត្រូវបានបង្ហាញជាក់លាក់នោះទេ ដែលទាមទារឱ្យមានការប្រើប្រាស់វិធានដទៃស្តីពីកិច្ចសន្យាយកមកបំពេញបន្ថែម ហេតុដូច្នេះហើយទើបបទប្បញ្ញត្តិទូទៅនៃនីតិឯកជនក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧[4] ត្រូវយកមកអនុវត្ត ក្នុងការកំណត់អំពីលក្ខខណ្ឌនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា ដើម្បីបំពេញបន្ថែមទៅលើអ្វី ដែលមិនបានកំណត់នៅក្នុងច្បាប់ពិសេសនេះ ដោយស្រមតាមការកំណត់របស់ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ត្រង់ជំពូកទី៦ ស្តីពីការសម្របសម្រួលរវាងក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

### កថាខណ្ឌទី ១ លក្ខខណ្ឌក្នុងការបង្កើត

#### ១. កិច្ចព្រមព្រៀងប្រាតិភោគ

កិច្ចព្រមព្រៀងប្រាតិភោគ ត្រូវតែមានសុពលភាពទើបសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់ទៅនឹងទ្រព្យធានា។ កិច្ចព្រមព្រៀងប្រាតិភោគនេះ ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សររវាងគូភាគី ហើយវាអាចស្ថិតនៅក្នុងកំណត់ត្រាផ្សេងគ្នា តែអាចបង្ហាញពីសំណើ និងស្វីកាក្នុងការបង្កើតកិច្ចព្រមព្រៀងប្រាតិភោគនេះ[5]។ ក្រៅពីនេះដើម្បីឱ្យកិច្ចព្រមព្រៀងមានសុពលភាព ធាតុផ្សំចំនួនបីត្រូវតែ

---

[4] យោងតាមមាត្រា១ នៃក្រមរដ្ឋប្បវេណី បានបង្ហាញថាវាគឺជាច្បាប់ទូទៅនៃនីតិឯកជន ដូច្នេះប្រសិនមានបញ្ញត្តិពិសេសចែងចំពោះទំនាក់ទំនងជាក់លាក់ ក្រមនេះមិនត្រូវយកមកអនុវត្តឡើយ។

[5] មាត្រា៧ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាឆ្នាំ២០០៧

បំពេញគឺ កិច្ចព្រមព្រៀងតាមច្បាប់ធរមាននៃព្រះរាជាណាចក្រកម្ពុជា តម្លៃតបចំពោះកូនបំណុល និងសិទ្ធិលើទ្រព្យធានាដែលកូនបំណុលត្រូវមាន[6]។

### ក. កិច្ចព្រមព្រៀងតាមច្បាប់ធរមាននៃព្រះរាជាណាចក្រកម្ពុជា

ជាការបកស្រាយលក្ខណៈទ្រឹស្តី កិច្ចព្រមព្រៀងមួយមានសុពលភាពតាមច្បាប់ ឬតាមស្មារតីនៃក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ មានលក្ខខណ្ឌពីរគឺលក្ខខណ្ឌសុពល និងលក្ខខណ្ឌទម្រង់ ក៏ប៉ុន្តែនៅក្នុងចំណុចនេះយើងនឹងពិភាក្សាតែពីលក្ខខណ្ឌសុពលតែប៉ុណ្ណោះ។ លក្ខខណ្ឌសុពលក្នុងការបង្កើតកិច្ចព្រមព្រៀង គឺសំដៅទៅលើលក្ខខណ្ឌដែលជាមូលដ្ឋានក្នុងការបង្កើតអានុភាពនៃប្រតិបត្តិការនីមួយៗ។ លក្ខខណ្ឌមួយដែលសំខាន់សម្រាប់បង្កើតសុពលភាពនោះគឺសមត្ថភាពរបស់ភាគី។ សមត្ថភាពរបស់ភាគីតាមក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ត្រូវបានបែងចែកជាបីគឺ សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។ សមត្ថភាពទាំងបីនេះនឹងត្រូវយកមកប្រើប្រាស់ដើម្បីវិនិច្ឆ័យនូវរាល់សកម្មភាព ដែលភាគីនឹងបំពេញនៅក្នុងការបង្កើតកិច្ចព្រមព្រៀងផងដែរដូចជា ការធ្វើសំណើ និងការផ្តល់ស្ទីការ ការបង្ហាញឆន្ទៈដោយគ្មានវិការៈ ឬមោឃភាពជាអាទិ៍។ សកម្មភាពមួយអាចត្រូវបានចាត់ទុកថាមានវិការៈ ប្រសិនបើមានអង្គហេតុនៃការភ័ន្តច្រលំ ការឆបោក អំពើកេងចំណេញហួសហេតុ ឬអង្គហេតុដទៃទៀត ឯមោឃភាពជាសកម្មភាពដែលបំពាននឹងបញ្ញត្តិអនុវត្តដោយបង្ខំ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ ឬទំនៀមទម្លាប់ប្រពៃណីបវេណីល្អរបស់ខ្មែរ។

### ខ. ការបញ្ជាក់ឯកភាព

ការបញ្ជាក់ឯកភាព ជាចំណុចសំខាន់ដែលត្រូវតែមានសម្រាប់ការភ្ជាប់សិទ្ធិប្រាតិភោគទៅលើកម្មវត្ថុ។ ការបញ្ជាក់នេះត្រូវធ្វើឡើងដោយកូនបំណុលលើកិច្ចព្រមព្រៀងបង្កើតប្រតិបត្តិការ។ ការបញ្ជាក់ការឯកភាព គឺជាការចុះហត្ថលេខា ឬការឯកភាពលើឈ្មោះ ឬនិមិត្តសញ្ញាផ្សេងៗ ដែលធ្វើឡើងដោយផ្ទាល់ដៃ ឬតាមវិធីផ្សេងៗ ហើយមានគោលបំណងបញ្ជាក់ពីអត្តសញ្ញាណរបស់ភាគីដែលឯកភាព ឬផ្តល់ការឯកភាព ឬកំណត់ត្រាមានតម្លៃផ្លូវច្បាប់។ ការបញ្ជាក់នេះមានសារសំខាន់ព្រោះនៅក្នុងកិច្ចព្រមព្រៀងនេះបានបញ្ជាក់ពីទ្រព្យធានាដែលវាទាមទារឱ្យកូនបំណុលបញ្ជាក់ពីវា។

[6] ក្រសួងពាណិជ្ជកម្ម, *ឯកសារបណ្តុះបណ្តាល ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា*, ៦២-៨១

### គ. ការរៀបរាប់ពីទ្រព្យធានា

នៅក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ត្រូវតែមានការរៀបរាប់ពីទ្រព្យធានាឱ្យបានសមស្រប។ ការរៀបរាប់នេះដើម្បីកំណត់ពីអត្តសញ្ញាណនៃទ្រព្យធានាចំពោះគូភាគី ដើម្បីចៀសវាងការភ័ន្តច្រលំពីទ្រព្យធានានៅពេលអនុវត្តប៉ុណ្ណោះ ហេតុនេះការរៀបរាប់នោះមិនចាំបាច់ឱ្យវាលម្អិតពេកទេ ដោយគ្រាន់តែប្រើពាក្យថា ទ្រព្យសកម្មទាំងអស់ ឬចលនវត្ថុទាំងអស់គឺគ្រប់គ្រាន់ហើយ។ ទោះបីជាមានបញ្ញត្តិបែបនេះក្តី មានករណីពីរ ដែលជាករណីលើកលែង គឺយានយន្តដែលមានលេខសេរី ដែលទាមទារឱ្យមានការបញ្ជាក់លម្អិត និងទំនិញប្រើប្រាស់។

### ២. ការទទួលតម្លៃតបរបស់កូនបំណុល

កិច្ចព្រមព្រៀងប្រាតិភោគនឹងមិនមានអានុភាពទេ បើប្រតិបត្តិការនោះមិនបានធ្វើឱ្យកូនបំណុលទទួលតម្លៃតបជាប្រាក់ ឬវត្ថុណាមួយ។ ការកំណត់បែបនេះ គឺមិនមានអ្វីដែលប្លែកទេ ព្រោះថាគោលបំណងនៃការបង្កើតប្រាតិភោគ ដើម្បីទទួលបាននូវតម្លៃតបអ្វីមួយក្នុងគោលបំណងប្រើប្រាស់វាដើម្បីបង្កើនផលប្រយោជន៍ដល់ម្ចាស់កម្មសិទ្ធិនៃទ្រព្យធានា ឬកូនបំណុល។ បើកូនបំណុលយកទ្រព្យខ្លួនទៅដាក់ប្រាតិភោគដែលនាំឱ្យជាប់កាតព្វកិច្ច តែបែរជាមិនទទួលតម្លៃតបនោះ វាក៏មិនមានន័យអ្វីក្នុងការបង្កើតនូវកិច្ចសន្យាប្រាតិភោគគ្មានសិទ្ធិបែបនេះដែរ។ ឧទាហរណ៍ កូនបំណុលបានយកសត្វគោនៅក្នុងកសិដ្ឋានរបស់ខ្លួនទៅដាក់ធានាកាតព្វកិច្ច ដើម្បីជាតម្លៃតបនឹងប្រាក់ ១០០,០០០០ដុល្លារ។ កិច្ចសន្យានេះមានសុពលភាព ដោយសារតែវាកូនបំណុលបានទទួលតម្លៃតបជាទឹកប្រាក់១០០,០០០ដុល្លារ នៃការយកគោខ្លួនទៅដាក់ធានា។ ផ្ទុយមកវិញ បើកូនបំណុលយកគោទៅប្រគល់ជូនម្ចាស់បំណុល ដោយមិនមានតម្លៃតបអ្វីនោះទេ កិច្ចសន្យានោះមិនចាត់ទុកថាជាការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា។

### ៣. សិទ្ធិលើទ្រព្យធានា

ដើម្បីឱ្យប្រតិបត្តិការមានសុពលភាព កូនបំណុលត្រូវមានសិទ្ធិលើទ្រព្យធានា ឬមានអំណាចផ្ទេរសិទ្ធិលើទ្រព្យធានានោះទៅកាន់ម្ចាស់បំណុល។ សិទ្ធិក្នុងន័យនេះ សំដៅទៅលើសិទ្ធិកម្មសិទ្ធិ ទោះជាវាមិនបានកំណត់នៅក្នុងច្បាប់ក៏ដោយ តែគោលគំនិតនៃការប្រើប្រាស់សិទ្ធិនេះ គឺដើម្បីចាត់ចែងទ្រព្យធានា ដែលមានតែម្ចាស់កម្មសិទ្ធិករតែប៉ុណ្ណោះដែលអាចធ្វើបាន។ ការណ៍ដែលតម្រូវឱ្យកូនបំណុលត្រូវតែមានសិទ្ធិ ព្រោះប្រតិបត្តិការដែលមានកិច្ចធានាអាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិកាន់

កាប់ និងអនុវត្តសិទ្ធិរបស់ខ្លួនលើទ្រព្យធានាបាន ដូច្នេះសិទ្ធិរបស់កូនបំណុលមានសារៈសំខាន់ណាស់ក្នុងការចាត់ចែងសិទ្ធិនេះ។

**កថាខណ្ឌទី២ កម្មវត្ថុនៃទ្រព្យធានា**

ទ្រព្យធានាតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា គឺជាចលនវត្ថុ។ ជាទូទៅចលនវត្ថុមានច្រើនបែបច្រើនសណ្ឋានខ្លាំងណាស់ បញ្ហាដែលចោទឡើងនោះគឺ តើគ្រប់ចលនវត្ថុនឹងអាចក្លាយជាកម្មវត្ថុនៃការធានាកាតព្វកិច្ចតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ឬត្រូវមានការកម្រិតអំពីទំហំនៃចលនវត្ថុដែលនឹងក្លាយជាទ្រព្យធានា? នៅក្នុងចំណុចនេះ យើងនឹងធ្វើការបែងចែកអំពីប្រភេទនៃកម្មវត្ថុដែលស្ថិតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងប្រភេទនៃវត្ថុដែលត្រូវបានកម្រិតមិនឱ្យយកមកធ្វើជាកម្មវត្ថុនៃការធានា។

**១. ចលនវត្ថុដែលអាចក្លាយជាកម្មវត្ថុនៃទ្រព្យធានា**

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មានវិសាលភាពសឹងតែលើចលនវត្ថុគ្រប់ប្រភេទ ជាហេតុនាំឱ្យការកំណត់ថាតើចលនវត្ថុប្រភេទណា ស្ថិតនៅក្រោមច្បាប់នេះមិនមែនជារឿងដែលងាយស្រួលនោះទេ។ ដើម្បីជួយសម្រួលដល់ការសិក្សា ផ្នែកនេះនឹងបង្ហាញពីប្រភេទនៃចលនវត្ថុដែលជាកម្មវត្ថុដោយការធ្វើចំណាត់ថ្នាក់ចលនវត្ថុ។ វិធីក្នុងការធ្វើចំណាត់ថ្នាក់មានច្រើនបែបច្រើនទម្រង់ ក៏ប៉ុន្តែកិច្ចការនឹងជ្រើសរើសវិធីធ្វើចំណាត់ថ្នាក់ប្រភេទនៃចលនវត្ថុជាពីររូបភាពគឺ ចលនវត្ថុរូបី និងចលនវត្ថុអរូបី ដែលនៅក្នុងប្រភេទនៃចលនវត្ថុនីមួយៗមានការបែងចែកបន្តទៅទៀតដើម្បីបង្កភាពងាយស្រួលដល់ការសិក្សា។ ការធ្វើចំណាត់ថ្នាក់ទ្រព្យធានា មិនមែនត្រឹមតែដើម្បីបង្កលក្ខណៈងាយស្រួលដល់ការសិក្សាតែប៉ុណ្ណោះទេ តែវាមានភាពចាំបាច់ដើម្បីកំណត់ពីវិសាលភាពនៃទ្រព្យធានាដែលស្ថិតនៅក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា វិធីក្នុងការបង្កើតប្រតិបត្តិការធានា រួមទាំងវិធីក្នុងការធ្វើសុក្រឹតកម្មទ្រព្យធានានោះថែមទៀតផង។ ថ្វីត្បិតតែមានការបែងចែងនូវប្រភេទទ្រព្យធានាបែបនេះក៏ដោយ តែចលនវត្ថុមួយចំនួនអាចចាត់ចូលទៅក្នុងចំណាត់ថ្នាក់នៃកម្មវត្ថុជាច្រើន ដូចជាទ្រព្យមួយអាចជាសារពើភណ្ឌផង ហើយវាអាចក្លាយជាទំនិញប្រើប្រាស់ផងដែរនៅពេលក្រោយ។ ហេតុនេះហើយ ការកំណត់ពេលវេលាមូលដ្ឋាននៃការធ្វើចំណាត់ថ្នាក់ គឺត្រូវយកពេលវេលានៃការភ្ជាប់សិទ្ធិប្រាតិភោគ ព្រោះថាទ្រព្យជាចលនវត្ថុនឹងក្លាយជាទ្រព្យធានានៅពេលដែលវាត្រូវបានភ្ជាប់ដោយសិទ្ធិប្រាតិភោគ។ ហេតុដូច្នេះហើយ ការកំណត់យក

ពេលវេលានៃការភ្ជាប់សិទ្ធិប្រាតិភោគធ្វើជាពេលវេលានៃការកំណត់ប្រភេទនៃទ្រព្យ ជាពេលវេលាដ៏សាកសមបំផុត។

**គ. ចលនវត្ថុរូបី**

ពាក្យថា ចលនវត្ថុរូបី បានកំណត់អំពីលក្ខណៈនៃកម្មវត្ថុនេះរួចស្រេចទៅហើយ។ ចលនវត្ថុជាវត្ថុទាំងឡាយណាដែលក្រៅពី អចលនវត្ថុដែលមិនអាចផ្លាស់ប្តូរទីកន្លែងបានដូចជា ដីធ្លី វត្ថុជាប់ដី (សំណង់ ដំណាំ រុក្ខជាតិជាអាទិ៍)[7]។ នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ចលនវត្ថុរូបីអាចត្រូវបានបែងចែកជាច្រើនប្រភេទដូចជា ទំនិញ កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារកម្មសិទ្ធិ លិខិតស្នាម និងរូបិយប័ណ្ណ។

**គ.១ ទំនិញ**

ទំនិញ គឺជាវត្ថុដែលជាចលនវត្ថុក្នុងពេលដែលសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងវត្ថុនេះ[8]។ ក៏ប៉ុន្តែការលើកឡើងបែបនេះមានវិសាលភាពទូលំទូលាយខ្លាំងណាស់ ព្រោះថាឱ្យតែជាវត្ថុដែលជាចលនវត្ថុនឹងត្រូវបញ្ចូលទៅក្នុងចំណុចនេះទាំងអស់។ ហេតុនេះហើយនៅក្នុងទំនិញ ច្បាប់នេះបានកម្រិតនូវវិសាលភាពនៃទំនិញត្រឹមតែផលិតផលរ៉ែ ដែលត្រូវភ្ជាប់សិទ្ធិប្រាតិភោគនៅពេលជីកបាន ឈើឈរដែលត្រូវកាប់ កូនសត្វពាហនៈមិនទាន់កើត និងផលដំណាំដែលបានដាំដុះ កំពុងលូតលាស់ ឬដែលត្រូវដាំដុះ រាប់បញ្ចូលទាំងផលដំណាំនៅជាប់នឹងដើម ប្រេង ជ័រ ឬរុក្ខជាតិផងដែរ។ ចំណែកឯគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា រូបិយប័ណ្ណ ឯកសារ ឬលិខិតស្នាម មិនត្រូវរាប់បញ្ចូលទៅក្នុងប្រភេទនៃទំនិញនោះទេ។ បើទោះបីជាមានការកម្រិតនូវដែននៃទំនិញយ៉ាងនេះក្តី វិសាលភាពនៃទំនិញនៅតែមានលក្ខណៈទូលាយដែលតម្រូវឱ្យបានការបែងចែកជាបន្តនូវប្រភេទនៃទំនិញ ដើម្បីបង្ហាញពីលក្ខណៈនៃទ្រព្យធានា។ ទំនិញត្រូវបានបែងចែកជាប្រាំប្រភេទផ្សេងទៀត ដូចជាសារពើភណ្ឌ កសិផល ឧបករណ៍ ទំនិញប្រើប្រាស់ និងចលនវត្ថុតាំងភ្ជាប់។

**គ.១.១ សារពើភណ្ឌ**

សារពើភណ្ឌ គឺជាទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬជាវត្ថុធាតុដើម គម្រោងដែលកំពុងដំណើរការ សម្ភារៈប្រើប្រាស់ក្នុងអាជីវកម្ម[9]។ ឧបមាថា ក្រុមហ៊ុនផលិតម៉ូតូមួយកន្លែង

[7] មាត្រា១២០ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧

[8] មាត្រា ៣ ចំណុច១៥ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

[9] មាត្រា ៣ ចំណុច២៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

បានផលិតម៉ូតូសម្រាប់ធ្វើអាជីវកម្មចែកចាយបន្ត ដោយមានឃ្លាំងជាច្រើនកន្លែងសម្រាប់ទុកដាក់ម៉ូតូដែលបានផលិតរួចរាល់។ ដោយមើលឃើញពីការរីកចម្រើនខាងអាជីវកម្មរបស់ខ្លួន ក្រុមហ៊ុនផលិតម៉ូតូនេះមានបំណងចង់ពង្រីកអាជីវកម្មរបស់ខ្លួន ទើបបានទៅស្នើសុំប្រាក់កម្ចីពីធនាគារមួយដោយយកម៉ូតូនៅក្នុងឃ្លាំងរបស់ខ្លួនធ្វើជាទ្រព្យធានា។ ក្នុងឧទាហរណ៍នេះ ទ្រព្យធានាដែលជាម៉ូតូនៅក្នុងឃ្លាំងនេះជាសារពើភណ្ឌ ព្រោះម៉ូតូជាចលនវត្ថុដែលម្ចាស់ក្រុមហ៊ុន ឬកូនបំណុលនៃប្រតិបត្តិការដែលមានកិច្ចធានាកាន់កាប់ក្នុងគោលបំណងសម្រាប់ទុកលក់។

### ក.១.២ ទំនិញប្រើប្រាស់

ទំនិញប្រើប្រាស់ ជាទំនិញដែលត្រូវបានប្រើប្រាស់ជាចម្បងសម្រាប់គោលបំណងផ្ទាល់ខ្លួនសមាជិកគ្រួសារ ឬសម្រាប់គោលបំណងគ្រួសារ លើកលែងតែយានយន្តដែលមានលេខសេរី[10]។ តាមការកំណត់នៃច្បាប់ ទំនិញប្រើប្រាស់មិនអាចយកមកធ្វើជាកម្មវត្ថុនៃទ្រព្យធានានោះទេ តែការដែលយើងសម្រេចយកចំណុចនេះមកសិក្សាដែរ ព្រោះវាមានទំនាក់ជាមួយនឹងឧបករណ៍ និងសារពើភណ្ឌដែលធ្វើឱ្យវាអាចផ្លាស់ប្តូរចំណាត់ថ្នាក់នៃទ្រព្យបាន ហើយម្យ៉ាងទៀតបើទោះជាច្បាប់មិនអនុញ្ញាតឱ្យបង្កើតកិច្ចធានាលើទំនិញប្រើប្រាស់ក៏ដោយ ក៏ច្បាប់បានអនុញ្ញាតឱ្យបង្កើតកិច្ចធានាលើប្រាក់ទិញទំនិញប្រើប្រាស់បានដែរ ហេតុនេះការកំណត់ពីសញ្ញាណនៃទំនិញប្រើប្រាស់ជារឿងចាំបាច់។ ទំនិញប្រើប្រាស់មានច្រើនបែបច្រើនសណ្ឋានឱ្យតែយើងអាចបង្ហាញបានថាយើងប្រើវាក្នុងជីវភាពប្រចាំថ្ងៃសម្រាប់ខ្លួនឯងផ្ទាល់ ឬសម្រាប់ក្រុមគ្រួសារដូចជាទូរទស្សន៍ កុំព្យូទ័រ ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបោកសម្លៀកបំពាក់ជាអាទិ៍។ ការណ៍ដែលច្បាប់មិនអនុញ្ញាតឱ្យយកទំនិញប្រើប្រាស់មកធ្វើជាទ្រព្យធានា អាចមកពីការដាក់ទំនិញប្រើប្រាស់ជាទ្រព្យធានាអាចធ្វើឱ្យអ្នកទិញមិនហ៊ានទិញទំនិញក្នុងគោលបំណងប្រើប្រាស់ទូទៅនោះទេ ដោយខ្លាចថាវានឹងក្លាយជាកម្មវត្ថុនៃការអនុវត្តសិទ្ធិរបស់ម្ចាស់សិទ្ធិនៅពេលណាក៏បាន បើកូនបំណុលមិនអាចអនុវត្តកាតព្វកិច្ចបាន។ សកម្មភាពបែបនេះនឹងបង្អាក់សកម្មភាពសេដ្ឋកិច្ច ដែលមិនមែនជាគោលបំណងនៃការបង្កើតច្បាប់នេះទេ។ ផ្ទុយទៅវិញ ការបង្កើតកិច្ចធានាលើប្រាក់ទិញទំនិញប្រើប្រាស់ ត្រូវបានអនុញ្ញាត ព្រោះវានឹងជួយបង្កើនអត្រាលក់តាមរយៈការផ្តល់ហិរញ្ញប្បទាន ដែលនឹងជួយជំរុញសកម្មភាពសេដ្ឋកិច្ចបានមួយចំណែក ហើយម្ចាស់សិទ្ធិលើប្រាតិភោគលើទំនិញប្រើប្រាស់នឹងប្រាកដថាខ្លួនអាចប្រមូលនូវមូលនិធិរបស់ខ្លួនត្រលប់មកវិញបានតាមរយៈសិទ្ធិប្រាតិភោគដែលនឹងភ្ជាប់ទៅលើទំនិញនោះ។

[10] មាត្រា ៣ ចំណុច១៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

**ក.១.៣ ឧបករណ៍**

ឧបករណ៍ ជាសារពើភណ្ឌ ឬទំនិញប្រើប្រាស់[11]។ ពេលធ្វើការសិក្សាមកដល់ចំណុចនេះ វាអាចនឹងមានការភ័ន្តច្រលំគ្នា ថាហេតុអ្វីទើបបានជាបង្កើតនូវសញ្ញាណនៃឧបករណ៍ផង សារពើភណ្ឌផង ហើយនៅមានទំនិញប្រើប្រាស់ថែមទៀត ថាតើទ្រព្យក្នុងប្រភេទទាំងបីនេះមានលក្ខណៈខុសគ្នាបែបណា ហើយវាមានប្រយោជន៍អ្វីនៅក្នុងការបែងចែក ចុះពេលអនុវត្តត្រូវធ្វើបែបណាវិញ? ឧបករណ៍ជាប្រភេទចុងក្រោយសម្រាប់ការបែងចែកគ្នារវាងសារពើភណ្ឌ ទំនិញប្រើប្រាស់ និងឧបករណ៍។ ដូច្នេះហើយនៅក្នុងការអនុវត្ត យើងត្រូវធ្វើការកំណត់ជាមុនសិនថាទ្រព្យដែលយកមកធានាជាទំនិញប្រើប្រាស់ ឬសារពើភណ្ឌ បើមិនមែននោះយើងអាចចាត់ថ្នាក់វាចូលក្នុងឧបករណ៍បាន[12]។ ការបែងចែកនេះវាមានអត្ថប្រយោជន៍នៅពេលដែលយើងធ្វើការសិក្សានៅចំណុចបន្ទាប់អំពីការធ្វើសុក្រឹតកម្មទ្រព្យធានា ហេតុនេះហើយចំណុចនេះនឹងមិនត្រូវធ្វើការបកស្រាយអំពីផលប្រយោជន៍នៃការបែងចែកនោះទេ។ ជាឧទាហរណ៍ ក្រុមហ៊ុនផលិតតុទូមួយ បានផលិតតុទូទុកសម្រាប់លក់ ដោយបានដាក់១០០ឈុតនៅក្នុងឃ្លាំងរបស់ខ្លួនសម្រាប់លក់ ហេតុនេះវាជាសារពើភណ្ឌ ប៉ុន្តែក្រោយមកម្ចាស់ក្រុមហ៊ុនបានយកតុទូ១០ឈុត មកប្រើប្រាស់នៅក្នុងការិយាល័យលក់របស់ខ្លួន។ ដូច្នេះតុទូ១០ឈុតដែលយកមកនោះលែងជាសារពើភណ្ឌទៀតហើយព្រោះវាបានបាត់បង់លក្ខណៈសម្បត្តិតាមនិយមន័យនៃសារពើភណ្ឌ ហើយវាក៏មិនបានបំពេញលក្ខខណ្ឌនៃទំនិញប្រើប្រាស់ដែរ។ ដូច្នេះវាក្លាយជាឧបករណ៍ ឯតុទូ៩០ឈុតដែលនៅសល់នៅតែជាសារពើភណ្ឌដដែល។

**ក.១.៤ កសិផល**

កសិផល ជាទំនិញរបស់កូនបំណុលដែលទាក់ទងនឹងកសិដ្ឋាន លើកលែងតែឈើឈរ[13]។ កសិផលមានដូចជា៖

- ផលដំណាំដែលដាំដុះ កំពុងលូតលាស់ ឬផលដំណាំ ដែលត្រូវដាំដុះ
- ទំនិញជលផលដែលផលិតក្នុងប្រតិបត្តិការវារីវប្បកម្ម
- សត្វពាហនៈ រាប់ទាំងកូនសត្វដែលសម្រាលហើយ ឬមិនទាន់សម្រាលហើយផងដែរ

[11] មាត្រា ៣ ចំណុច៣៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមាកិច្ចធានា

[12] ការប្រៀបធៀបនេះស្ថិតនៅក្នុងរង្វង់នៃសារពើភណ្ឌ ទំនិញប្រើប្រាស់ និងឧបករណ៍ ចំណែកចំណាត់ថ្នាក់ផ្សេងទៀតនៃទំនិញប្រើប្រាស់ មិនត្រូវយកមកបកស្រាយនៅក្នុងការប្រៀបធៀបនេះនោះទេ

[13] មាត្រា ៣ ចំណុច១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

- ទំនិញផ្គត់ផ្គង់ដែលប្រើ ឬផលិតក្នុងប្រតិបត្តិការកសិកម្ម
- ផលដំណាំដែលទទួលបានមកពីការប្រមូលផល ឬផលដែលបានមកពីសត្វពាហនៈ ហើយមិនទាន់កែច្នៃ

ជាឧទាហរណ៍ម្ចាស់ចំការកៅស៊ូមួយកន្លែង បានបង្កើតប្រតិបត្តិការដែលមានកិច្ចធានាដោយយកដើមកៅស៊ូនៅក្នុងចំការខ្លួនដែលទើបតែដាំធ្វើជាទ្រព្យធានាកាតព្វកិច្ចចំនួន ២៥,០០០ ដុល្លារ ដើម្បីយកមកប្រាក់មកទិញជីសម្រាប់ដាក់ដំណាំកៅស៊ូនោះ។ ប្រតិបត្តិការអាចធ្វើបានក្រោមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ព្រោះកូនកៅស៊ូជាកសិផល ហើយវានឹងផ្តល់ផលនៅពេលអនាគតដែលអាចឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិរបស់គាត់បាននៅពេលអនាគត។

**ក.១.៥ ចលវត្ថុតាំងភ្ជាប់**

ចលនវត្ថុតាំងភ្ជាប់ជាទំនិញដែលត្រូវបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬមានគោលបំណងភ្ជាប់ទៅនឹងអចលនវត្ថុតាមរបៀបណាមួយដែលនាំឱ្យមានសិទ្ធិភណ្ឌិកកើតឡើងតាមច្បាប់ភូមិបាលឆ្នាំ ២០០១[14]។

**ក.២ កិច្ចសន្យាលក់ដែលមានកិច្ចធានា**

កិច្ចសន្យាលក់ដែលមានកិច្ចធានា[15] ជាកំណត់ត្រាដែលបង្កើតឱ្យមានកាតព្វកិច្ចបង់ប្រាក់របស់អតិថិជន តាមការកំណត់របស់អ្នកលក់ ហើយមានសិទ្ធិប្រាតិភោគលើទំនិញ ឬការជួលទំនិញ[16]។ ឧទាហរណ៍ ក បានលក់កុំព្យូទ័រ១០០គ្រឿងឱ្យ ខ និងបានព្រមព្រៀងគ្នាថា ខ នឹងបង់ប្រាក់ជូន ក ក្នុងរយៈពេលមួយខែ ដោយយកទំនិញក្នុងហាងរបស់ ខ មកដាក់ជាទ្រព្យធានាតាមរយៈឯកសារកំណត់ត្រាជាលាយលក្ខណ៍អក្សរ។ ឯកសារដែលត្រូវបានធ្វើនោះជាកិច្ចសន្យាលក់ដែលមានកិច្ចធានា។ បើយើងពិនិត្យមើលលើលក្ខណៈនៃកិច្ចសន្យានេះ យើងអាចសន្និដ្ឋានបានថាប្រភេទនៃកិច្ចសន្យាបែបនេះ បម្រើគោលបំណងជំនួញច្រើនជាងប្រតិបត្តិការធម្មតារវាងប្រជាជនសាមញ្ញ។

---

[14] មាត្រា ៣ ចំណុច១៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ប៉ុន្តែមានការធ្វើវិសោធនកម្មលើច្បាប់ភូមិបាល ២០០១ ដូច្នេះសញ្ញាណនេះគួរគប្បីបកស្រាយតាមក្រមរដ្ឋប្បវេណីវិញ

[15] នៅក្នុងសៀវភៅ ការពន្យល់ និងឧទាហរណ៍ ស្តីពីប្រតិបត្តិការដែលមាកិច្ចធានា ទំព័រ២៩ ប្រើប្រាស់ពាក្យនេះជា កិច្ចសន្យាលក់ដែលមានកិច្ចធានាជលប័ត្រពាណិជ្ជកម្ម។ នៅក្នុងការបកស្រាយ កិច្ចសន្យាលក់ដែលមានកិច្ចធានា មាននិយមន័យដូចគ្នានឹងជលប័ត្រពាណិជ្ជកម្មដែរក្នុងក្រមឯកភាពពាណិជ្ជកម្មរបស់អាមេរិក ឯការអនុវត្តទៀតសោតក៏មានលក្ខណៈស្រដៀងគ្នាទៅនឹងប្រទេសដទៃទៀត ទើបនៅក្នុងចំណុចនេះច្បាប់ប្រើពាក្យថាកិច្ចសន្យាលក់ដែលមានកិច្ចធានាតែម្តង។

[16] មាត្រា ៣ ចំណុច ៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

**ក.៣ ឯកសារកម្មសិទ្ធិ**

ឯកសារកម្មសិទ្ធិ សំដៅទៅលើបង្កាន់ដៃឃ្លាំង បង្កាន់ដៃដឹកជញ្ជូន ឬបង្កាន់ដៃរ៉ាប់រងកំពង់ផែ ដែលចេញដោយបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ឬស្តុកទំនិញ[17]។ ឯកសារកម្មសិទ្ធិតាមន័យនៃច្បាប់ស្តីពីប្រតិបត្តិការដែលកិច្ចធានា មិនមែនជាឯកសិទ្ធិតាមន័យទូទៅនោះទេ។ ដូចបានឃើញនៅក្នុងនិយមន័យស្រាប់ ឯកសារកម្មសិទ្ធិនេះជាឯកសារកម្មសិទ្ធិលើទំនិញ ដែលអាចនៅក្នុងឃ្លាំង លើមធ្យោបាយដឹកជញ្ជូន ឬនៅកំពង់ផែ តែទំនិញទាំងអស់នេះ គឺជាចលនវត្ថុទាំងអស់។ ប្រភេទនៃឯកសារកម្មសិទ្ធិបែបនេះ ក៏អាចយកមកធ្វើជាទ្រព្យធានាដែរ ដោយហេតុថានៅក្នុងប្រតិបត្តិការជំនួញភាគច្រើនមានការដោះដូរគ្នាបែបនេះ ទើបច្បាប់នេះបានពង្រីកវិសាលភាពនៃទ្រព្យធានាទៅដល់ឯកសារទាំងនេះផងដែរ។ ឧទាហរណ៍ កសិករមួយរូបបានយកស្រូវទៅផ្ញើនៅនឹងឃ្លាំងមួយកន្លែងដោយម្ចាស់ឃ្លាំងបានចេញបង្កាន់ដៃមួយជូនគាត់។ ក្នុងករណីដែលកសិករមានបំណងខ្ចីប្រាក់ពីតតិយជននោះ គាត់អាចយកបង្កាន់ដៃនោះទៅធ្វើជាទ្រព្យធានាបានដោយបង្កើតប្រតិបត្តិការស្របតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

**ក.៤ លិខិតស្នាម**

លិខិតស្នាម ជាកំណត់ត្រាជាលាយលក្ខណ៍អក្សរ រួមទាំងរបស់ដែលផ្តល់ភស្តុតាងអំពីសិទ្ធិទទួលការទូទាត់ប្រាក់ ហើយមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ ឬកិច្ចសន្យាជួលដោយខ្លួនឯងនោះទេ ហើយវាជាប្រភេទដែលនៅក្នុងដំណើរការធម្មតានៃអាជីវកម្មត្រូវបានគេផ្ទេរដោយការប្រគល់ជាមួយនឹងបដិលេខចាំបាច់ណាមួយ ឬអនុប្បទានសិទ្ធិ។ របស់ដែលផ្តល់នូវភស្តុតាងទាំងនេះរួមមានមូលប្បទានប័ត្រផ្ទាល់ខ្លួន ប័ណ្ណដែលអាចទូទាត់បាន ប័ណ្ណភាគហ៊ុន(លិខិតបញ្ជាក់ថាត្រឹមត្រូវដែលបង្ហាញភស្តុតាងពីកម្មសិទ្ធិលើភាគហ៊ុនក្នុងក្រុមហ៊ុន[18]។

**ក.៥ រូបិយប័ណ្ណបរទេស**

វាអាចជាប្រតិបត្តិការដែលមិនងាយនឹងកើតឡើងទេ ដែលកូនបំណុលយកប្រាក់ទៅធានាប្រាក់ ប៉ុន្តែដើម្បីឱ្យច្បាប់នេះគ្រប់ជ្រុងជ្រោយ រូបិយប័ណ្ណក៏ត្រូវបានបញ្ចូលផងដែរ។ ការយករូបិយប័ណ្ណមកធ្វើជាទ្រព្យធានា វាអាចនឹងកើតមាននៅក្នុងប្រតិបត្តិដែលមានភាគីម្ខាងជាជនបរទេស ហើយគេយករូបិយប័ណ្ណបរទេសដែលគេមាន មកធ្វើជាទ្រព្យធានាសម្រាប់យករូបិយប័ណ្ណជាតិទៅប្រើប្រាស់។ វាអាចនឹងត្រូវបានគេចោទសួរថា ហេតុអ្វីក៏មិនធ្វើការប្តូររូបិយប័ណ្ណនោះតែម្តងទៅ

[17] ក្រសួងពាណិជ្ជកម្ម, *ឯកសារបណ្តុះបណ្តាល ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា*, ៣០

[18] ក្រសួងពាណិជ្ជកម្ម, *ឯកសារបណ្តុះបណ្តាល ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា*, ៣០

វាអាចមានលក្ខណៈងាយស្រួលជាង? តាមការបកស្រាយនៅក្នុងការពន្យល់ និងឧទាហរណ៍៖ ប្រតិបត្តិការដែលមានកិច្ចធានា វាគ្រាន់តែជាការបំពេញបន្ថែមឱ្យបានពេញលេញនូវលក្ខណៈសម្បត្តិជាទ្រព្យធានាដែលមានសណ្ឋានជាចលនវត្ថុតែប៉ុណ្ណោះ។ ប៉ុន្តែ បើយើងធ្វើការពិចារណាទៅ វាក៏មិនមែន មិនអាចកើតមាននោះដែរ ដូចជាការធ្វើប្រតិបត្តិការជំនួញអន្តរជាតិ ក្នុងពេលអតិផរណាជាអាទិ៍។

### ខ. ចលនវត្ថុអរូបី

#### ខ.១ គណនី (សិទ្ធិលើបំណុល)

គណនី ជាសិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានដាក់លក់ ឬបានជួល ឬថ្លៃសេវាកម្មដែលមិនមែនជាលិខិតស្នាម ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា[19]។ ជាឧទាហរណ៍ ភាគី ក បានលក់កូនជ្រូកទៅឱ្យភាគី ខ តែ ខ នៅមិនទាន់បានបង់ប្រាក់ទៅភាគី ក នៅឡើយទេ។ ប្រាក់ដែល ខ មិនទាន់បានសងនោះជា គណនី ដែលអាចឱ្យ ក យកទៅធានាកាតព្វកិច្ចបាន។

#### ខ.២ សិទ្ធិ

ក្រៅពីទ្រព្យដែលបានរៀបរាប់ខាងលើហើយ សិទ្ធិរបស់កូនបំណុលក៏អាចក្លាយជាទ្រព្យធានាដែរ។ សិទ្ធិទាំងនោះមានដូចជាសិទ្ធិប្រត្យក្ស ឬសិទ្ធិផ្សេងទៀតដែលគាត់មាន។ ឧបមាថា ក ជាពាណិជ្ជករដែលទទួលបានសិទ្ធិក្នុងការរុករករ៉ែក្នុងដីពីរដ្ឋ។ ក អាចយកសិទ្ធិក្នុងការរុករករ៉ែនោះទៅធ្វើជាទ្រព្យធានា ដើម្បីធានាកាតព្វកិច្ចបាន ព្រោះវាជាសិទ្ធិដែលគាត់មានជាក់ស្តែង។

### ២. ប្រតិបត្តិការផ្សេងៗ

ក្រៅពីទ្រព្យជាចលនវត្ថុហើយ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានលក្ខណៈពិសេសមួយទៀតដែលខុសពីច្បាប់ដទៃ គឺច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើប្រតិបត្តិការមួយចំនួនដែលជាប្រភេទនៃប្រតិបត្តិការទំនើបដូចជា ប្រតិបត្តិការដែលមានអានុភាពលើការបញ្ចាំចលនវត្ថុ ការផ្ទេរកម្មសិទ្ធិ បញ្ញើទុកលក់ និងការអនុប្បទានសិទ្ធិ ការជួលទំនិញរយៈពេលលើសពីមួយឆ្នាំ និងការលក់គណនី និងកិច្ចសន្យាលក់ដែលមានកិច្ចធានា។ ប្រតិបត្តិការដែលមានរៀបរាប់ខាងលើនេះ ជាប្រភេទប្រតិបត្តិការដែលមានសញ្ញាណមួយចំនួនថ្មីមិនធ្លាប់មាននៅកម្ពុជា តែប្រតិបត្តិការមួយចំនួនអាចមានលក្ខណៈស្រដៀងទៅនឹងសញ្ញាណនៃក្រមរដ្ឋប្បវេណីកម្ពុជា។

---

[19] មាត្រា ៣ ចំណុច១១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

### ៣. ចលនវត្ថុ និងប្រតិបត្តិការដែលមិនអាចក្លាយជាទ្រព្យធានាបាន

ថ្វីត្បិតតែច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មានអានុភាពលើចលនវត្ថុ និងប្រតិបត្តិការជាច្រើនក៏ដោយ ក៏មានចលនវត្ថុ និងប្រតិបត្តិការមួយចំនួនមិនអាចក្លាយជាកម្មវត្ថុនៃប្រតិបត្តិការដែលមានកិច្ចធានាផងដែរ។ ចលនវត្ថុ និងប្រតិបត្តិការទាំងនោះរួមមានការផ្ទេរកម្មសិទ្ធិទាមទារប្រាក់បៀរវត្សរបស់និយោជិត ការលក់គណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានាដែលជាផ្នែកនៃការលក់អាជីវកម្មរួមទាំងគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា ការធ្វើអនុប្បទានគណនីកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាមដែលសម្រាប់តែគោលបំណងប្រមូលប្រាក់ដែលជំពាក់ ការផ្ទេរសិទ្ធិទទួលប្រាក់តាមកិច្ចសន្យាទៅអនុប្បទានិកដែលមានកាតព្វកិច្ចអនុវត្តកិច្ចសន្យា និងការប្រាក់លើប្រាក់បញ្ញើ គណនីមូលទានប័ត្រ គណនីសញ្ជ័យ សៀវភៅធនាគារឬគណនីសាច់ប្រាក់ដទៃទៀត លើកលែងផលនៃទ្រព្យធានា[20]។

## ផ្នែកទី ២ អានុភាពនៃប្រតិបត្តិការដែលមានកិច្ចធានា

### កថាខណ្ឌទី១ វិធីក្នុងការធ្វើសុក្រឹតកម្ម

សុក្រឹតកម្ម គឺជាការពង្រីកសិទ្ធិនៃភាគីដែលមានកិច្ចធានា ឱ្យដល់កំរិតអតិបរមាទល់នឹងតតិយជន។ សុក្រឹតកម្មនេះត្រូវបានចែងនៅក្នុងជំពូកទី២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ បើយើងធ្វើការបកស្រាយឱ្យងាយស្រួលយល់ នោះពាក្យសុក្រឹតកម្មនេះ សំដៅទៅលើលក្ខខណ្ឌតតាំងនេះឯង ដែលអាចជួយឱ្យភាគីដែលជាម្ចាស់បំណុលអាចធ្វើការតតាំងជាមួយតតិយជនបានប្រសិនបើមានវិវាទស្តីពីកម្មវត្ថុនៃប្រតិបត្តិការដែលកំពុងប្រព្រឹត្តទៅនោះ។

នៅពេលដែលសិទ្ធិប្រាតិភោគបានភ្ជាប់ទៅនឹងទ្រព្យធានា នោះគេអាចធ្វើឱ្យសិទ្ធិនោះ មានសុក្រឹតកម្មដោយមធ្យោបាយបីយ៉ាង គឺ សុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹង សុក្រឹតកម្មដោយការកាន់កាប់ និង សុក្រឹតកម្មដោយស្វ័យប្រវត្តិនៅពេលភ្ជាប់សិទ្ធិប្រាតិភោគដោយប្រភេទនីមួយៗខុសគ្នាអាស្រ័យលើកម្មវត្ថុនៃទ្រព្យធានា។

[20] មាត្រា ២ កថាខណ្ឌ៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

### ១. សុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹង

ការតម្កល់លិខិតជូនដំណឹងនេះ អាចធ្វើទៅបាននៅការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលមានមូលដ្ឋាននៅក្នុងក្រសួងពាណិជ្ជកម្ម ដោយយោងតាមមាត្រា ២៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។

#### ក. ការិយាល័យតម្កល់លិខិតជូនដំណឹង

ការិយាល័យនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម។ ជាទូទៅកន្លែងតែមួយដែល អាចគួរតែទៅនោះគឺតាមរយៈគេហទំព័រផ្លូវការ ឬការចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម[21] ដែលបានបង្កើតឡើងដោយក្រសួងពាណិជ្ជកម្មផ្ទាល់តែម្តង ដោយហេតុថាការិយាល័យតម្កល់ដែលស្ថិតនៅក្នុងក្រសួងគឺជាការិយាល័យរដ្ឋបាល ដែលអាចឱ្យយើងធ្វើការសួរសំនួរដែលទាក់ទងទៅនឹងប្រតិបត្តិការតម្កល់តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះតែប៉ុណ្ណោះ។

ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការិយាល័យតម្កល់លិខិតជូនដំណឹងមានតួនាទី ក្នុងការទទួលតម្កល់លិខិតដូចជា៖ លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹតកម្ម ប្រាតិភោគលើទ្រព្យធានាដែលចែងក្នុងច្បាប់នេះ លើកលែងតែទ្រព្យធានាដែលកំណត់ក្នុងមាត្រា ៥៤ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា និងលិខិតជូនដំណឹងពីសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក។

ក្នុងការបង្កើតការិយាល័យតម្កល់លិខិតជូនដំណឹង នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមានគោលបំណងសាមញ្ញពីរគឺ រំលឹកដល់ម្ចាស់បំណុលពីសិទ្ធិទាមទារពីមុនចំពោះចលនទ្រព្យ (ទ្រព្យរូបី និង ទ្រព្យអរូបី) និងបង្កើតកាលបរិច្ឆេទអាទិភាព សម្រាប់ដោះស្រាយបណ្តឹងទាមទារប្រជែងគ្នាលើទ្រព្យតែមួយ។

លិខិតបទដ្ឋានទាំងអស់ជាការទទួលខុសត្រូវចេញឱ្យ ដោយក្រសួងពាណិជ្ជកម្ម ដែលស្របទៅតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដែលមានលិខិតដូចតទៅ៖

- ថ្លែងការណ៍បញ្ជាក់ចំពោះកំណត់ត្រាដែលបានតម្កល់នីមួយៗ ដូចជា ប្រាប់ពីអត្តសញ្ញាណរបស់អ្នកតម្កល់, រាយការណ៍នូវទិន្នន័យទាំងអស់ដែលបានផ្តល់ឱ្យទៅការិយាល័យតម្កល់, ផ្តល់នូវលេខតម្កល់ពិសេសសម្រាប់លិខិតជូនដំណឹងដំបូង ហើយករណីមានការតម្កល់បន្តបន្ទាប់ និងចុះនូវពេលវេលា ព្រមទាំងការបរិច្ឆេទតម្កល់។
- របាយការណ៍គណនីលើថ្លៃដែលបានជំពាក់។
- វិក័យប័ត្រលើថ្លៃដែលបានបង់រួច។

[21] គេហទំព័រការិយាល័យតម្កល់លិខិតជូនដំណឹង www.setfo.gov.kh

- របាយការណ៍ស្រាវជ្រាវលើពាក្យសុំដែលផ្អែកទៅតាមលក្ខខណ្ឌច្បាប់ ដែលរួមមានព័ត៌មាននៅលើលិខិតជូនដំណឹងទាំងអស់ រួមទាំងការកែប្រែ ការបន្ត និងការបញ្ចប់។
- លិខិតបដិសេធការណ៍ ក្នុងករណីក្រសួងបដិសេធមិនធ្វើការតម្កល់ដល់អ្នកស្នើសុំដែលមិនបំពេញលក្ខខណ្ឌនៃពាក្យសុំ។

ដោយឡែកការិយាល័យតម្កល់លិខិតជូនដំណឹងបានផ្តល់នូវគុណសម្បត្តិ និងសម្របសម្រួលលក្ខខណ្ឌច្រើនយ៉ាងចំពោះវិស័យពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជាយើងដូចជា ផ្តល់ភាពងាយស្រួល ដោយគ្រាន់តែបំពេញនូវព័ត៌មានតិចតួចបំផុត នៅក្នុងការដាក់តម្កល់លិខិតជូនដំណឹងសាមញ្ញមួយ, មានតម្លាភាព ដោយផ្តល់ឱ្យម្ចាស់បំណុលនូវភាពច្បាស់លាស់ក្នុងការធ្វើប្រតិបត្តិមួយដែលគ្មានហានិភ័យនៅពេលអនាគត និងការចំណាយតិច ដែលផ្តល់ប្រយោជន៍ដល់ពាណិជ្ជករក្នុងការទទួលបាននូវការសន្យាខ្ពស់ផ្នែកហិរញ្ញវត្ថុជាងប្រតិបត្តិការនៅក្នុងច្បាប់ផ្សេងៗ។

### ខ. លិខិតជូនដំណឹង

មាត្រា ៣៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានចែងថា ត្រូវចាត់ទុកថាលិខិតជូនដំណឹងដំបូងមានលក្ខណៈគ្រប់គ្រាន់ត្រូវមានព័ត៌មានដូចជា៖

- អត្តសញ្ញាណ និងអាសយដ្ឋានរបស់កូនបំណុល
- អត្តសញ្ញាណ និងអាសយដ្ឋានរបស់ម្ចាស់បំណុល និង អត្តសញ្ញាណរបស់ភ្នាក់ងាររបស់ម្ចាស់បំណុល។
- ពណ៌នាពីទ្រព្យធានា ដោយប្រើអក្សរខ្មែរ និង អក្សរឡាតាំង ព្រមទាំងលេខអារ៉ាប់ ហើយអធិប្បាយពីអចលនវត្ថុដែលពាក់ព័ន្ធ ប្រសិនបើលិខិតមចែងពីវត្ថុដូចមានចែងក្នុងមាត្រា ៥៤ នៃច្បាប់នេះ។
- មានកំណត់ត្រាបញ្ជាក់ពីការអនុញ្ញាតឯកភាពពីកូនបំណុលក្នុងការតម្កល់នេះ (មិនបាច់ចែងក្នុងលិខិតជូនដំណឹងទេ)។
- ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាតិភោគដោយកូនបំណុល
- លិខិតនេះអាចត្រូវបានតម្កល់មុនកិច្ចព្រមព្រៀង ឬមុនសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា។
- លិខិតជូនដំណឹងមិនត្រូវមានការភាន់ច្រឡំខ្លាំង ដូចជាមិនបានចែងពីឈ្មោះ ម្ចាស់បំណុល ឬកូនបំណុលជាដើម។

មាត្រា ៣៩នៃច្បាប់ខាងលើនេះ បានចែងថា ត្រូវចាត់ទុកថាគ្រប់គ្រាន់ពី ឈ្មោះ និង នាមករណ៍ របស់កូនបំណុល ជាអក្សរខ្មែរ និងអក្សរឡាតាំង និងលេខអារ៉ាប់ កាលណា៖

- ត្រូវមានចុះអត្តលេខប្រាំបួនខ្ទង់ដែលមានក្នុងអត្តសញ្ញាណប័ណ្ណ របស់កូនបំណុលជារូបវន្ត បុគ្គលដែលមានឈ្មោះនៅក្នុងកំណត់ត្រារបស់ក្រសួងមហាផ្ទៃ។
- ត្រូវចុះឈ្មោះរបស់សាមីខ្លួន និង ឈ្មោះប្រទេស តាមលិខិតឆ្លងដែនប្រសិនបើកូនបំណុល មិនមែនជាជនជាតិខ្មែរ។
- មាននាមករណ៍របស់កូនបំណុលដែលជានីតិបុគ្គល ដែលបានចុះបញ្ជីពាណិជ្ជកម្មស្រប ច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។
- នាមករណ៍របស់នីតិបុគ្គលបរទេសដែលបានចុះបញ្ជីពាណិជ្ជកម្មត្រឹមត្រូវ នៅក្នុងព្រះ រាជាណាចក្រកម្ពុជា។
- នាមករណ៍របស់នីតិបុគ្គលបរទេសដោយយោងបញ្ជីពាណិជ្ជកម្មរបស់ប្រទេសកំណើត នៃ នីតិបុគ្គលនោះ ប្រសិនបើនីតិបុគ្គលនោះមិនបានចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រ កម្ពុជា។

ត្រូវចាត់ទុកថាមិនគ្រប់គ្រាន់ប្រសិនបើ លិខិតជូនដំណឹងនោះចែងតែពី ពាណិជ្ជនាម ឬ ឈ្មោះផ្សេងទៀត ក្រៅពីការរៀបរាប់ខាងលើរបស់កូនបំណុល។ ឈ្មោះរបស់ម្ចាស់បំណុល និងកូន បំណុលអាចចែងលើសពីមួយបាន និង មិនប៉ះពាល់ដល់លិខិតនោះទេ ប្រសិនបើមិនបានបញ្ជាក់ថា បុគ្គលជាតំណាងរបស់ម្ចាស់បំណុល។

### គ. ការសុំបន្តសុពលភាពលិខិតជូនដំណឹង

លិខិតនេះត្រូវមានសុពលភាពរយៈពេល ប្រាំឆ្នាំគិតចាប់ពីការបរិច្ឆេទនៃការតម្កល់ លើកលែង តែភាគី បានតម្កល់លិខិតសុំបន្តសុពលភាពក្នុងរយៈ ពេលប្រាំមួយខែមុនផុតកំណត់រយៈពេលប្រាំ ឆ្នាំនៃសុពលភាព។ ក្រោយតម្កល់លិខិតសុំបន្តសុពលភាពហើយ សុក្រឹតកម្មត្រូវមានសុពលភាព ចំពោះម្ចាស់បំណុលនៃកិច្ចធានាបានរយៈប្រាំឆ្នាំទៀត ចាប់ពីថ្ងៃដែលលិខិតជូនដំណឹងដំបូងអស់ សុពលភាព។ លក្ខខណ្ឌនៃការធ្វើវិសោធកម្មនេះមានចែងនៅក្នុងមាត្រា៣៧ កថាខណ្ឌទីទី១ដែល មានដូចជា៖

- បញ្ជាក់ពីលេខតម្កល់របស់លិខិតជូនដំណឹងដំបូង។
- បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យមាន លិខិតសុំបន្ត។

- បញ្ជាក់ថាលិខិតជូនដំណឹងត្រូវបន្តសុពលភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានា ដែលអនុញ្ញាតឱ្យតម្កល់។

### ឃ. ការបញ្ចប់សុពលភាពលិខិតជូនដំណឹង

លិខិតជូនដំណឹងក៏អាចត្រូវបានបញ្ចប់សុពលភាព ដោយការតម្កល់លិខិតសុំបញ្ចប់ផងដែរ។ ក្នុងលិខិតនេះត្រូវបញ្ជាក់ពី លេខលិខិតជូនដំណឹងដំបូង ម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យបញ្ចប់នេះ និងភាពគ្មានប្រយោជន៍ដល់ម្ចាស់បំណុលនៃលិខិតជូនដំណឹងដំបូង។ លិខិតនេះអាចត្រូវតម្កល់ដោយម្ចាស់បំណុលបានក្នុងរយៈពេល ២០ថ្ងៃបន្ទាប់ពីមានការទាមទារជាលាយលក្ខណ៍អក្សរពីកូនបំណុល ដោយមូលហេតុថា៖

- គ្មានជំពាក់កាតព្វកិច្ចប្រាតិភោគ និងគ្មានការសន្យាផ្តល់បុរេប្រទាន ការបង្កើតកាតព្វកិច្ច ឬការផ្តល់តាមវិធីក្រៅពីនេះទេ។
- លិខិតដំបូងត្រូវបានតម្កល់ដោយគ្មានការយល់ព្រមដោយកូនបំណុល។
- កាតព្វកិច្ចត្រូវបានរលត់សព្វគ្រប់ហើយ។

### ង. ការវិសោធនកម្ម

ក្រៅពីករណីសុំបន្ត និងបញ្ចប់សុពលភាពហើយ លិខិតជូនដំណឹងក៏អាចសុំធ្វើវិសោធនកម្មបានផងដែរ។ ការសុំកែប្រែនេះអាចធ្វើច្រើនដងបានដោយមូលហេតុផ្សេងៗបានដូចជា ការបន្ថែម ឬបន្ថយទ្រព្យធានាជាដើម។ លក្ខខណ្ឌនៃការធ្វើវិសោធកម្មនេះមាន ចែងនៅក្នុងមាត្រា៣៧ កថាខណ្ឌទី១ ដែលមានដូចជា៖

- បញ្ជាក់ពីលេខតម្កល់របស់លិខិតជូនដំណឹងដំបូង។
- បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យមានវិសោធនកម្មនេះ។
- បញ្ជាក់ថានេះជាវិសោធនកម្មលើលិខិតជូនដំណឹង។
- ចែងពីព័ត៌មានចាំបាច់ក្នុងជូនដំណឹងដំបូង។

### ច. ប្រតិបត្តិការដែលទាមទារឱ្យមានការតម្កល់លិខិតជូនដំណឹង

ការតម្កល់លិខិតជូនដំណឹងនេះ មិនមែនសុទ្ធតែមានប្រយោជន៍យកទៅអនុវត្តគ្រប់ប្រតិបត្តិការនោះទេ តែកម្មវត្ថុនៃកិច្ចធានាខ្លះអាចធ្វើឱ្យមានសុក្រឹតភាពបានតាមរយៈមធ្យោបាយពីរផ្សេង

ទៀតដូចជា ការកាន់កាប់ និងសុក្រឹត្យភាពដោយស្វ័យប្រវត្តិ។ ក្នុងនោះប្រតិបត្តិការមួយចំនួនដែលស្ថិតនៅក្រោមការតម្កល់លិខិតជូនដំណឹងនេះមានដូចជា៖

- សិទ្ធិប្រាតិភោគលើទំនិញ លិខិតស្នាម ឯកសារ ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា។
- សិទ្ធិប្រាតិភោគលើយានយន្តដែលមានលេខស៊េរី។

### ២. សុក្រឹតកម្មដោយការកាន់កាប់

ដោយយោងតាមមាត្រា២២៧ នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ ២០០៧ បានឱ្យនិយមន័យទៅលើការកាន់កាប់ថា សំដៅទៅលើការក្តាប់ទុកវត្ថុ ឬការគ្រប់គ្រងវត្ថុ តាមការជាក់ស្តែង ទោះដោយចំពោះក្តី ឬដោយប្រយោលក្តី។ នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាវិញ ការកាន់កាប់ទ្រព្យធានាដោយម្ចាស់បំណុលដែលមានកិច្ចធានា គឺជាមធ្យោបាយមួយទៀតនៃការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគ។ តាមន័យនេះយើងអាចនិយាយបានថាវាមានភាពស្រដៀងគ្នាទៅនឹង បញ្ញត្តិស្តីពីសិទ្ធិប្រាតិភោគប្រត្យក្ស (ការបញ្ចាំចលនវត្ថុ) ដែលមាននៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។ ដោយឡែក មធ្យោបាយកាន់កាប់នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានេះមិនមែនអនុវត្តបានលើគ្រប់កម្មវត្ថុនៃប្រតិបត្តិការនោះទេ តែអាចត្រូវអនុវត្តទៅលើកម្មវត្ថុនៃធានាមួយចំនួនដូចជា ទំនិញ លិខិតស្នាម ឯកសារ ប័ណ្ណភាគហ៊ុន ឬកិច្ចសន្យាលក់ដែលមានកិច្ចធានាជាដើម ដែលមានភាពស្រដៀងទៅនឹងកម្មវត្ថុនៃការធ្វើសុក្រឹតកម្មតាមការតម្កល់លិខិតជូនដំណឹងដែរ។

### ក. ប្រភេទនៃការកាន់កាប់

ដោយហេតុថានៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មិនមានបញ្ញត្តិណាចែងជាក់លាក់ពីការកាន់កាប់នោះទេ ដូច្នេះដោយយោងតាមមាត្រា៧២ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលបានចែងពីការសម្របសម្រួលនៃច្បាប់ទាំងពីរនេះ យើងអាចយកបញ្ញត្តិស្តីពីការកាន់កាប់នៅក្នុងច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី) មកអនុវត្តក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបាន។ ដោយយោងតាមមាត្រា ២២៨ នៃក្រមរដ្ឋប្បវេណី បានធ្វើការបែងចែកការកាន់កាប់ជាពីរធំៗ គឺ ការកាន់កាប់ដោយចំពោះ និងការកាន់កាប់ដោយប្រយោល។ ការកាន់កាប់ដោយចំពោះ គឺជាការក្តាប់ទុកវត្ថុដោយផ្ទាល់ ដោយឡែកការកាន់កាប់ដោយប្រយោលគឺជាការក្តាប់ទុកវត្ថុដោយតាមរយៈអ្នកដទៃ។ ក្នុងករណីការកាន់កាប់ដោយប្រយោល អ្នកកាន់កាប់មានពីរគឺ អ្នកកាន់កាប់ដោយផ្ទាល់ និងអ្នកកាន់កាប់ដោយប្រយោល។

**ខ. ការផ្ទេរការកាន់កាប់**

ការផ្ទេរការកាន់កាប់មាន ៤ ប្រភេទ ដូចជា ការផ្ទេរដោយជាក់ស្តែង ការផ្ទេរដោយការប្តូរលក្ខណៈនៃការកាន់កាប់ ការផ្ទេរដោយសង្ខេប និងការផ្ទេរដោយបញ្ជា។

- ការផ្ទេរការកាន់កាប់ដោយជាក់ស្តែង គឺជាការប្រគល់វត្ថុដោយកាន់កាប់ដោយផ្ទាល់។
- ការផ្ទេរការកាន់កាប់ដោយការប្តូរលក្ខណៈនៃការកាន់កាប់ គឺជាការផ្ទាល់ដោយគ្រាន់តែមានការព្រមព្រៀងរវាងគូភាគីតែប៉ុណ្ណោះ ដោយមិនមានការប្រគល់វត្ថុជាក់ស្តែងនោះទេ ដែលនាំឱ្យអ្នកដែលទទួលបានការកាន់កាប់ពីការផ្ទេរការកាន់កាប់នោះ ក្លាយជាអ្នកដែលធ្វើការកាន់កាប់ដោយប្រយោល។
- ការផ្ទេរការកាន់កាប់ដោយការប្រគល់ដោយសង្ខេប គឺជាការដែលជាការជាក់ស្តែងអ្នកដែលនឹងទទួលបាននូវអនុប្បទាននូវការកាន់កាប់នោះ បានធ្វើការក្តាប់ទុកវត្ថុនោះដោយចំពោះតាមការជាក់ស្តែងមុនជាស្រេចរួចមកហើយ ដូច្នេះគ្រាន់តែមានការព្រមព្រៀងរវាងគូរភាគីជាការស្រេច។
- ការផ្ទេរការកាន់កាប់ដោយបញ្ជា គឺជាការផ្ទេរដែលវត្ថុស្ថិតនៅលើដៃតតិយជន ទៅឱ្យតតិយជនម្នាក់ទៀយដោយអ្នកដែលកាន់កាប់ដោយប្រយោល។ ករណីនេះការផ្ទេរមានសុពលភាពលុះត្រាតែមានការព្រមព្រៀងជាមួយអនុប្បទានិក និងធ្វើការជូនដំណឹងទៅឱ្យអ្នកកាន់កាប់ដោយចំពោះជាការស្រេច។

ជាក់ស្តែងការផ្ទេរការកាន់កាប់ខាងលើនេះ មានតែការផ្ទេរការកាន់កាប់តែបីប្រភេទប៉ុណ្ណោះ ដែលអាចយកមកអនុវត្តនៅក្នុងការធ្វើសុក្រឹតកម្មបាន គឺការផ្ទេរការកាន់កាប់ដោយផ្ទាល់ ការផ្ទេរការកាន់កាប់ដោយសង្ខេប និងការផ្ទេរការកាន់កាប់ដោយការបញ្ជា ដោយហេតុថាច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា នៅក្នុងករណីនៃការធ្វើសុក្រឹតកម្មដោយកាន់កាប់នេះ ជាលក្ខណៈមួយដែលដូចទៅនឹង បទប្បញ្ញត្តិស្តីពីការបញ្ចាំចលនវត្ថុ[22]ដែលទាមទារឱ្យមានការកាន់កាប់ទ្រព្យធានាដោយម្ចាស់បំណុលទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ។ ដូច្នេះយើងអាចទាញបានថាបញ្ញត្តិដែលមានចែងនៅការបញ្ចាំចលនវត្ថុនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ អាចត្រូវបានយកមកសម្របសម្រួលត្រង់ចំណុចស្តីពីការកាន់កាប់នេះបាន ក្នុងនោះដោយយោងតាមមាត្រា៨១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងហាមឃាត់មិនឱ្យកូនបំណុលធ្វើការកាន់កាប់ដោយផ្ទាល់នៃវត្ថុធានា

[22] ក្រសួងពាណិជ្ជកម្ម, *ឯកសារបណ្តុះបណ្តាលស្តីពីប្រតិបត្តិការដែលមានកិច្ចធានា*, ៨២

នោះទេ ដែលជាហេតុក្នុងធ្វើឱ្យការផ្ទេរការកាន់កាប់ដោយប្តូរលក្ខណៈនៃការកាន់កាប់មិនអាចយកមកអនុវត្តបាននៅក្នុងប្រតិបត្តិការនេះ។

**គ. ការរលត់នូវការកាន់កាប់**

ដោយយោងតាមក្រមរដ្ឋប្បវេណីនៃឆ្នាំ ២០០៧ បានបញ្ញត្តនៅក្នុងមាត្រា២៣០ ថាការកាន់កាប់ត្រូវបានរលត់ នៅពេលដែលអ្នកកាន់កាប់ត្រូវបានដកហូតនូវការក្តាប់ទុកវត្ថុកាន់កាប់។ ប៉ុន្តែបញ្ញត្តិនេះ មិនយកមកអនុវត្តឡើយក្នុងករណីអ្នកនោះទទួលបាននូវការកាន់កាប់មកវិញក្នុងអំឡុងពេល ១ឆ្នាំ។ ដូច្នេះប្រសិនបើភាគី ដែលជាម្ចាស់បំណុល បានបាត់បង់ការកាន់កាប់តាមរយៈបញ្ញត្តិខាងលើ នោះសុក្រឹតភាពនៃការកាន់កាប់ក៏បាត់បង់ដែរ ដោយយោងតាមមាត្រា១០ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា កថាខណ្ឌទីទី៥ បានបញ្ញត្តិថា សិទ្ធិប្រាតិភោគបន្តមានសុក្រឹតភាពដោយការកាន់កាប់ គិតចាប់ពីពេលកាន់កាប់ហើយសុក្រឹតភាពនេះ ត្រូវបន្តអនុភាពតែក្នុងពេលមានការកាន់កាប់ប៉ុណ្ណោះ។ ដូច្នេះប្រសិនបើក្នុងកំឡុងពេលនោះភាគីម្ចាស់បំណុលបានបាត់បង់នូវការកាន់កាប់របស់ខ្លួនដោយមូលហេតុផ្សេងៗ នោះសុក្រឹតកម្មដោយការកាន់កាប់មិនអាចយកទៅធ្វើជាលក្ខខណ្ឌតតាំងជាមួយតតិយជនឡើយ។

**ឃ. ប្រតិបត្តិការដែលស្ថិតនៅក្រោមសុក្រឹតកម្មដោយការកាន់កាប់**

ដោយយោងតាមមាត្រា១០ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានអនុញ្ញាតឱ្យប្រតិបត្តិការមួយចំនួនអាចធ្វើសុក្រឹតកម្មតាមរបៀបនេះ ដូចជា៖

- សិទ្ធិប្រាតិភោគលើទំនិញ លិខិតស្នាម ឯកសារ ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា
- សិទ្ធិប្រាតិភោគលើរូបិយវត្ថុ
- សុក្រឹតកម្មលើឯកសារកម្មសិទ្ធិ

**៣. ការធ្វើសុក្រឹតកម្មដោយស្វ័យប្រវត្តិ**

ក្នុងករណីដែលសិទ្ធិប្រាតិភោគមួយចំនួនត្រូវបានភ្ជាប់ទៅនឹងវត្ថុធានា នោះសុក្រឹតភាពនឹងកើតមានឡើងដោយឯកឯងទៅលើសិទ្ធិប្រាតិភោគនោះ ដោយមិនចាំបាច់មានសកម្មភាពអ្វីពីគូភាគីឡើយ នេះគេហៅថា សុក្រឹតកម្មដោយស្វ័យប្រវត្តិ។

សិទ្ធិប្រាតិភោគលើទំនិញប្រើប្រាស់ ត្រូវបានគេធ្វើសុក្រឹតកម្មជាស្វ័យប្រវត្តិនៅពេលដែលវាភ្ជាប់ទៅនឹងទំនិញប្រើប្រាស់ ដោយហេតុថា ទំនិញប្រើប្រាស់តែងតែមានតម្លៃទាប ដូច្នេះដើម្បីកាត់

បន្ថយម្ចាស់បំណុល និងការិយាល័យតម្កល់ ចៀសវាងស្ទះការងារ និងចំណាយច្រើនលើថ្លៃចុះបញ្ជីលើទំនិញទាំងនោះ។ ដោយឡែក សុក្រឹតកម្មលើសិទ្ធិប្រាតិភោគលើផលនៃទ្រព្យ ក៏ត្រូវទទួលបានសុក្រឹតភាពដោយស្វ័យប្រវត្តិដែលនៅពេលសិទ្ធិនោះត្រូវបានភ្ជាប់។ ផលនៃទ្រព្យនេះគឺសំដៅទៅលើប្រាក់ដែលជាសាច់ប្រាក់ទទួលបានពីការលក់ ការប្តូរ ឬការជម្រះចោលនៃទ្រព្យធានានោះ មិនមែនសំដៅទៅលើប្រាក់ធម្មតាដែលកូនបំណុលយកមកដាក់ធានា ដែលតម្រូវឱ្យមានការកាន់កាប់នោះទេ។

**កថាខណ្ឌទី ២ អាទិភាពនៃសុក្រឹតកម្ម**

អាទិភាព គឺសំដៅទៅលើភាពដែលមានសិទ្ធិមានប្រៀបជាងសិទ្ធិមួយ ឬច្រើនផ្សេងទៀតក្នុងករណីដែលមានការប្រជែងគ្នា។ នៅក្នុងច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា បានបញ្ញត្តិទុកជាមុនរួចជាស្រេចសម្រាប់ការដោះលើស្រាយបញ្ហានេះ ដែលអាចកើតមានឡើងកាលណាដែលកម្មវត្ថុដែលជាទ្រព្យធានា បានភ្ជាប់ទៅនឹងប្រតិបត្តិការពីរ ឬច្រើនក្នុងពេលតែមួយ។ វាអាចជាភាពស្មុគស្មាញមួយក្នុងការដោះស្រាយលើបញ្ហានេះក្នុងសភាពជាក់ស្តែង ដែលទាមទារឱ្យភាគីធ្វើការបង្ហាញតាមអ្វីដែលច្បាប់នេះទាមទារ។ ដោយយោងតាមមាត្រា១២ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានចែងថា ក្នុងករណីមានសិទ្ធិប្រាតិភោគច្រើន លើទ្រព្យធានាតែមួយ ត្រូវមានអាទិភាពដោយយោងទៅតាមពេលវេលានៃការតម្កល់លិខិតជូនដំណឹង ឬការធ្វើសុក្រឹតភាព លើកលែងតែមានករណីខ្លះច្បាប់នេះបានចែងផ្សេង ប៉ុន្តែក្នុងករណីដែលសិទ្ធិប្រាតិភោគទាំងអស់មិនបានធ្វើការតម្កល់លិខិតជូនដំណឹង ឬធ្វើសុក្រឹតភាពនោះទេ អាទិភាពត្រូវអនុលោមទៅតាមពេលដែលសិទ្ធិប្រាតិភោគណាបានភ្ជាប់ទៅនឹងទ្រព្យធានាមុនគេ។ អាទិភាពដែលមានចែងនៅក្នុងច្បាប់នេះ គឺមានច្រើនខុសៗគ្នាដែលអាស្រ័យទៅលើប្រតិបត្តិការនីមួយៗរបស់វា។

**១. អាទិភាពរបស់គាហកនៃសិទ្ធិឃាត់ទុក**

ដោយយោងទៅតាមមាត្រា១៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានេះ បានចែងថា សិទ្ធិប្រាតិភោគមានអាទិភាពលើសិទ្ធិរបស់គាហកនៃសិទ្ធិឃាតទុក លើកលែងតែគាហកនៃសិទ្ធិឃាតទុកបានតម្កល់លិខិតជូនដំណឹងមុនពេលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ឬមុនពេលម្ចាស់តម្កល់លិខិតជូនដំណឹងពីទ្រព្យធានា។ នៅក្នុងឯកសារស្តីពីប្រតិបត្តិការដែលមានកិច្ចធានារបស់ក្រសួងពាណិជ្ជកម្មបានកំណត់ពីគាហកនៃសិទ្ធិឃាត់ទុកដូចជា អាជ្ញាធរពន្ធដារ អាជ្ញាសាលា ឬអភិបាលបណ្តោះអាសន្ននៃសិទ្ធិឃាត់ទុកដែលមានសិទ្ធិរឹបអូសទ្រព្យធានានោះ។ តាមវិធានខាង

លើគាហកនៃសិទ្ធិឃាតទុកមានអាទិភាពប្រសិនបើមានការតម្កល់មុនគេ។ ច្បាប់តម្រូវឱ្យគាហកនៃសិទ្ធិឃាតទុកតម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹតកម្មតាមរបៀបតែមួយដូចគ្នាទៅនឹងម្ចាស់បំណុលដែលមានកិច្ចធានា។

### ២. អ្នកទិញទ្រព្យធានា

បើទោះបីជាទ្រព្យធានាត្រូវបានលក់ ឬក៏ដោះដូរយ៉ាងណាក៏ដោយ ប៉ុន្តែសិទ្ធិប្រាតិភោគដែលមាននៅលើទ្រព្យនោះនឹងទៅជាមួយទ្រព្យនោះ ដែលធ្វើឱ្យអ្នកទិញយកទ្រព្យធានានោះត្រូវជាប់ជាមួយនឹងសិទ្ធិប្រាតិភោគផងលើកលែងតែច្បាប់បានចែងផ្សេងពីនេះ។ ប៉ុន្តែបើក្នុងករណី អ្នកទិញមិនបានដឹងថាមានប្រតិបត្តិការដែលមានកិច្ចធានានៅលើទ្រព្យនោះ ហើយសិទ្ធិប្រាតិភោគនោះមិនបានធ្វើសុក្រឹតកម្មទេនោះ អ្នកទិញនឹងទទួលបានទ្រព្យនោះដោយមិនជាប់សិទ្ធិប្រាតិភោគ។ ប៉ុន្តែករណីខាងលើមិនអាចយកមកអនុវត្តបានទេ ប្រសិនបើអ្នកទិញទំនិញក្នុងអាជីវកម្មលក់ទំនិញធម្មតា ដែលសុក្រឹតកម្មនឹងមានលើទ្រព្យធានាដោយស្វ័យប្រវត្តិដោយហេតុថាទ្រព្យធានានោះមានតម្លៃថោក ចៀសវាងការចំណាយមិនចាំបាច់លើថ្លៃនៃការតម្កល់ និងស្មុះការងារនៅការិយាល័យតម្កល់។ ដូច្នេះមានន័យថា ទោះបីជាតតិយជនបានទិញទ្រព្យធានានោះដោយមិនដឹងថាមានសិទ្ធិប្រាតិភោគក៏ដោយ ក៏ម្ចាស់បំណុលនៃកិច្ចធានា នៅតែអាទិភាពលើសិទ្ធិរបស់អ្នកទិញទ្រព្យធានាដែលដោយហេតុសុក្រឹតកម្មដោយស្វ័យប្រវត្តិ។

### ៣. កិច្ចសន្យាជួលទ្រព្យធានា

មិនខុសគ្នាពីអាទិភាពរបស់អ្នកទិញនោះទេ ប្រសិនបើអ្នកជួលទ្រព្យធានាបានទទួលសិទ្ធិលើការជួលដោយមិនដឹងថាមានសិទ្ធិប្រាតិភោគ និង មុនពេលដែលទ្រព្យនោះមានសុក្រឹតភាពនោះ អ្នកជួលនោះនឹងទទួលបាននូវសិទ្ធិជួលរបស់ខ្លួនដោយមិនជាប់ជាមួយសិទ្ធិប្រាតិភោគទៅជាមួយនោះទេ។ ប៉ុន្តែករណីខាងលើមិនអនុវត្តនោះទេ ប្រសិនបើអ្នកជួលក្នុងអាជីវកម្មធម្មតា បើទោះបីជាអ្នកជួលបានដឹងមុនពីសិទ្ធិប្រាតិភោគ និងសិទ្ធិប្រាតិភោគនោះ ត្រូវបានធ្វើសុក្រឹតកម្មក៏ដោយ ក៏អ្នកទិញមិនទទួលយកជាប់ជាមួយសិទ្ធិប្រាតិភោគលើទ្រព្យនោះជាមួយទេ។

### ៤. សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញ

សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញ គឺជាសិទ្ធិប្រាតិភោគដែលកាន់កាប់ដោយអ្នកលក់ទំនិញជឿ ឬម្ចាស់ទំនិញបានឱ្យប្រាក់ខ្ចីទិញទំនិញ។ ដើម្បីទទួលបាននូវអាទិភាព ម្ចាស់បំណុលនៃ

កិច្ចធានាទាមទារឱ្យធ្វើការតម្កល់លិខិតជូនដំណឹងស្តីពីសិទ្ធិប្រាតិភោគរបស់ខ្លួនក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីកូនបំណុលទទួលបានការប្រគល់ទំនិញ ដែលនាំឱ្យម្ចាស់បំណុលមានអាទិភាព លើប្រាក់ខ្ចីទិញទំនិញដោយត្រូវបានចាត់ទុកថាតម្កល់ ក្នុងរយៈពេលប្រាំថ្ងៃ ក្រោយសិទ្ធិប្រាតិភោគត្រូវបានភ្ជាប់។

### ៥. ការជម្រះចោលទ្រព្យធានា និងផលនៃទ្រព្យធានា

ផលនៃទ្រព្យធានាសំដៅទៅលើ អ្វីដែលទទួលបានពីការជម្រះចោលនៃទ្រព្យធានា ហើយការជម្រះចោលអាចធ្វើទៅបានដោយការលក់ ឬដោយការជួលទ្រព្យធានានោះ ឬតាមវិធីផ្សេងៗដោយកូនបំណុល។ នៅពេលដែលការជម្រះបានធ្វើហើយនោះ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយក្តី សិទ្ធិប្រាតិភោគត្រូវភ្ជាប់ជាស្វ័យប្រវត្តិទៅនឹងផលនៃការជម្រះចោល ប៉ុន្តែក៏មានករណីខ្លះសិទ្ធិប្រាតិភោគនៅបន្តលើទ្រព្យធានាដូចជា ករណីអ្នកទិញបានដឹងថាមានសិទ្ធិប្រាតិភោគជាមុន។ សិទ្ធិប្រាតិភោគលើផលនៃទ្រព្យ ត្រូវមានសុក្រឹតភាពក្នុងរយៈពេល២០ថ្ងៃ បន្ទាប់ពីកូនបំណុលទទួលបាននូវផលនៃទ្រព្យធានានោះ ប្រសិនបើសិទ្ធិប្រាតិភោគលើទ្រព្យធានានោះត្រូវបានធ្វើសុក្រឹតកម្មដើមរួច។ តែករណីនេះមិនអនុវត្តទេ ប្រសិនបើផលជាទ្រព្យធានាជារូបិយវត្ថុ ឬករណីផលនោះមានលក្ខណៈដូចក្នុងលិខិតជូនដំណឹង។ តែប្រសិនបើមិនក្នុងករណីទាំងនោះទេ ម្ចាស់បំណុលត្រូវធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានា មុនផុតរយៈពេល ២០ថ្ងៃ។

### ៦. សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញឧបករណ៍ សត្វពាហនៈ និងសារពើភណ្ឌ

ប្រាក់ខ្ចីទិញទំនិញ ត្រូវបានផ្តល់ឱ្យកូនបំណុលដើម្បីទិញទំនិញ ដូចជា ឧបករណ៍ជាក់លាក់ សត្វពាហនៈ ឬ សារពើភណ្ឌ ហើយសិទ្ធិប្រាតិភោគគឺមានលើទំនិញនោះតែម្តង។ សិទ្ធិត្រូវបានយកមកអនុវត្តពិសេសជាងគេ ដោយច្បាប់បានផ្តល់ឱ្យនូវវិធានពិសេសមួយសំរាប់ធានាដល់ម្ចាស់បំណុលនៃសិទ្ធិនេះ មានអាទិភាពជាងសិទ្ធិដ៏ទៃទៀតលើទំនិញ ដែលត្រូវបានដាក់ធានា។ បើទោះបីជាសិទ្ធិប្រាតិភោគដ៏ទៃទៀតបានធ្វើនូវសុក្រឹតកម្មរួចហើយក៏ដោយ ក៏ម្ចាស់បំណុលលើប្រាក់ខ្ចីទិញទំនិញ មានអាទិភាពជាងគេដែរ។ គោលការណ៍នៃវិធានការពិសេសខាងលើ គឺដើម្បីជំរុញឱ្យប្រតិបត្តិការផ្នែកលក់ទំនិញឱ្យមានការលូតលាស់ និងសកម្មទៅមុន ដោយផ្តល់ឱ្យនូវមធ្យោបាយជឿ ដើម្បីពន្យាពេលរកប្រាក់ដើមមកសងវិញ និងហេតុផលមួយទៀត គឺដើម្បីចៀសវាងការចំណាយច្រើនទាំងពេលវេលា និងទ្រព្យសម្បត្តិរបស់ម្ចាស់បំណុល ដើម្បីស្រាវជ្រាវពីការតម្កល់លិខិតជូនដំណឹង ដែលបញ្ជាក់ពីវត្តមានសុក្រឹតភាពមុនៗដែរឬទេ។

### ៧. ចលនវត្ថុតាំងភ្ជាប់

ចលនវត្ថុតាំងភ្ជាប់ គឺជាទំនិញដែលត្រូវបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬមានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុ តាមរបៀបមួយដែលនាំឱ្យមានសិទ្ធិភណ្ឌិតកើតឡើងតាមច្បាប់ភូមិបាល។ ចលនវត្ថុតាំងភ្ជាប់នេះមានត្រូវបានបែងចែកជាពីរ គឺ អចលនវត្ថុពីកំណើត និង អចលនវត្ថុតាមភ័ព្វវាសនា។ ដោយឡែកដើម្បីទទួលបានសិទ្ធិអាទិភាពទៅលើ ចលនវត្ថុប្រភេទនេះ លុះត្រាតែម្ចាស់បំណុលបានធ្វើលិខិតជូនដំណឹងនៅការិយាល័យតម្កល់មុន ម្ចាស់បំណុលផ្សេងទៀតដូចជា ម្ចាស់បំណុលនៃសិទ្ធិឃាត់ទុក ម្ចាស់បំណុលហ៊ីប៉ូតែកបានធ្វើការចុះបញ្ជី ឬ ម្ចាស់បំណុលអចលនវត្ថុផ្សេងទៀតបានធ្វើការចុះបញ្ជី នៅការិយាល័យចុះបញ្ជីដែលកំណត់តាមច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ តែប្រសិនបើសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញ ត្រូវមានអាទិភាពដោយការតម្កល់លិខិតជូនដំណឹងមុនពេលដែលទំនិញក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ឬ ប្រាំថ្ងៃបន្ទាប់ពីទំនិញបានក្លាយជាចលនវត្ថុតាំងភ្ជាប់។ តែករណីខាងលើនេះលើមិនអនុវត្តទេ ចំពោះការបញ្ចាំចលនវត្ថុដែលធ្វើឡើងដើម្បីផ្តល់ហិរញ្ញប្បទានដល់ការសាងសង់ដើម្បីកែលំអដី។

### ៨. ផលដំណាំ

ដំណាំកំពុងដាំដុះក៏អាចជាទ្រព្យធានាផងដែរ ដោយម្ចាស់បំណុលមានសិទ្ធិប្រាតិភោគលើផលដំណាំនេះ ដោយការផ្តល់ឱ្យនូវប្រាក់សំរាប់ទិញពូជ និងដី ទៅឱ្យកូនបំណុល ហើយដែលច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានផ្តល់ឱ្យនូវអាទិភាពទៅម្ចាស់បំណុល ប្រសិនកូនបំណុលបានកាន់កាប់អចលនទ្រព្យ ឬមានសិទ្ធិលើអចលនទ្រព្យដែលបានចុះបញ្ជីតាមច្បាប់ជាធរមាន។

### ៩. វត្ថុចំណុះ

វត្ថុចំណុះគឺជាចលនវត្ថុដែលត្រូវបានផ្គុំបញ្ចូលគ្នាជាមួយចលនវត្ថុផ្សេង តាមរបៀបដែលមិនធ្វើឱ្យបាត់បង់អត្តសញ្ញាណនៃចលនវត្ថុចំបងនោះទេ។ ហើយតាមមាត្រា២២ នាំច្បាប់ខាងលើបានបញ្ញត្តិថា សិទ្ធិប្រាតិភោគដែលបានបង្កើតលើវត្ថុចំណុះនោះនៅតែបន្តទោះបីជាវត្ថុធានានោះក្លាយទៅជាវត្ថុចំណុះក្តី ហើយសុក្រឹតកម្មក៏ដូចគ្នា។ ក្នុងករណីដែលកូនបំណុលមិនសង ម្ចាស់បំណុលអាចធ្វើការដកហូតនូវ វត្ថុចំណុះនោះមកវិញបាន ប្រសិនបើសិទ្ធិប្រាតិភោគនោះមានអាទិភាពជាងសិទ្ធិដ៏ទៃទៀត តែបើសិទ្ធិរបស់អ្នកកាន់កាប់មានអាទិភាពជាង ម្ចាស់បំណុលត្រូវសងការខូចខាតជាក់ស្តែង ឬជួសជុលលើចលនវត្ថុទាំងមូលដែលកាន់កាប់ដោយអ្នកដែលមិនមែនជាកូនបំណុល តែមិនរាប់បញ្ចូលនូវ ការចុះតម្លៃដែលបណ្តាលមកពីការគ្មានវត្ថុចំណុះនោះទេ និងបុគ្គលដែលមាន

សិទ្ធិទារសំណងមានសិទ្ធិទាមទារការធានាច្បាស់លាស់មុននឹងអនុញ្ញាតឱ្យមានការរុះរើយកវត្ថុចំណុះ។

### ១០. ទំនិញបញ្ចូលគ្នា

ទំនិញបញ្ចូលគ្នានេះ សំដៅទៅលើទំនិញដែលត្រូវបានដាក់បញ្ចូលគ្នាជាមួយទំនិញដទៃទៀតតាមរបៀបមួយ ដែលធ្វើឱ្យអត្តសញ្ញាណនៃទំនិញត្រូវបានបាត់បង់ រួចវាបង្កើតបាននូវផលិតផលមួយ ឬច្រើនថ្មីទៀត។ ឧទាហរណ៍ នំពងទា ត្រូវបានផ្សំឡើងពីផលិតផលច្រើនបញ្ចូលគ្នាដូចជា ពងទា ម្សៅ ស្ករត្នោតជាដើម។ ដូច្នេះសិទ្ធិប្រាតិភោគដែលប្រើប្រាស់នៅក្នុងប្រតិបត្តិការនេះមិនមែនជាសិទ្ធិប្រាតិភោគដែលមានលើ ពងទា ឬម្សៅ នោះទេ តែសិទ្ធិប្រាតិភោគនេះមាននៅលើផលិតផលសំរេចតែម្តង តាមឧទាហរណ៍ខាងលើ គឺនំពងទាតែម្តង។ ប្រសិនសិទ្ធិប្រាតិភោគដែលមាននៅលើ សមាសធាតុត្រូវបានធ្វើសុក្រឹតកម្ម នោះសិទ្ធិប្រាតិភោគលើផលិតផលសម្រេចក៏ត្រូវបានសន្មតថា មានសុក្រឹតភាពដែល ហើយមានអាទិភាពជាងសិទ្ធិប្រាតិភោគផ្សេងៗដែលមិនទាន់ធ្វើសុក្រឹតកម្ម។ ប៉ុន្តែប្រសិនបើ ធាតុផ្សំដែលត្រូវយកមកបញ្ចូលគ្នាត្រូវបានស្ថិតនៅក្រោមសិទ្ធិប្រាតិភោគលើសពីមួយ នោះលំដាប់អាទិភាពត្រូវអាស្រ័យលើតម្លៃនៃទ្រព្យធានានីមួយៗ។

### ១១. អ្នកទិញកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម

កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម គឺចង់សំដៅទៅរកការទិញនូវ កិច្ចសន្យាលក់មួយដែលមានកិច្ចធានា ឬលិខិតស្នាម ដែលនាំឱ្យអ្នកទិញមានអាទិភាពលើផលនៃកិច្ចសន្យាលក់ផងដែរប្រសិនបើ អ្នកទិញបានផ្តល់ឱ្យអ្នកលក់នូវតម្លៃថ្មីមួយ ដើម្បីបានការកាន់កាប់លើកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាម និង កិច្ចសន្យាលក់នោះមិនបានបង្ហាញថាត្រូវបានផ្ទេរសិទ្ធិទៅឱ្យបុគ្គលផ្សេងទេ។

### ក. អនុប្បទាននូវសិទ្ធិ

តាមមាត្រា ២៥នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានផ្តល់សិទ្ធិឱ្យបុគ្គលអាចធ្វើការផ្ទេរសិទ្ធិរបស់ខ្លួនមួយផ្នែក ឬទាំងអស់ លើគណនីកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម និងសិទ្ធិលើទ្រព្យអរូបិយផ្សេងៗទៀត ដែលមាននៅពេលបច្ចុប្បន្ន និងពេលអនាគត។ អ្នកទទួលបាននូវសិទ្ធិគោរពទៅតាមការព្រមព្រៀងរបស់ភាគីអ្នកផ្ទេរឱ្យ។ ការធ្វើអនុប្បទាននេះមិនចាំបាច់មានការជូនដំណឹងទៅកូនបំណុលនោះទេ លើងលែងតែអនុប្បទាយីមានបំណងឱ្យភាគីកូន

បំណុលធ្វើការទូទាត់ថ្លៃទំនិញឱ្យទៅអនុប្បទាយីផ្ទាល់។ ការជូនដំណឹងក្នុងករណីនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខាអនុប្បទាយី ឬអនុប្បទានិកផងដែរ។

**ខ. សិទ្ធិរបស់តតិយជន**

កិច្ចសន្យានឹងមិនអាចអនុវត្តបានឡើយ ប្រសិនបើ ភាគីត្រូវបានកំរិតសមត្ថភាពក្នុងការលក់ ឬផ្ទេរសិទ្ធិលើទ្រព្យអរូបី។ វិធាននេះបានជួយឱ្យភាគី អាចធ្វើការផ្ទេរ ឬលក់ទ្រព្យអរូបីដោយសេរី និងការទទួលយកសិទ្ធិប្រាតិភោគលើវាបានដោយងាយ ដោយមិនចាំបាច់ក្នុងការប្រុងប្រយ័ត្ន ដើម្បីកំណត់ថាកិច្ចសន្យានោះអាចនឹងមោឃភាពដល់ការលក់ ឬអត់ ដែលបង្ករឱ្យមានការពន្យាពេល និងការចំណាយដែលមិនចាំបាច់។

❖ ចំណាំ

ម្ចាស់បំណុលមានកិច្ចធានា និងម្ចាស់បំណុលដ៏ទៃទៀតដែលមានសិទ្ធិអាទិភាពតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា អាចព្រមព្រៀងគ្នាធ្វើការកែប្រែ ឬលុបចោលអាទិភាពរបស់ខ្លួនបាន ហើយមិនចាំបាច់ធ្វើការតម្កល់លិខិតជូនដំណឹងអ្វីនោះទេ។

ជារួមមក កិច្ចសន្យាប្រាតិភោគនៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា បានបើកផ្លូវឱ្យភាគីមានភាពងាយស្រួល នៅក្នុងការបង្កើតដោយគ្រាន់តែបំពេញតាមលក្ខខណ្ឌមួយចំនួនដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីក្នុងឋានៈជាច្បាប់សារធាតុ។ លើសពីនេះថែមទៀតច្បាប់នេះក៏បាននាំមកនូវប្រព័ន្ធសុវត្ថិភាពបីយ៉ាង សម្រាប់ម្ចាស់បំណុលធ្វើការពារខ្លួន ដើម្បីធ្វើការតតាំងជាមួយតតិយជនក្នុងករណីមានការប្រជែងសិទ្ធិ តែសុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹង ការកាន់កាប់ និង សុក្រឹតកម្មដោយស្វ័យប្រវត្តិ។

ដោយឡែកបន្ទាប់ពីកិច្ចសន្យាមួយត្រូវបានបង្កើតហើយនោះ ប្រសិនបើកិច្ចសន្យាប្រាតិភោគនោះមិនត្រូវបានអនុវត្តដោយកូនបំណុល ថាតើនឹងមានរឿងអ្វីកើតឡើងចំពោះម្ចាស់បំណុល និងត្រូវធ្វើយ៉ាងណាដើម្បីទទួលបានការសង។ ចំណុចនេះនឹងត្រូវបានបង្ហាញ នៅក្នុងជំពូកទី៣ បន្ទាប់នេះ។

# ជំពូកទី៣
# ការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានា

ក្នុងផ្នែកនេះ យើងនឹងធ្វើការសិក្សាទៅលើការអនុវត្តប្រតិបត្តិការដែលមានកិច្ចធានាក្នុងករណីដែលភាគីកូនបំណុលមិនអនុវត្តកាតព្វកិច្ច តាមការកំណត់របស់គូភាគីនៅក្នុងកិច្ចសន្យាប្រាតិភោគ ។ គូភាគីនៃកិច្ចសន្យាប្រាតិភោគស្តីពីប្រតិបត្តិការដែលមានកិច្ចធានាអាចធ្វើការកំណត់ពីអត្ថន័យនៃការមិនអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួនបាន ហេតុថា ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមិនបានធ្វើការកំណត់ពីការមិនសងបំណុល ឬមិនបានចែងថាតើពេលណា និងស្ថិតនៅក្រោមកាលៈទេសៈណា ដែលការមិនសងបំណុលកើតឡើងទេ។ ដោយយោងតាមកិច្ចព្រមព្រៀងប្រាតិភោគ ជាកិច្ចសន្យារវាងភាគីទាំងពីរ នោះភាគីនៃកិច្ចព្រមព្រៀងនោះមានសេរីភាពក្នុងការកំណត់ពីកាលៈទេសៈនៃការមិនសងបាន។ នៅពេលដែលគ្មានការអនុវត្តកាតព្វកិច្ចម្ចាស់បំណុលអាចអនុវត្តបាននូវសិទ្ធិកាន់កាប់ ឬគ្រប់គ្រងទ្រព្យធានាតាមសិទ្ធិរបស់ខ្លួនបាន បើទោះបីជាកិច្ចសន្យាគ្មានចែងពីការកាន់កាប់ ឬការត្រួតត្រាក៏ដោយ។ ការដែលមានកូនបំណុលមិនសងបំណុល ម្ចាស់បំណុលអាចមានមធ្យោបាយច្រើនក្នុងការដោះស្រាយទៅលើបញ្ហានេះ ដែលសិទ្ធិនិងដំណោះស្រាយអាចអនុវត្តតាមច្បាប់ ឬតាមការកំណត់នៅក្នុងកិច្ចសន្យាគូភាគីក៏បាន។ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានអនុញ្ញាតឱ្យភាគីម្ចាស់បំណុលអាចអនុវត្តសិទ្ធិណាមួយ ឬទាំងអស់របស់ខ្លួននៅពេលតែមួយទៅលើកូនបំណុលបាន។ ដោយយោងតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាបានរំលេចឡើងនូវដំណោះស្រាយសម្រាបបញ្ហាខាងលើនេះ ដោយបានផ្តល់សិទ្ធិឱ្យទៅម្ចាស់បំណុលមួយចំនួន ដែលនឹងធ្វើការសិក្សាបន្តទៀតនេះ។

## ផ្នែកទី១ សិទ្ធិក្នុងការឃាត់ទុក កាន់កាប់ និងប្រមូលទ្រព្យធានា

នៅពេលដែលកូនបំណុលខកខានក្នុងការសងកាតព្វកិច្ច ម្ចាស់បំណុលប្រាកដជាស្វះស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីជួយខ្លួនឯងឱ្យប្រមូលបំណុលមកវិញឱ្យបានកាន់តែឆាប់រហ័សតាមដែលអាចធ្វើទៅបានដើម្បីបញ្ចៀសនូវការខាតបង់នានា។ ដោយហេតុថា នីតិនិពន្ធបានសិក្សាពីគោលគំនិតទាំងនេះហើយ ទើបបានជានៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលកិច្ចធានា បានផ្តល់នូវមធ្យោបាយសង្គ្រោះខ្លួនឯងទៅកាន់ម្ចាស់បំណុល តាមរយៈការកាន់កាប់ និងឃាត់ទុកទ្រព្យធានារបស់កូនបំណុលដោយស្របច្បាប់ និងមិនតម្រូវឱ្យឆ្លងកាត់នីតិវិធីតុលាការលើកលែងតែករណីពិសេស។

**កថាខណ្ឌទី ១ សិទ្ធិក្នុងការឃាត់ទុក**

យោងតាមមាត្រា ៥១ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ម្ចាស់បំណុលនៃកិច្ចធានា អាចធ្វើការស្នើសុំឃាត់ទុកទ្រព្យធានា ដើម្បីឱ្យមានការទូទាត់កាតព្វកិច្ចមួយផ្នែក ឬទាំងស្រុងបាន។ ការស្នើសុំដើម្បីធ្វើការឃាត់ទុកខាងលើនេះ ប្រសិនបើកូនបំណុលធ្វើការយល់ព្រមក្នុងរយៈពេល២០ថ្ងៃ បន្ទាប់ពីមានការស្នើសុំ ម្ចាស់បំណុលអាចធ្វើការរក្សាទុកវត្ថុធានានោះរហូតដល់តែកូនបំណុលព្រមអនុវត្តកាតព្វកិច្ច។ ដោយឡែកលក្ខខណ្ឌនៃការឃាត់ទុកមិនបានចែងច្បាស់លាស់នោះទេ នៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដូច្នេះបញ្ញត្តិស្តីពីការឃាត់ទុកនៅក្នុងក្រមរដ្ឋប្បវេណីត្រូវចូលខ្លួនមកគ្រប់គ្រងបញ្ហានេះ។ ដោយយោងតាមមាត្រា៧៧៤ នៃក្រមរដ្ឋប្បវេណី បានចែងថា សិទ្ធិឃាត់ទុកមិនត្រូវកើតមានឡើយ ប្រសិនបើសិទ្ធិលើបំណុលនោះមិនដល់ពេលកំណត់ត្រូវសង។ បន្ថែមពីលើនេះក្រមរដ្ឋប្បវេណីក៏បានផ្តល់ឱ្យម្ចាស់បំណុលនូវកាតព្វកិច្ចមួយចំនួនដូចមានចែងក្នុងមាត្រា៧៧៦ ដោយម្ចាស់បំណុលត្រូវកាន់កាប់វត្ថុដែលឃាតទុកនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ហើយករណីណាក៏ដោយម្ចាស់បំណុលមិនអាចយកវត្ថុធានាទៅប្រើប្រាស់ ឬជួល ឬដាក់ប្រាតិភោគបាននោះទេ បើគ្មានការយល់ព្រមពីសំណាក់កូនបំណុល ប៉ុន្តែម្ចាស់បំណុលអាចប្រើប្រាស់ ក្នុងកម្រិតនៃការរក្សាទុកវត្ថុនោះប៉ុណ្ណោះ ប្រសិនបើមិនដូច្នេះទេសិទ្ធិឃាត់ទុកនឹងរលត់ទៅវិញ។ សិទ្ធិឃាត់ទុកក៏ត្រូវរំលត់ដោយមូលហេតុមួយចំនួនទៀតដូចដែលបានចែងក្នុងមាត្រា៧៨០ នៃក្រមរដ្ឋប្បវេណី ដោយទាមទារឱ្យភាគីម្ចាស់បំណុលរក្សានូវការកាន់កាប់លើទ្រព្យធានាកុំឱ្យបាត់បង់ ប្រសិនបើបាត់បង់ការកាន់កាប់ តែម្ចាស់បំណុលបានទទួលការកាន់កាប់មកវិញស្របតាមបញ្ញត្តិនៃមាត្រា៧៧៦ ស្តីពីសិទ្ធិទាមទារការកាន់កាប់មកវិញ។ តែផ្ទុយទៅវិញ ប្រសិនបើកូនបំណុលមិនយល់ព្រមក្នុងរយៈពេល២០ថ្ងៃខាងលើទេនោះ ម្ចាស់បំណុលត្រូវតែការជ្រើសរើសវិធីមួយទៀតគឺការជម្រះចោលទ្រព្យធានា។

**កថាខណ្ឌទី ២ សិទ្ធិក្នុងការកាន់កាប់ទ្រព្យធានា**

ក្រោយពេលដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ម្ចាស់បំណុលដែលមានកិច្ចធានា អាចធ្វើការសុំទៅកូនបំណុលជាលាយលក្ខណ៍អក្សរដើម្បីធ្វើការកាន់កាប់ ឬត្រួតត្រាលើទ្រព្យធានានោះមួយផ្នែក ឬទាំងមូល ដោយមិនចាំបាច់ដាក់ពាក្យបណ្តឹងទៅតុលាការនោះទេ។

ប្រសិនបើក្នុងកំឡុងពេល បន្ទាប់ពីការស្នើសុំ កូនបំណុលបានធ្វើការជំទាស់ នោះម្ចាស់បំណុលអាចធ្វើការប្តឹងទៅ តុលាការដើម្បីផ្តល់សិទ្ធិឱ្យខ្លួនក្នុងការកាន់កាប់ ឬត្រួតត្រាលើទ្រព្យធានា

តាមរយៈដីកាសម្រេចកិច្ចការប្រញាប់[23]។ នៅក្នុងសវនាការ តុលាការត្រូវផ្តោតតែបញ្ហាដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងប្រាតិភោគ ដែលចែងពីទ្រព្យធានា ហើយត្រូវមានការខកខានមិនបានសងបំណុលយ៉ាងតិចមួយលើកតែប៉ុណ្ណោះដោយមិនធ្វើការវិនិច្ឆ័យលើចំណុចផ្សេងនោះទេ។ ម្ចាស់បំណុលអាចយកដីកាសម្រេចស្ថាពររបស់តុលាការមកអនុវត្តបាន ក្នុងករណីត្រូវការកម្លាំងដើម្បីទទួលបានការកាន់កាប់នោះ ម្ចាស់បំណុលអាចត្រូវការពឹងលើកម្លាំងអាជ្ញាសាលា ឬមន្រ្តីនគរបាលយុត្តិធម៌ដោយត្រូវបង់ថ្លៃសេវាជាប្រាក់រៀល ទៅតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងយុត្តិធម៌។

### កថាខណ្ឌទី៣ សិទ្ធិក្នុងការប្រមូលទ្រព្យធានា

ក្នុងករណីកូនបំណុលមិនអនុវត្តកាតព្វកិច្ចសងបំណុល ទៅម្ចាស់បំណុលនោះទេ ម្ចាស់បំណុលដែលមានកិច្ចធានាខ្លួនឯងផ្ទាល់ មានសិទ្ធិក្នុងការប្រមូលភ្លាមៗនូវគណនីដែលជាទ្រព្យធានា ឬផលនៃទ្រព្យធានាបាន ដោយមិនចាំបាច់ធ្វើការប្តឹងទៅតុលាការដើម្បីអនុវត្តនីតិវិធីនោះទេ។ គណនី គឺជាសិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានលក់ ឬបានជួល ឬថ្លៃសេវាកម្មដែលមិនមែនជាលិខិតស្នាម ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា។ ចំនែកឯផលនៃទ្រព្យធានា គឺ អ្វីដែលទទួលបាននៅពេលលក់ ជួល ឬផ្តល់អាជ្ញាប័ណ្ណ ដោះដូរ ឬការជម្រះចោលទ្រព្យ ធានាតាមវិធីផ្សេងពីនេះដូចជាអ្វីៗដែលប្រមូលបានពីទ្រព្យធានា អ្វីៗត្រូវបែងចែកពីទ្រព្យធានា ដូចជាសិទ្ធិដែលកើតចេញពីទ្រព្យធានា អ្វីៗត្រូវបែងចែកពីទ្រព្យធានា បណ្តឹងទាមទារដែលកើតចេញពីទ្រព្យខាតបង់ ការមិនគោរពតាមវិការៈ ឬការខូតខាតទ្រព្យធានា ទៅតាមកម្រិតតម្លៃនៃទ្រព្យធានា ថ្លៃធានារ៉ាប់រងដែលត្រូវសងដោយសារ ការខាតបង់ ឬការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានាទៅតាមកម្រិតតម្លៃទ្រព្យធានា និងតាមកម្រិតដែលត្រូវចេញសងកូនបំណុល ឬម្ចាស់បំណុលដែលមានកិច្ចធានា។ ផលជា

[23] ដីកាសម្រេចកិច្ចការប្រញាប់នេះ ជាសញ្ញាណនៅក្នុងសារាចរលេខ ០៤ ស្តីពីនីតិវិធីរដ្ឋប្បវេណី ដែលបានដាក់ឱ្យប្រើក្នុងសម័យរដ្ឋកម្ពុជា និងបន្តប្រើប្រាស់ក្នុងសម័យអន្តរកាលរហូតដល់ពេលដែលក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ត្រូវបានដាក់ឱ្យអនុវត្តទើបនិរាករណ៍សារាចរនោះ។ តាមសារាចរលេខ ០៤ តុលាការអាចចេញដីកាសម្រេចកិច្ចការប្រញាប់តាមសំណូមពររបស់ភាគី ដែលដីកានេះមានគោលបំណងក្នុងការបង្ការហានិភ័យផ្សេងៗ ដែលអាចនឹងកើតឡើងក្នុងអំឡុងពេលនីតិវិធី ហើយដីកានេះមិនអាចប៉ះពាល់ដល់អង្គសេចក្តីឡើយ ដូចជាដីកាសម្រេចឱ្យកត់ទ្រព្យសម្បត្តិ (បញ្ជីសារពើភណ្ឌ តាមក្រមនីតិវិធីរដ្ឋប្បវេណីជាធរមាន) និងប្រគល់សិទ្ធិដល់ជនណាម្នាក់ ឱ្យថែរក្សាជាបណ្តោះអាសន្ន នូវទ្រព្យសម្បត្តិដែលមានទំនាស់ ឬទ្រព្យសម្បត្តិសម្រាប់ការពារផលប្រយោជន៍របស់គូភាគី។ បើយើងធ្វើការប្រៀបធៀបចរិតលក្ខណៈនៃដីកានេះទៅនឹងវិធានក្នុងក្រមនីតិវិធីរដ្ឋប្បវេណីវិញ វាជាសញ្ញាណនៃការចាត់ចែងរក្សាការពារ។

រូបិយវត្ថុ មានន័យថា ផលជាសាច់ប្រាក់មូលប្បទានប័ត្រ មូលនិធិដែលផ្ញើក្នុងធនាគា និងផលនៃទ្រព្យធានា ដែលមានលក្ខណៈដូចគ្នា។

ប្រសិនបើជាការចាំបាច់ ម្ចាស់បំណុលដែលមានកិច្ចធានាអាចជូនដំណឹងដល់កូនបំណុលគណនី ដើម្បីឱ្យធ្វើការសងបំណុលមកឱ្យខ្លួន និងមិនត្រូវសងទៅកូនបំណុលនៃកិច្ចធានានោះទេ។ ក្នុងការប្រមូលបំណុលរបស់ម្ចាស់បំណុលពីគណនីរបស់កូនបំណុលហើយ ប្រសិនបើចំនួនទឹកប្រាក់មានបរិមាណលើសពីទំហំបំណុលរបស់ខ្លួន នោះម្ចាស់បំណុលត្រូវធ្វើការទូទាត់ទំហំដែលលើសនោះ មកឱ្យកូនបំណុលនៃកិច្ចធានាវិញ ប៉ុន្តែប្រសិនបើប្រាក់ដែលប្រមូលបានពីគណនី មិនអាចរំលត់នូវសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃកិច្ចធានាបាននោះទេ កូនបំណុលនៃកិច្ចធានាត្រូវមានកាតព្វកិច្ចសងទៅម្ចាស់បំណុលនៃកិច្ចធានាដដែល ត្រឹមកម្រិតដែលនៅសល់។ ប៉ុន្តែករណីនេះមិនអាចយកទៅអនុវត្តបានឡើយ ករណីដែលប្រតិបត្តិការនោះជាការលក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ដែលម្ចាស់បំណុលត្រូវទទួលខុសត្រូវលើការខាតបង់ ឬចំណេញពីការប្រមូលបំណុលពីកូនបំណុលគណនី លើកលែងតែមានការចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងប្រាតិភោគ[24]។

## ផ្នែកទី២ សិទ្ធិក្នុងការជម្រះចោលទ្រព្យធានា

### កថាខណ្ឌទី១ ការជម្រះចោលទ្រព្យធានា និងការលោះទ្រព្យធានា

នៅពេលដែលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានា មានសេរីភាពក្នុងការជម្រះចោលនូវទ្រព្យធានាបាន បន្ទាប់ពីបានធ្វើការកាន់កាប់ ឬត្រួតត្រាលើទ្រព្យធានាដូចមានកំណត់នៅចំណុចខាងលើ។ ការជម្រះចោលអាចត្រូវបានធ្វើការជម្រះចោលទាំងអស់ក្នុងពេលតែមួយ ឬក៏មួយផ្នែកម្តងក៏បាន តាមការសម្រេចរបស់ម្ចាស់បំណុល។ ទិដ្ឋភាពនៃការជម្រះចោលអាចធ្វើឡើងដោយមានលក្ខណៈជាឯកជន ឬជាសាធារណៈក្រោមរូបភាពដូចជា៖

- ជួលទ្រព្យធានាទាំងអស់ ឬមួយផ្នែក
- លក់ទ្រព្យធានាទាំងអស់ ឬមួយផ្នែក
- ផ្តល់អាជ្ញាប័ណ្ណទ្រព្យធានាទាំងអស់ ឬមួយផ្នែក
- រក្សាទុកក្នុងកាលៈទេសៈមួយចំនួននូវទ្រព្យធានាទាំងអស់ ឬមួយផ្នែក។

[24] ក្រសួងពាណិជ្ជកម្ម, *ការពន្យល់ និងឧទាហរណ៍ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា,* (ឯកសារបណ្តុះបណ្តាល), ១០២

ម្ចាស់បំណុលក៏អាចទិញយកទ្រព្យធានានោះបាន ដោយការផ្តល់នូវតម្លៃទិញជាសាធារណៈនៃប្រតិបត្តិការលក់ ឬការលក់ជាលក្ខណៈឯកជន។

ប្រសិនបើកូនបំណុលទាមទារ ហើយទ្រព្យនោះមិនស្ថិតនៅក្នុងកាលៈទេសៈនៃការលក់ដោយប្រញាប់ម្ចាស់បំណុល ដែលមានកិច្ចធានា អាចធ្វើការជូនដំណឹងទៅកូនបំណុលនោះនូវៈ

- លិខិតជូនដំណឹងសមស្រប ដែលមានរៀបរាប់ពីពេលវេលា និងទីកន្លែងលក់ជាសាធារណៈ
- លិខិតជូនដំណឹងសមស្រប ដែលមានបញ្ជាក់ពីការលក់ជាឯកជន ឬជម្រះចោលជាឯកជននូវទ្រព្យធានានោះ។

អ្នករៀបចំការលក់ត្រូវធ្វើការជូនដំណឹងទៅម្ចាស់បំណុលផ្សេងទៀត ដែលខ្លួនបានទទួលកំណត់ត្រាជាលាយលក្ខណអក្សរអំពីសិទ្ធិលើទ្រព្យធានាមុនពេលធ្វើការជម្រះចោល។ នៅពេលធ្វើការជម្រះចោលនូវទ្រព្យធានានោះទាមទារឱ្យភាគីម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវគោរពទៅតាម "គោលការណ៍ពាណិជ្ជកម្មសមស្រប"។ គោលការណ៍ពាណិជ្ជកម្មសមស្របនេះគឺទាមទារឱ្យម្ចាស់បំណុល ធ្វើការលក់ឱ្យសមស្របទៅនឹងទីកន្លែង ពេលវេលា និងតម្លៃទីផ្សារនៃតម្លៃទ្រព្យបច្ចុប្បន្ន។

ក្រោយពីពេលជម្រះចោលផលនៃទ្រព្យធានានឹងត្រូវអនុវត្តទៅតាមសេចក្តីបង្គាប់ដូចតទៅៈ

- ការយកផលនោះត្រូវយកទៅទូទាត់ជាមួយនឹងការចំណាយសមស្រប ដែលបានកើតមានឡើងដោយការជម្រះចោលទ្រព្យធានា ដោយមានដូចជា ការស្តុបទុកទ្រព្យធានា ការរៀបចំទ្រព្យធាន និងការចំណាយលើឯកសារច្បាប់មួយចំនួនរបស់ម្ចាស់បំណុលដែលមានកិច្ចធានា។
- ការយកផលនោះទៅ ជម្រះលើបំណុលដែលមានកិច្ចធានា ទៅតាមចំនួនដែលមានចែងក្នុងកិច្ចសន្យាប្រាតិភោគរវាងគូភាគី។
- ការយកផលនោះ ទៅជម្រះជាមួយម្ចាស់បំណុល ដែលមានកិច្ចធានាផ្សេងទៀត ប្រសិនបើមានការទាមទារជាលាយលក្ខណ៍អក្សរ រួមជាមួយនឹងភស្តុតាងត្រឹមត្រូវ។
- ទូទាត់បំណុលគ្មានទ្រព្យធានាដទៃទៀតដែលបានទទួលស្គាល់។

ប្រសិនបើទឹកប្រាក់ដែលម្ចាស់បំណុលដែលមានកិច្ចធានា ទទួលបានពីការលក់ទ្រព្យធានានោះ លើសពីបំណុលដើមដែលកូនបំណុលជំពាក់ ម្ចាស់បំណុលដែលមានកិច្ចធានមានកាតព្វកិច្ចសងនូវចំនួនលើសនោះឱ្យទៅកូនបំណុលវិញ។ ប៉ុន្តែបើចំនួនទឹកប្រាក់ដែលម្ចាស់បំណុលមានកិច្ចធានា ប្រមូលបាននោះតិចជាបំណុលដើមដែលកូនបំណុលជំពាក់វិញ កូនបំណុលនោះត្រូវមានកាតព្វកិច្ចសងនូវចំនួនដែលខ្វះនោះទៅម្ចាស់បំណុល លើកលែងមានការព្រមព្រៀងរវាងគូរភាគី។

ក្នុងកាលៈទេសៈមួយចំនួន កូនបំណុល ឬម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត អាចធ្វើការលោះយកទ្រព្យធានា ដោយអនុវត្តកាតព្វកិច្ចទាំងអស់ ដែលធានាដោយទ្រព្យធានា និងចេញថ្លៃចំណាយសមស្របដែលម្ចាស់បំណុលដែលមានកិច្ចធានាបានចំណាយនានា ក្នុងការទទួលបានការកាន់កាប់ និងរៀបចំទ្រព្យធានាសំរាប់ធ្វើការជម្រះចោល ដូចជាថ្លៃដឹកជញ្ជូន ថ្លៃស្តុកទុកជាដើម ថ្លៃជួសជុលទ្រព្យធានា ឬថ្លៃមេធាវីជាដើម។ កូនបំណុលត្រូវអនុវត្តនូវកាតព្វកិច្ចទាំងអស់ដែលត្រូវធានាដោយទ្រព្យធានានោះ។ ការលោះយកវត្ថុធានាមកវិញទាមទារឱ្យកូនបំណុល ឬម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ត្រូវតែធ្វើឡើងមុនពេលម្ចាស់បំណុលធ្វើការជម្រះចោលទ្រព្យធានា ឬមុនពេលដែលម្ចាស់បំណុលធ្វើការចុះកិច្ចសន្យា ដើម្បីជម្រះចោលទ្រព្យធានា ឬមុនពេលកាតព្វកិច្ចត្រូវបានរំលត់។

### កថាខណ្ឌទី២ ភាពស្របច្បាប់ក្នុងការអនុសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា

បើទោះបីជា ម្ចាស់បំណុលមានកិច្ចធានា មានសិទ្ធិក្នុងការកាន់កាប់ និង ជម្រះចោលទ្រព្យធានាក៏ដោយ ម្ចាស់បំណុលដែលមានកិច្ចធានានោះត្រូវអនុវត្តសិទ្ធិទាំងនេះតាមរបៀបត្រឹមត្រូវស្របតាមបទដ្ឋាននៃភាពសមស្របតាមគោលការណ៍ពាណិជ្ជកម្ម។ ការជម្រះបញ្ជីដែលសមស្របតាមគោលការណ៍ពាណិជ្ជកម្ម បង្គាប់ឱ្យភាគីម្ចាស់បំណុលធ្វើការជម្រះចោលទ្រព្យ នៅកន្លែង និងពេលវេលាសមស្រប និងតម្លៃទីផ្សារ តាមគោលការណ៍ពាណិជ្ជកម្មបច្ចុប្បន្ន[25]។ ក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានា អនុវត្តខុសពីបញ្ញត្តិខាងលើ ម្ចាស់បំណុលដែលមានកិច្ចធានានោះត្រូវទទួលខុសត្រូវចំពោះការខូតខាត របស់កូនបំណុល និងម្ចាស់បំណុលផ្សេងទៀតដែលបានជូនដំណឹងពីសិទ្ធិប្រាតិភោគរបស់ខ្លួនទៅម្ចាស់បំណុលដែលមានកិច្ចធានា មុនពេលជម្រះចោលទ្រព្យធានា។ កូនបំណុល និងម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត អាចចាត់វិធានការណ៍ជាមុនទៅលើការជម្រះចោលទ្រព្យធានាដែលមិនគោរពតាម គោលការណ៍ពាណិជ្ជកម្មរបស់ម្ចាស់បំណុលនៃប្រតិបត្តិការដើម។

ការមិនគោរពគោលការណ៍ពាណិជ្ជកម្ម មិនត្រូវយកមកអនុវត្តឡើយប្រសិនបើ ម្ចាស់បំណុលដែលមានកិច្ចធានា ធ្វើការជម្រះចោលទ្រព្យធានានោះនៅក្នុង កន្លែងផ្សេង ឬពេលវេលាពិសេសផ្សេង ហើយបានទទួលនូវតម្លៃដ៏ប្រសើរជាងការលក់ធម្មតា លើសពីនេះកូនបំណុលមិនអាចប្រឆាំងនឹងការលក់ ជួល ឬការជម្រះចោលទ្រព្យធានាខាងលើបានឡើយ។

[25] ដោយយោងតាមមាត្រា៥៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

ករណី ដែលម្ចាស់បំណុលដែលមានកិច្ចធានា មិនគោរពតាមលក្ខខណ្ឌតម្រូវនៃ បញ្ញត្តិស្តីពីការអនុវត្តដែលមានចែងក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា តុលាការអាចបង្គាប់ ឬហាមឃាត់ការជម្រះចោលទ្រព្យធានានោះ។ ការជម្រះចោលទ្រព្យអាចមានការឯកភាពពីតុលាការ ប៉ុន្តែការឯកភាពមិនមានភាពចាំបាច់ឡើយនៅក្នុងច្បាប់នេះ។

**ឧទាហរណ៍៖** កូនបំណុល A និងម្ចាស់បំណុល B បានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាប្រាតិភោគមួយដោយយក ក្របី ៥ ក្បាលដាក់ធានបំណុល ៤ លានរៀល ដោយកំណត់រយៈពេលដើម្បីសងបំណុលវិញ ៣ខែក្រោយ។ បន្ទាប់ពីរយៈពេល៣ខែក្រោយ កូនបំណុលមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះទេ ដែលជាហេតុនាំឱ្យម្ចាស់បំណុល B បានអនុវត្តសិទ្ធិរបស់ខ្លួនដោយធ្វើការដកហូតក្របីទាំង៥ក្បាលនោះ ដើម្បីយកមកគ្រប់គ្រងសម្រាប់ធ្វើការជម្រះចោលតាមបញ្ញត្តិនៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ សំនួរមួយបានចោទឡើងថា តើម្ចាស់បំណុល B ត្រូវធ្វើការជម្រះចោលរបៀបណាទើបសមស្របតាមគោលការណ៍ពាណិជ្ជកម្ម?

- **ការជម្រះចោលស្របតាមគោលការណ៍ពាណិជ្ជកម្ម**

ម្ចាស់បំណុលបានយកក្របីនោះ ទៅលក់នៅទីកន្លែងដែលជាប្រចាំខែ ឬសប្តាហ៍ តែងតែមានអ្នកទិញគោក្របី មកពីបណ្តាលខេត្ត ឬយកទៅលក់នៅកន្លែងសត្វឃាតនៅជិតតំបន់នោះ។ ហើយម្ចាស់បំណុលដែលមានកិច្ចធានា បានយល់ព្រមទទួលយកតាមតម្លៃទីផ្សារក្របីនោះនៅថ្ងៃលក់ដេញថ្លៃ។ បើទោះការលក់នោះបានតម្លៃទាបជាង ការលក់ដេញថ្លៃនៅមុនមួយសប្តាហ៍ ឬក្រោយមួយសប្តាហ៍ក្តី ម្ចាស់បំណុលនៅតែចាត់ទុកថាបានលក់ស្រមទៅតាមគោលការណ៍ពាណិជ្ជកម្ម ដោយសន្មត់តាមម្ចាស់បំណុលដែលមានកិច្ចធានានោះប្រព្រឹត្តិតាមរបៀបមួយស្របនឹងមនុស្សដទៃទៀតក្នុងអាជីវកម្ម ទិញលក់សត្វក្របី។

- **ការជម្រះចោលមិនស្របតាមគោលការណ៍ពាណិជ្ជកម្ម**

ការលក់ក្របី របស់ម្ចាស់បំណុលអាចមិនស្របតាមគោលការណ៍ពាណិជ្ជកម្មទេ បើម្ចាស់បំណុលដែលមានកិច្ចធានានោះ បានយកសត្វក្របីនោះមកដាក់ដេញថ្លៃយឺតពេល ដែលធ្វើឱ្យអ្នកទិញក្របីមិនអាចផ្តល់តម្លៃតបស្នងបានត្រឹមត្រូវ ឬប្រសិនបើក្របីនោះមិនត្រូវបានចិញ្ចឹមវាឱ្យបានត្រឹមត្រូវមុនពេលដាក់លក់ដេញថ្លៃ។ ករណីដែលម្ចាស់បំណុលបានយកក្របីនោះទៅលក់ខុសពីការបរិច្ឆេទដែលបានកំណត់ដេញថ្លៃក៏ត្រូវចាត់ទុកថាមិនគោរពតាមគោលការណ៍ពាណិជ្ជកម្មដែរ។

អ្វីដែលបានបង្ហាញនៅក្នុងជំពូកនេះ គ្រាន់តែជាសិទ្ធិក្នុងការអនុវត្តដែលបានផ្តល់ជូនតាមច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាតែប៉ុណ្ណោះ ហើយវាក៏មិនបានហាមឃាត់ភាគីឱ្យអនុវត្តសិទ្ធិតាមវិធីផ្សេងៗដោយសមស្រប ក្នុងការទទួលបានការសងពីកូនបំណុលរបស់ខ្លួន។ ជាក់ស្តែង

បើយើងពិចារណាទៅលើគោលបំណងជាក់លាក់ នៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា ប្រតិបត្តិការនេះបង្កើតដើម្បីគោលបំណងសេដ្ឋកិច្ច ហេតុនេះហើយវិវាទតាមផ្លូវបណ្ដឹងមិនគួរជាជម្រើសរវាងភាគីនោះទេ ព្រោះវាអាចនឹងខាតបង់ពេលវេលាច្រើនជាងការអនុវត្តដោយសង្ខេបបែបនេះ។

# សេចក្តីសន្និដ្ឋាន

ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានារបស់ប្រទេសកម្ពុជាដែលមាន៥៥ មាត្រា និង ៥ ជំពូកនេះ ត្រូវបានដកស្រង់ និងកែសម្រួលតាមប្រព័ន្ធច្បាប់ក្រមឯកភាពពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។ ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ជាច្បាប់ថ្មីមួយក្នុងបរិបទប្រទេសកម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍ តម្រូវទាមទារឱ្យមាននូវការពង្រឹងនូវប្រព័ន្ធគតិយុត្ត ដូចជាការកែប្រែច្បាប់ដែលមានស្រាប់ ការកែប្រែរចនាសម្ព័ន្ធច្បាប់ថ្មី និងការបង្កើតនូវវិធានគតិយុត្តិថ្មីៗ ដើម្បី ធ្វើការអភិវឌ្ឍប្រទេសដោយ ផ្តល់នូវទំនុកចិត្តដល់អ្នកវិនិយោគទុនជាតិ និងអន្តរជាតិ។ ជាក់ស្តែង ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដែលត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ ២០០៧ ក្នុងគោលដៅជំរុញភាពរឹងមាំនៃវិធាន ដែលគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម ពិសេសគឺវិស័យហិរញ្ញប្បទានដែលជួយសម្រួលដល់អ្នកវិនិយោគ ក្នុងការកាត់បន្ថយពេលវេលា ការចំណាយ និងជៀងវាងនីតិវិធីវែងឆ្ងាយ។

ច្បាប់នេះជាចលករក្នុងការជំរុញឱ្យមានការប្រើប្រាស់ចលនវត្ថុនៅក្នុងវិស័យប្រាតិភោគ ឱ្យបានច្រើនជាងមុន ក្រៅពីការធានាដោយបុគ្គល និងការធានាអចលនវត្ថុ។ ការប្រើប្រាស់ចលនវត្ថុនៅក្នុងវិស័យហិរញ្ញប្បទាននេះ បានជួយឱ្យអ្នកដែលត្រូវការដើមទុនក្នុងប្រើប្រាស់ជាបន្ទាន់មានភាពងាយស្រួល ប្រសិនបើពួកគេមិនមានអចលនវត្ថុក្នុងការធានា លើសពីនេះទៀតច្បាប់នេះបានជួយជំរុញដល់កំណើននៃប្រតិបត្តិការលក់រាយ ដោយកម្មវិធីស្វ័យប្រវត្តកម្មនៃការធ្វើសុក្រឹតកម្មដែលមានចែងនៅក្នុងច្បាប់នេះ។ ការអនុញ្ញាតដោយច្បាប់នេះកូនបំណុលអាចយកចលនវត្ថុ ទាំងរូបី (ដូចជា ទំនិញ កិច្ចសន្យាលក់ដែលមានកិច្ចធានាផលប័ត្រពាណិជ្ជកម្ម ឯកសារកម្មសិទ្ធិ លិខិតស្នាម និង រូបិយប័ណ្ណបរទេស) និងអរូបី (ដូចជា គណនី និង សិទ្ធិ) យកមកធ្វើជាកម្មវត្ថុនៃការធានាបាន។

ម្យ៉ាងទៀត ច្បាប់នេះក៏បានជួយសម្រួលដល់ការបង្កើតនូវកិច្ចសន្យាប្រាតិភោគ ដែលទាមទារត្រឹមត្រូវស្របតាមគោលការណ៍ស៊ីវិលដែលមានចែងនៅក្នុងក្រមសារធាតុ(ក្រមរដ្ឋប្បវេណី) ដូចជា លក្ខខណ្ឌសុពលភាព និងលក្ខខណ្ឌទម្រង់។ លក្ខខណ្ឌសុពលភាពក្នុងការបង្កើតកិច្ចព្រមព្រៀង គឺសំដៅទៅលើលក្ខខណ្ឌដែលជាមូលដ្ឋានក្នុងការបង្កើតអានុភាពនៃប្រតិបត្តិការនីមួយៗ។ លក្ខខណ្ឌមួយដែលសំខាន់សម្រាប់បង្កើតសុពលភាពនោះគឺសមត្ថភាពរបស់ភាគី។ សមត្ថភាពរបស់ភាគីតាមក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ត្រូវបានបែងចែកជាបីគឺសមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ និងសមត្ថភាពក្នុងការធ្វើសកម្មភាព។ សមត្ថភាពទាំងបីនេះនឹងត្រូវយកមកប្រើប្រាស់ដើម្បីវិនិច្ឆ័យនូវរាល់សកម្មភាព ដែលភាគីនឹងបំពេញនៅក្នុងការបង្កើតកិច្ចព្រម

ព្រៀងផងដូចជាការធ្វើសំណើ និងការផ្តល់ស្ទីការ ការបង្ហាញឆន្ទៈដោយគ្មានវិការៈ ឬមោឃភាពជាអាទិ៍។

លើសពីភាពងាយស្រួលក្នុងការប្រើប្រាស់កម្មវត្ថុ និងការបង្កើតកិច្ចសន្យា ច្បាប់នេះក៏បានបន្ថែមនូវគោលការណ៍សុវត្ថិភាពមួយបន្ថែមទៀត គឺគោលការណ៍សុក្រឹតកម្ម (លក្ខខណ្ឌតតាំង) ដើម្បីធានាដល់ម្ចាស់បំណុល ក្នុងការតតាំងជាមួយតតិយជនដែលជាម្ចាស់បំណុលផ្សេងទៀត ប្រសិនបើមានករណីជាន់សិទ្ធិកើតឡើង និង ដើម្បីធានាថាម្ចាស់បំណុលទទួលបាននូវអាទិភាពនៃការទទួលបានការសងមុនម្ចាស់បំណុលផ្សេងទៀត។ ម្ចាស់បំណុលត្រូវបានអនុញ្ញាតឱ្យធ្វើសុក្រឹតកម្មតាមរយៈបីរបៀប គឺការធ្វើសុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹងនៅការិយាល័យតម្កល់នៃក្រសួងពាណិជ្ជកម្ម ការធ្វើសុក្រឹតកម្មតាមរយៈការកាន់កាប់ និង ការធ្វើសុក្រឹតកម្មដោយស្វ័យប្រវត្ត។ ការតម្កល់លិខិតជូនដំណឹងនេះ អាចធ្វើទៅបាននៅការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ដែលមានមូលដ្ឋាននៅក្នុងក្រសួងពាណិជ្ជកម្ម ដោយយោងតាមមាត្រា ២៩ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា។ ចំនែកឯការកាន់កាប់គឺ សំដៅទៅលើការក្តាប់ទុកវត្ថុ ឬការគ្រប់គ្រងវត្ថុ តាមការជាក់ស្តែង ទោះដោយចំពោះក្តី ឬដោយប្រយោលក្តី។ ចុងក្រោយគឺការធ្វើសុក្រឹតកម្មដោយស្វ័យប្រវត្តិ ដែលមានន័យថាករណីដែលសិទ្ធិប្រាតិភោគមួយចំនួនត្រូវបានភ្ជាប់ទៅនឹងវត្ថុធានា នោះសុក្រឹតភាពនឹងកើតមានឡើងដោយឯកឯងទៅលើសិទ្ធិប្រាតិភោគនោះ ដោយមិនចាំបាច់មានសកម្មភាពអ្វីពីគូភាគីឡើយ។ ប៉ុន្តែការធ្វើសុក្រឹតកម្មទាំងបីរបៀបខាងលើ ម្ចាស់បំណុលអាចធ្វើទៅបានដោយយោងទៅតាមប្រភេទកម្មវត្ថុនៃកិច្ចសន្យាប្រាតិភោគ ដែលត្រូវបានភ្ជាប់មកក្នុងឧបសម្ព័ន្ធស្រាប់។

ដូចដែលបានបញ្ជាក់ជាការស្រេចរួចមកហើយ ច្បាប់នេះមានវិសាលភាពទៅលើប្រតិបត្តិការប្រាតិភោគ ដូច្នេះកម្មវត្ថុនៃកិច្ចសន្យាធានាបានផ្តល់សុវត្ថិភាពខ្ពស់ សម្រាប់ម្ចាស់បំណុលក្នុងការប្រមូលបំណុលរបស់ខ្លួនពីកូនបំណុលមកវិញករណីមិនអនុវត្តកាតព្វកិច្ច។ ប្រសិនបើកូនបំណុលមិនបានធ្វើការសងបំណុលមកម្ចាស់បំណុលវិញ ច្បាប់នេះបានផ្តល់សិទ្ធិឱ្យម្ចាស់បំណុលធ្វើការអនុវត្តទៅលើកម្មវត្ថុនៃកិច្ចសន្យានោះដោយខ្លួនឯង ដោយមិនចាំបាច់ពឹងពាក់លើប្រព័ន្ធតុលាការ ប៉ុន្តែក៏តម្រូវឱ្យម្ចាស់បំណុលគោរពនូវគោលការមួយចំនួន ដូចជា ការលក់ដោយគោរពតាមគោលការពាណិជ្ជកម្ម (តម្លៃទីផ្សារបច្ចុប្បន្ន) ការគោរពសិទ្ធិម្ចាស់បំណុលផ្សេងទៀតដែលបានជូនដំណឹងមកខ្លួន និងការបដិទាននូវលុយដែលនៅលស់ពីការអនុវត្តទៅកូនបំណុលវិញជាដើម។ មិនតែប៉ុណ្ណោះ ម្ចាស់បំណុលក៏អាចធ្វើការប្តឹងទៅតុលាការដើម្បីចេញសេចក្តីសម្រេចផ្សេងៗ ក្នុងករណី

ដែលកូនបំណុលមិនព្រមប្រគល់កម្មវត្ថុធានា មកឱ្យម្ចាស់បំណុលសម្រាប់ធ្វើការអនុវត្តស្របទៅតាមច្បាប់នេះ។

ជារួមមកច្បាប់នេះបានផ្តល់មកនូវអត្ថប្រយោជន៍ជាច្រើន ទាំងក្នុងវិស័យពាណិជ្ជកម្មទាំងមូល និងវិស័យផ្សេងទៀតដែលទទួលបានការជំរុញ ពីការប្រើប្រាស់ចលនវត្ថុក្នុងវិស័យប្រាតិភោគ។ លើសពីនេះទៀតសោត ច្បាប់នេះក៏បានជួយសម្រួលផងដែរទៅលើការពង្រីកវិសាលភាពនៃការប្រតិបត្តិការបញ្ចាំ បន្ថែមលើបញ្ញត្តិដែលមាននៅក្នុងក្រមរដ្ឋប្បវេណីស្តីពីការបញ្ចាំផងដែរ។ ទោះជាយ៉ាងនេះក៏ដោយ ច្បាប់នេះនៅតែមានចំណុចខ្វះខាតមួយចំនួនដែលទាមទារឱ្យមានការពិនិត្យពិច័យឱ្យបានច្បាស់លាស់ មុននឹងធ្វើការអនុវត្ត។ ជាក់ស្តែងច្បាប់នេះ ពោរពេញទៅដោយពាក្យពិបាកៗជាច្រើន ដែលមិនងាយស្រួលក្នុងការស្វែងយល់ពីអត្ថន័យដើមដែលនីតិនិពន្ធចង់បង្ហាញ បើទោះបីជាមានការពន្យល់ពាក្យគន្លឹះមួយចំនួនក្នុងមាត្រា៣ក៏ដោយ។ ថែមពីលើនេះប្រតិបត្តិការមួយចំនួននៅក្នុងច្បាប់នេះមិនបានពន្យល់ឱ្យបានក្បោះក្បាយនោះទេ ដោយសារការបកប្រែពីច្បាប់បរទេស ហើយក៏មិនមានអត្ថបទគតិយុត្តក្នុងស្រុកច្រើននោះទេ ដែលធ្វើការពន្យល់លើប្រតិបត្តិការនីមួយៗដែលមិនបានបញ្ជាក់ច្បាស់ក្នុងច្បាប់នេះ ដូច្នេះទាមទារឱ្យនិស្សិតខ្លួនឯងផ្ទាល់ត្រូវធ្វើការស្រាវជ្រាវពីប្រភពដើមនៃច្បាប់នេះដោយខ្លួនឯង។ ដោយហេតុថាច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា មិនបានបញ្ញត្តិពីនីតិវិធីនៃប្រតិបត្តិការមួយចំនួន ដែលទាមទារឱ្យមានការសម្របសម្រួលដោយច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី) ដោយផ្អែកតាមការអនុញ្ញាតដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ ត្រង់ជំពូកទី៦។

តាមរយៈការសិក្សាស្រាវជ្រាវរយៈពេលជាង ៣ខែមកនេះយើងខ្ញុំ បានទទួលបាននូវចំណេះដឹងជាច្រើនពីច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានានេះ ដែលរួមមានកាលប្បវត្តិ ការវិវត្ត ការប្រើប្រាស់ជាដើម ប៉ុន្តែទន្ទឹមនឹងការទទួលបាននេះ យើងខ្ញុំទាំងពីរនាក់ក៏បានជួបប្រទះនូវការលំបាកមួយចំនួនផងដែរ ដែលក្នុងនោះមានដូចជា៖

- ការខ្វះខាតទៅលើឯកសារស្រាវជ្រាវ ដោយហេតុថា ច្បាប់នេះមិនសូវជាត្រូវបានអនុវត្តទូលំទូលាយដូចក្រមរដ្ឋប្បវេណីនោះទេ ដែលប្រតិបត្តិការភាគច្រើនអនុវត្តតែនៅក្នុងការិយាល័យច្បាប់មួយចំនួនតែប៉ុណ្ណោះ ម្យ៉ាងទៀតឯកសារទាំងនោះយើងមិនអាចធ្វើការដកយកមកធ្វើការសិក្សាជាសាធារណៈបាននោះទេ ព្រោះថាវាអាចប៉ះពាល់ដល់សិទ្ធិឯកជនរបស់អតិថិជនរបស់ការិយាល័យគេ។

- ការខ្វះខាតគ្រឹះចំណេះដឹង ពីសាកលវិទ្យាល័យដោយហេតុថា ច្បាប់នេះមិនត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សានោះទេ ដូច្នេះអ្វីៗទាំងអស់ដែលមាននៅក្នុងច្បាប់នេះគឺជាភាពថ្មីស្រឡាងសម្រាប់ពួកយើង។
- ការពិបាកស្វែងយល់ពីប្រតិបត្តិការ ដែលត្រូវបានបញ្ញត្តិនៅក្នុងច្បាប់នេះ ដោយហេតុថា ប្រតិបត្តិការមួយចំនួនមិនទាន់មាន ឬកម្រនឹងមាននៅក្នុងប្រទេសយើង ដូច្នេះហើយ ទាមទារឱ្យពួកយើងត្រូវធ្វើការជ្រាវជ្រាវបន្ថែមជាភាសាបរទេសជាផង។

# អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវ ក្នុងមួយរយៈពេលកន្លងមក ទៅលើប្រធានបទស្តីអំពី ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដោយរួមមានការបង្កើត ការវិវត្តន៍ និងការអនុវត្តរបស់ច្បាប់នេះនៅក្នុងប្រទេសកម្ពុជារួចមក ពួកយើងខ្ញុំទាំងពីរនាក់បានប្រទះឃើញនូវចំណុចអសកម្មមួយចំនួននៅក្នុងច្បាប់នេះ ឬយើងអាចហៅម្យ៉ាងទៀតថា ជាចំណុចខ្វះខាត។

ចំណុចទីមួយដែលពួកយើងខ្ញុំយល់ឃើញថាជាចន្លោះខ្វះខាតនោះ គឺទាក់ទងទៅនឹងការប្រើប្រាស់ពាក្យនោះក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ដោយហេតុថា ច្បាប់នេះត្រូវបានចំលងចេញពីច្បាប់របស់អាហរដ្ឋអាមេរិច ដោយចែងក្នុងក្រមឯកភាពពាណិជ្ជកម្ម **(THE UNIFORM COMMERCAIL CODE)** ត្រង់មាត្រា៩ ដោយធ្វើការយកមកកែសម្រួលជាថ្មីជាភាសាខ្មែរ ដោយត្រូវបានអនុម័តដោយសភា នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ ២០០៧ និងមានការយល់ស្របពីព្រឹទ្ធសភា នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ ហើយជាចុងក្រោយត្រូវបានប្រកាសឱ្យប្រើនៅប្រទេសកម្ពុជាដោយព្រះមហាក្សត្រនៅក្នុងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧។ ដូច្នេះហើយរាល់ការប្រើប្រាស់ពាក្យពេចន៍ដែលបានបកចេញពីក្រមរបស់សហរដ្ឋអាមេរិចនោះមានការពិបាកក្នុងការសិក្សាស្វែងយល់ ជាពិសេសគឺពាក្យបច្ចេកទេសមួយចំនួនត្រូវបាន ប្រើប្រាស់ខុសពីន័យធម្មតាដែលយើងធ្លាប់ជួបប្រទះ។ ដោយយោងតាមគោលដៅ ច្បាប់នេះមានវិសាលភាពទៅលើការវិស័យប្រាតិភោគចលនវត្ថុ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីស្រាប់ ប៉ុន្តែបើយើងធ្វើការប្រៀបធៀបពាក្យពេចន៍ដែលបានប្រើប្រាស់នៅក្នុងច្បាប់ទាំងពីរនេះ យើងសង្កេតឃើញថា មានភាពខុសគ្នាស្ទើតែមិនអាចកាត់ន័យបានងាយនោះទេ ប្រសិនបើគ្មានការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅជាមុន ជាក់ស្តែង ពាក្យថា **លក្ខខណ្ឌតតាំង** នៅក្នុង (ក្រមរដ្ឋប្បវេណី) ត្រូវបានជំនួសដោយពាក្យ **សុក្រឹតកម្ម** នៅក្នុង (ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា) និង ពាក្យថា **សិទ្ធិលើបំណុល** នៅក្នុង (ក្រមរដ្ឋប្បវេណី) ត្រូវបានប្រើប្រាស់ពាក្យថា **គណនី** នៅក្នុង (ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា) ទៅវិញ ហើយនៅមានពាក្យជាច្រើនទៀតដែលលក្ខណៈដូចខាងលើ។ ការប្រើប្រាស់បែបពាក្យនេះមិនត្រឹមតែមានភាពពិបាកចំពោះ មនុស្សធម្មតា ដែលមិនដែលមានជំនាញផ្នែកច្បាប់នោះទេ តែក៏មានផលប៉ះពាល់ចំពោះ អ្នកដែលកំពុងសិក្សាស្រាវជ្រាវទៅលើច្បាប់នេះផងដែរ ដោយតម្រូវឱ្យមានការចំណាយពេលច្រើនជាងការសិក្សាច្បាប់ផ្សេងទៀត ដូចជាក្រមរដ្ឋប្បវេណីជាដើម។

ចំពោះដំណោះស្រាយនៅក្នុងបញ្ហាខ្វះចន្លោះនៅក្នុងចំណុចទីមួយ ដែលទាក់ទងទៅនឹងការបម្រើបម្រាស់ពាក្យនេះ ពួកយើងខ្ញុំយល់ឃើញថា សាស្ត្រាចារ្យ និស្សិត និងអ្នកដែលមានបំណងស្រាវជ្រាវលើច្បាប់នេះ គួរធ្វើការស្វែងយល់ពីអត្ថន័យនៃពាក្យនីមួយៗ នៅក្នុងច្បាប់នេះជាមុនសិន

មុននឹងធ្វើការសិក្សាទៅលើលក្ខខណ្ឌដទៃទៀត ដោយការសិក្សាពាក្យនេះយើងអាចធ្វើទៅបាន ពីការឱ្យនិយមន័យនៅក្នុងមាត្រា៣ នៃច្បាប់នេះផ្ទាល់ ឬយើងអាចធ្វើការសិក្សាច្បាប់នេះជាភាសាបរទេសក៏បាន ព្រោះវាអាចជួយឱ្យមានភាពងាយស្រួលយល់ជាង ការណ៍ដែលត្រូវយកមកបកប្រែជាខេមរភាសា។

ចំណែកឯចំណុចខ្វះចន្លោះមួយទៀតគឺ ភាពមិនស៊ីចង្វាក់គ្នារវាងច្បាប់សារធាតុ (ក្រមរដ្ឋប្បវេណី) និង ច្បាប់ពិសេស (ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា)។ បើទោះបីជាការច្បាប់ទាំងពីរត្រូវបានបង្កើតឡើងក្នុងឆ្នាំដូចគ្នា (ឆ្នាំ២០០៧) ក៏ពិតមែន ប៉ុន្តែមិនមែនច្បាប់សារធាតុត្រូវបានបង្កើតឡើងមុននោះទេ ផ្ទុយទៅវិញច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាដែលជាច្បាប់ពិសេស ត្រូវបានបង្កើតឡើងមុនប៉ុន្មានខែទៅវិញ ដែលធ្វើឱ្យអត្ថន័យនៃច្បាប់ទាំងពីរនេះមានភាពមិនចុះសម្រុងគ្នាមួយចំនួន ម្យ៉ាងទៀត ច្បាប់ទាំងពីរត្រូវបានយកចេញពីប្រព័ន្ធពីរផ្សេងគ្នាថែមទៀតផងគឺ ប្រព័ន្ធច្បាប់ Common Law (ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា) និង ប្រព័ន្ធច្បាប់ Civil Law (ក្រមរដ្ឋប្បវេណី) ហើយមានបញ្ញត្តិដែលមានវិសាលភាពលើប្រតិបត្តិការប្រាតិភោគដូចគ្នាផងដែរ។ ដូច្នេះធ្វើឱ្យច្បាប់ទាំងពីរ រឹតតែមានគម្លាតពីគ្នាមួយកម្រិតថែមទៀត។ ឧទាហរណ៍ បញ្ញត្តិស្តីពីការបញ្ចាំចលនវត្ថុនៅក្នុងក្រមរដ្ឋប្បវេណី ទាមទារឱ្យភាគីអ្នកទទួលបញ្ចាំធ្វើការកាន់កាប់វត្ថុបញ្ចាំដើម្បីទទួលបានលក្ខខណ្ឌតតាំង ដោយឡែកនៅក្នុងច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាវិញដើម្បីទទួលបានលក្ខខណ្ឌតតាំង អនុញ្ញាតឱ្យម្ចាស់បំណុលអាចធ្វើបានបីរបៀប គឺ សុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹង សុក្រឹតកម្មដោយការកាន់កាប់ និង សុក្រឹតកម្មដោយស្វ័យប្រវត្តិ។

សម្រាប់ដំណោះស្រាយលើបញ្ហាខ្វះចន្លោះខាងលើ ពួកយើងខ្ញុំទាំងគ្នានអ្វីក្រៅពីសំណូមពរឱ្យសិស្ស និស្សិត អ្នកស្រាវជ្រាវ ធ្វើការសិក្សាស្វែងយល់ពីច្បាប់ទាំងពីរឱ្យបានច្បាស់ជាមុនសិនដើម្បីអាចធ្វើការកំណត់សម្គាល់ទៅលើវិធានដែលមានភាពផ្ទុយគ្នា និងដូចគ្នារវាងច្បាប់ទាំងពីរព្រមទាំងទាមទាមឱ្យគ្រប់ភាគី ត្រូវកំណត់ជាមុនថា ប្រតិបត្តិការនៅក្នុងដៃរបស់ខ្លួនត្រូវបានបង្កើតឡើងដោយយោងតាមច្បាប់មួយណាឱ្យប្រាកដ ដើម្បីងាយស្រួលយកវិធានមកដោះស្រាយ៕

# គន្ថនិទ្ទេស

## I. បទដ្ឋានគតិយុត្តជាតិ

### ច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧
- ច្បាប់ស្ដីពីប្រតិបត្តិការដែលមានកិច្ចធានា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៧/០១២ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៧
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/００៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១

### អនុក្រឹត្យ

- អនុក្រឹត្យលេខ ១៣១ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

### សេចក្ដីជូនដំណឹង

- សេចក្ដីជូនដំណឹងលេខ ៣០៥៨ ព ណនតក ចុះថ្ងៃទី២៧.ខែធ្នូ ឆ្នាំ២០០៧ របស់ក្រសួងពាណិជ្ជកម្ម ស្ដីពីការតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងការស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិច

## II. បទដ្ឋានគតិយុត្តអន្តរជាតិ

- UNCITRAL Model Law on Secured Transactions
- Uniform Commercial Code of United States, Article 9

## III. ឯកសារពិគ្រោះជាខេមរភាសា


- ក្រសួងពាណិជ្ជកម្ម ,*ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងជំនួយសម្រាប់ពាណិជ្ជកម្មនៅប្រទេសកម្ពុជា*២០១១ ,ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម ,
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មាការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* ,ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៧

- ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី ភាគទី២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ* , ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩
- ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១ ភាគ២*, ភ្នំពេញ៖ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ២០១៣
- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី១ គន្ថី១ដល់គន្ថី៣*, ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩
- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី២ គន្ថី៤*, ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០០៩
- គណៈកម្មាការទទួលបន្ទុកកិច្ចការផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីកម្ពុជា និងក្រុមការងារជប៉ុនទទួលបន្ទុករៀបចំសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី* , ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ២០១១
- ធនាគារអភិវឌ្ឍអាស៊ី (Asia Development Bank, ADB), *សៀវភៅស្តីពី "ការពន្យល់និងឧទាហរណ៍នៃប្រតិបត្តិការដែលមានកិច្ចធានា"* ,ឯកសារបណ្តុះបណ្តាល, ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម
- ណូមីរ៉ា តូយ៉ូហ៊ីរ៉ូ, *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី,* ភ្នំពេញ៖ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន, ២០១៤


## IV. ឯកសារពិគ្រោះជាភាសាបរទេស


- Council for the Development of Cambodia, *Cambodia Investment Guidebook*, Council for the Development of Cambodia, 2013
- E Walde Warner Jr and Gavin R Skene, *Project Finance: In 45 jurisdictions worldwide*, London: Encompass Print Solutions, 2011

- Independent Evaluation Department, *Cambodia: First Financial Sector Program Loan Cluster),* Performance Evaluation, Asian Development Bank, 2009
- J. Michael Goodson, *Uniform Commercial Code (UCC) Research Guide*, Duke University School of Law: Law Library, 2016
- National Conference of Commissioners on Uniform State Laws, *Amendments to Uniform Commercial Code Article 9*, The American Law Institute and National Conference of Commissioners on Uniform State Laws, 2010
- Rabat, *Secured Transactions and Collateral Registries: A Global Perspective*, Morocco, 2014
- Susan L, Green, *Guide to the Law on Secured Transactions (Cambodia) 2007*, Phnom Penh, 2014
- William H. Lawrence, William H. Henning and R. Wilson Freyermuth, *Understanding Secured Transactions*, Fourth Edition, LexisNexis Law School Publishing, 2007
- World Bank, *Secured Transactions and Collateral Registries*, Washington: International France Cooperation, 2010


## V. គេហទំព័រ


- http://www.setfo.gov.kh/dtn_str/search/searchpublic
- http://www.uncitral.org/uncitral/en/about_us.html
- https://www.justia.com/business-operations/docs/secured-transactions.html
- http://www.rizzolawfirm.com/Business-and-Commercial-Law_PC/Secured Transactions-2-Business-and-Commercial-Law_PC.shtml
- https://www.cisg.law.pace.edu/cisg/text/commentary2.html
- https://www.adb.org/documents/cambodia-first-financial-sector-program-loan-cluster-loans-1859-cam-1951-cam-and-2185-cam

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ ១** ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

**ឧបសម្ព័ន្ធ ២** តារាងពាក្យគន្លឹះ

**ឧបសម្ព័ន្ធ ៣** លំហូរនីតិវិធីនៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា

**ឧបសម្ព័ន្ធ ៤** តារាងនៃប្រតិបត្តិការដែលត្រូវធ្វើសុក្រឹតកម្ម

**ឧបសម្ព័ន្ធ ៥** តារាងតម្លៃសេវាពាក់ព័ន្ធនឹងការតម្កល់លិខិតជូនដំណឹង

**ឧបសម្ព័ន្ធ ៦** គម្រូលិខិតជូនដំណឹង

**ឧបសម្ព័ន្ធ ៧** គម្រូលិខិតសុំបញ្ចប់លិខិតជូនដំណឹង

**ឧបសម្ព័ន្ធ ៨** អាសយដ្ឋានទំនាក់ទំនងការិយាល័យតម្កល់លិខិតជូនដំណឹង

# ឧបសម្ព័ន្ធ ១
# ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

# ព្រះរាជក្រម

នស/រកម/០៥០៧/០១២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ប្រតិបត្តិការដែលមានកិច្ចធានា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៦ ខែ មេសា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

១-ច្បាប់នេះមានគោលបំណងលើកស្ទួយសកម្មភាពសេដ្ឋកិច្ច តាមរយៈវិធានរួមស្តីពីការប្រើប្រាស់ទ្រព្យធានា ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ដើម្បីធានាកាតព្វកិច្ច ។

២-ក្នុងករណីមានភាពផ្ទុយគ្នា រវាងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទប្បញ្ញត្តិនៃច្បាប់ដទៃទៀត ច្បាប់នេះត្រូវចាត់ទុកជាបញ្ញត្តិគោល លើកលែងតែច្បាប់ផ្សេងនោះចែងយោងជាក់លាក់ ឬធ្វើវិសោធនកម្មលើបទប្បញ្ញត្តិ ដែលផ្ទុយនឹងច្បាប់នេះ ។

ចំពោះបញ្ញត្តិដែលពុំមានចែងក្នុងច្បាប់នេះទេ ត្រូវអនុវត្តតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

១-ច្បាប់នេះអនុវត្តចំពោះ :

ក-រាល់ប្រតិបត្តិការដែលមានអានុភាពលើការធានាកាតព្វកិច្ចដោយទ្រព្យធានា ដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ រួមមានការបញ្ចាំចលនវត្ថុ ការផ្ទេរកម្មសិទ្ធិ បញ្ញើទុកលក់ អនុប្បទានសិទ្ធិជាដើម ។

ខ-ការលក់គណនី និងកិច្ចសន្យាលក់ដែលមានកិច្ចធានា ។

គ-ការជួលទំនិញសម្រាប់រយៈពេលលើសពីមួយឆ្នាំ ។

២-ការអនុវត្តន៍ចំពោះប្រតិបត្តិការ ដែលបានកំណត់ក្នុងចំណុចទី ១ ដោយមិនគិតពីទម្រង់ ឬពាក្យពេចន៍ ដែលប្រើក្នុងកិច្ចព្រមព្រៀងឡើយ ហើយទោះបីជាសិទ្ធិលើកម្មសិទ្ធិត្រូវបានកាន់កាប់ដោយម្ចាស់បំណុលដែលមានកិច្ចធានា ឬកូនបំណុលក៏ដោយ ។

៣-ច្បាប់ទាំងឡាយដែលចែងពីសមត្ថភាពចុះកិច្ចសន្យា ដូចជាច្បាប់ស្តីពីទីភ្នាក់ងារ ការឆបោក ការបង្ខិតបង្ខំ ការភ័ន្តច្រឡំនិងធនក្ស័យ ត្រូវបំពេញបន្ថែមលើច្បាប់នេះ ។

៤-ថ្វីបើមានចែងក្នុងចំណុចទី ១ និងចំណុចទី ២ នៃមាត្រានេះក្តី ច្បាប់នេះមិនអនុវត្ត

ROYAUME DU CAMBODGE
ចំពោះ :
MINISTRE DU PALAIS ROYAL

ក-ការផ្ទេរសិទ្ធិទាមទារប្រាក់បៀវត្សរបស់និយោជិត ។

ខ-ការលក់គណនី ឬកិច្ចសន្យាលក់ ដែលមានកិច្ចធានាដែលជាផ្នែកនៃការលក់អាជីវកម្មរួមទាំងគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានានេះ ។

គ-អនុប្បទានគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាមដែលសម្រាប់តែគោលបំណងប្រមូលប្រាក់ដែលជំពាក់ ។

ឃ-ការផ្ទេរសិទ្ធិទទួលប្រាក់តាមកិច្ចសន្យាទៅអនុប្បទានិក ដែលមានកាតព្វកិច្ចអនុវត្តកិច្ចសន្យា ។

ង-ការប្រាក់លើប្រាក់បញ្ញើ គណនីមូលប្បទានប័ត្រ គណនីសញ្ជ័យ សៀវភៅធនាគារ ឬគណនីសាច់ប្រាក់ដទៃទៀត លើកលែងតែផលនៃទ្រព្យធានា ។

**មាត្រា ៣.-**

នៅក្នុងច្បាប់នេះពាក្យបច្ចេកទេសទាំងឡាយ ត្រូវមានន័យដូចកំណត់ខាងក្រោម :

១-"កសិផល" មានន័យថា ទំនិញរបស់កូនបំណុល ដែលបានពីមុខរបរកសិកម្ម លើកលែងតែឈើឈរ ។ កសិផលរួមមាន :

ក-ផលដំណាំដែលដាំដុះ កំពុងដុះលូតលាស់ ឬ ផលដំណាំដែលត្រូវដាំដុះ

ខ-ទំនិញផលផលដែលផលិតក្នុងប្រតិបត្តិការវារីវប្បកម្ម

គ-សត្វចិញ្ចឹមគ្រប់ប្រភេទ រាប់ទាំងកូនសត្វដែលកើតហើយ ឬ មិនទាន់កើតផងដែរ

ឃ-ទំនិញផ្គត់ផ្គង់ដែលប្រើ ឬផលិតក្នុងប្រតិបត្តិការកសិកម្ម

ង-ផលដំណាំដែលប្រមូលបាន ឬ ផលដែលបានមកពីសត្វចិញ្ចឹមគ្រប់ប្រភេទ ហើយមិនទាន់កែច្នៃ ។

២-"ការជួលទំនិញសម្រាប់រយៈពេលលើសពីមួយ(០១)ឆ្នាំ" មានន័យថា :

ក-ការជួលទំនិញដែលកំណត់រយៈពេលលើសពីមួយ(០១)ឆ្នាំ ។

ខ-ការជួលទំនិញដែលគ្មានកំណត់រយៈពេល ទោះបីជារយៈពេលនេះអាចត្រូវបានកំណត់ថាតិចជាងមួយឆ្នាំក៏ដោយ ។

គ-ការជួលទំនិញដែលកំណត់រយៈពេលដំបូងមួយឆ្នាំ ឬតិចជាងមួយឆ្នាំ បើអ្នកជួលបន្តកាន់កាប់ទំនិញដោយបានការឯកភាពពីអ្នកជួលឱ្យនិងគ្មានការអាក់ខាន ឬ គ្មានការអាក់ខានជាសារវន្ត ក្នុងរយៈពេលមួយ(០១)ឆ្នាំ បន្ទាប់ពីអ្នកជួលបានទទួលចលនវត្ថុនោះមក ប៉ុន្តែកិច្ចសន្យាជួលនេះ មិនក្លាយទៅជាមានរយៈពេលមួយ(០១)ឆ្នាំទេ លើកលែងតែអ្នកជួលបន្តការកាន់កាប់លើសពីមួយ(០១)ឆ្នាំ

ឃ-ការជួលទំនិញដែលកំណត់រយៈពេលមួយ(០១)ឆ្នាំ ឬ តិចជាងមួយ(០១)ឆ្នាំ កាលណាកិច្ចសន្យាជួលចែងថា អាចបន្តរយៈពេលលើសពីមួយ(០១)ឆ្នាំ ។

៣-"ការទិញ" ការទទួលបានវត្ថុក្នុងឋានៈជាអ្នកទិញ រាប់បញ្ចូលទាំងអ្នកទទួលអំណោយ អ្នកទទួលទ្រព្យធានា ម្ចាស់បំណុលដែលមានកិច្ចធានា ឬ ម្ចាស់បំណុលអ៊ីប៉ូតែក ឬ តាមប្រតិបត្តិការដោយស្ម័គ្រចិត្តដែលបង្កើតសិទ្ធិលើទ្រព្យ ។ បុគ្គលដែលទទួលបានចលនវត្ថុដោយការទិញហៅថា "អ្នកទិញ" ។

៤-"បញ្ជាក់ការឯកភាព" មានន័យថា ការចុះហត្ថលេខា ឬ ការឯកភាពលើឈ្មោះ ឬ និមិ្មតសញ្ញាផ្សេងៗ ដែលធ្វើឡើងដោយផ្ទាល់ដៃ ឬ តាមវិធីផ្សេងៗ ហើយមានគោលបំណងបញ្ជាក់ពីអត្តសញ្ញាណរបស់ភាគីដែលឯកភាព ឬ ផ្តល់ការឯកភាព ឬ បញ្ជាក់ឱ្យកំណត់ត្រាមានតម្លៃតាមច្បាប់ ។

៥-"កិច្ចធានា" គឺជាកាតព្វកិច្ចគាំទ្រ ជាអាទិ៍មានកាតព្វកិច្ចបង់ប្រាក់ ឬកាតព្វកិច្ចបង់ប្រាក់របស់អ្នកចេញលិខិតឥណទាន និងដែលគាំទ្រការបង់ប្រាក់ ឬការបំពេញកាតព្វកិច្ចលើកណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬ ទ្រព្យអរូបីផងទៃទៀត ។

៦-"កិច្ចសន្យាលក់ដែលមានកិច្ចធានា" មានន័យថា កំណត់ត្រាដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិប្រាតិភោគលើទំនិញ ឬ ការជួលទំនិញ ។

៧-"កិច្ចព្រមព្រៀងប្រាតិភោគ" គឺជាកិច្ចព្រមព្រៀងដែលបង្កើត ឬ ចែងពីសិទ្ធិប្រាតិភោគ ។

៨-"កូនបំណុល" មានន័យថា បុគ្គលដែលជំពាក់ប្រាក់ ឬកាតព្វកិច្ច ទោះបុគ្គលនោះជាកម្មសិទ្ធិករ ឬបុគ្គលដែលមានសិទ្ធិលើទ្រព្យធានាក៏ដោយ និងរាប់បញ្ចូលទាំងអ្នក

លក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកទទួលទំនិញទុកលក់ អ្នកជួលចលនវត្ថុតាមកិច្ចសន្យាជួលដែលកំណត់ក្នុងច្បាប់នេះ ។

៩-"កូនបំណុលគណនី" មានន័យថា បុគ្គលដែលជំពាក់កាតព្វកិច្ចក្នុងគណនី ក្នុងកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ ទ្រព្យអរូបីដទៃទៀត ។

១០-"កំណត់ត្រា" គឺជាព័ត៌មានដែលកត់ត្រាតាមមធ្យោបាយទាក់ទងរូបី ឬ ព័ត៌មានដែលរក្សាទុកក្នុងប្រព័ន្ធអេឡិចត្រូនិក ឬ មធ្យោបាយទាក់ទងផ្សេងទៀត និងអាចយកមកប្រើបានក្នុងទម្រង់ដែលអាចយល់ ឬដឹងខ្លឹមសារបាន ។ លិខិតជូនដំណឹងវិសោធនកម្ម លិខិតស៊ុំបន្ត ឬ លិខិតស៊ុំបញ្ឈប់ត្រូវចាត់ទុកជាកំណត់ត្រា បើបានប្រគល់ជូនការិយាល័យតម្កល់តាមមធ្យោបាយដែលការិយាល័យតម្កល់បានកំណត់ ។

១១-"គណនី" គឺជាសិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានលក់ ឬ បានជួល ឬ ថ្លៃសេវាកម្មដែលមិនមែនជាលិខិតស្នាម ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ។

១២-"គាហកនៃសិទ្ធិឃាត់ទុក" មានន័យថា :

ក-បុគ្គលដែលទទួលបានសិទ្ធិ លើទ្រព្យធានារបស់ម្ចាស់បំណុលមានកិច្ចធានា ឬ មានសិទ្ធិរឹបអូសទ្រព្យធានារបស់ម្ចាស់បំណុល ដែលមានកិច្ចធានាតាមវិធីប្តឹងទៅមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដូចជាមន្ត្រីតុលាការ អភិបាល ឬ អភិបាលបណ្តោះអាសន្នក្នុងរឿងក្តីក្ស័យធនជាដើម ។

ខ-បុគ្គលដែលមានឯកសិទ្ធិទូទៅ ឬ ឯកសិទ្ធិលើចលនវត្ថុពិសេសតាមច្បាប់ផ្សេងទៀត ។

១៣-"ចលនវត្ថុតាំងភ្ជាប់" គឺជាទំនិញដែលបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬ មានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុ តាមរបៀបមួយដែលនាំឱ្យមានសិទ្ធិប្រស៊ីក្យកើតឡើងតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

១៤-"តម្លៃ" មានន័យថាតម្លៃដែលបានផ្តល់សម្រាប់សិទ្ធិក្នុងករណីដែលបុគ្គលបានទទួលសិទ្ធិ :

ក-ជាថ្នូរនឹងការសន្យាមានសុពលភាពក្នុងការផ្តល់ឥណទាន ទោះបីជាការសន្យាដែលអាចដកវិញបាន ឬ មិនអាចដកវិញបានក៏ដោយ ។

÷

ខ-ជាទ្រព្យធានា ឬ ការទូទាត់ទាំងស្រុង ឬ មួយភាគចំពោះការទាមទារពីមុន ។

គ-ដោយការទទួលការប្រគល់ អនុលោមតាមកិច្ចសន្យាទិញដែលមានស្រាប់ ។

ឃ-ជាថ្នូរនឹងអ្វីដែលត្រូវបានផ្ដល់ក្នុងការដោះដូរ ឬជាថ្នូរនឹងការសន្យា។

១៥-"ទំនិញ" គឺជាវត្ថុដែលជាចលនវត្ថុក្នុងពេលដែលសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងវត្ថុនេះ ។ ក្នុងនេះពាក្យថា ទំនិញសំដៅដល់ផលិតផលរ៉ែ ដែលត្រូវភ្ជាប់សិទ្ធិប្រាតិភោគនៅពេលជីកបាន ឈើឈរដែលបំរុងនឹងកាប់ កូនសត្វចិញ្ចឹមគ្រប់ប្រភេទមិនទាន់កើតនិងផលដំណាំដែលបានដាំដុះ កំពុងលូតលាស់ ឬដែលត្រូវដាំដុះ រាប់បញ្ចូលទាំងផលដំណាំនៅជាប់នឹងដើម ប្រេង ជ័រ ឬរុក្ខជាតិផងដែរ ។ ពាក្យថា ទំនិញនេះមិនរាប់បញ្ចូលនូវគណនីកិច្ចសន្យាលក់ដែលមានកិច្ចធានា រូបិយវត្ថុ ឯកសារ ឬ លិខិតស្នាមឡើយ ។

១៦-"ទំនិញប្រើប្រាស់" គឺទំនិញដែលបានប្រើប្រាស់ ឬទិញសម្រាប់ប្រើប្រាស់ជាចម្បងសម្រាប់គោលបំណងផ្ទាល់ខ្លួន សមាជិកគ្រួសារ ឬសម្រាប់គោលបំណងគ្រួសារ ទំនិញទាំងនេះ មិនអាចជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគបានទេ លើកលែងតែយានយន្តមានលេខស៊េរី ។

១៧-"ទំនិញបញ្ចូលគ្នា" មានន័យថាទំនិញដែលបានលាយបញ្ចូលជាមួយទំនិញផ្សេងតាមរបៀបមួយដែលអត្តសញ្ញាណនៃទំនិញនេះត្រូវបាត់បង់និងចូលក្នុងទំនិញថ្មី ឬក្នុងសមាសធាតុរួម ។

១៨-"ទ្រព្យអរូបីផ្សេងទៀត" មានន័យថារាល់ចលនវត្ថុ ឬសិទ្ធិដែលក្រៅពីទំនិញ គណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម និងរូបិយវត្ថុ ។

១៩-"បញ្ញើទុកលក់" គឺជាប្រតិបត្តិការដែលបុគ្គលម្នាក់(អ្នកផ្ញើទំនិញទុកលក់) ប្រគល់ទំនិញឱ្យទៅពាណិជ្ជករ(អ្នកទទួលទំនិញទុកលក់) ដើម្បីលក់ដោយមិនគិតពីទម្រង់នៃកិច្ចសន្យា ឬពាក្យពេចន៍ដែលប្រើក្នុងកិច្ចសន្យាហើយ :

ក-ពាណិជ្ជករទិញនិងលក់ទំនិញប្រភេទនេះ ប្រើឈ្មោះផ្សេងពីឈ្មោះអ្នកផ្ញើទំនិញទុកលក់ ។

ខ-ពាណិជ្ជករមិនមែនជាអ្នកលក់ដេញថ្លៃ ។

គ-ទំនិញមិនមែនជាទំនិញប្រើប្រាស់ មុនពេលប្រគល់ឱ្យទៅពាណិជ្ជករ ។

ឃ-ប្រតិបត្តិការនេះមិនបង្កើតសិទ្ធិប្រាតិភោគ ដែលធានាកាតព្វកិច្ចនោះទេ ។

២០-“បុគ្គល” មានន័យថារូបវន្តបុគ្គល ឬនីតិបុគ្គលដែលច្បាប់កម្ពុជាទទួលស្គាល់ ។

២១-“អ្នកទិញក្នុងអាជីវកម្មធម្មតា” មានន័យថា បុគ្គលដែលទិញទំនិញពីបុគ្គលដែលប្រកបអាជីវកម្មលក់ទំនិញ ក្នុងប្រភេទទំនិញដែលបានទិញ បើអ្នកទិញបានទិញដោយសុចរិត ហើយមិនបានដឹងថាការលក់នេះបំពានលើសិទ្ធិរបស់បុគ្គលផ្សេងទេ ។

២២-“ផលនៃទ្រព្យធានា” មានន័យថា អ្វីដែលទទួលបាននៅពេលលក់ ជួល ឬផ្តល់អាជ្ញាប័ណ្ណ ដោះដូរ ឬការជម្រះចោលទ្រព្យធានាតាមវិធីផ្សេងពីនេះ ។ គឺអ្វីៗដែលប្រមូលបានពីទ្រព្យធានា អ្វីៗត្រូវបានបែងចែកពីទ្រព្យធានា ដូចជាសិទ្ធិដែលផុសចេញពីទ្រព្យធានា បណ្តឹងទាមទារដែលកើតចេញពីការខាតបង់ ការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានា ទៅតាមកំរិតតម្លៃនៃទ្រព្យធានា ថ្លៃធានារ៉ាប់រងដែលត្រូវសងដោយសារការខាតបង់ ឬ ការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានា ទៅតាមកំរិតតម្លៃទ្រព្យធានា និងតាមកំរិតដែលត្រូវចេញសងកូនបំណុល ឬម្ចាស់បំណុលដែលមានកិច្ចធានា ។ “ផលជារូបិយវត្ថុ” មានន័យថា ផលជាសាច់ប្រាក់ មូលប្បទានប័ត្រ មូលនិធិដែលផ្ញើក្នុងធនាគារ និងផលនៃទ្រព្យធានា ដែលមានលក្ខណៈដូចគ្នានេះ ។

២៣-“ម្ចាស់បំណុលដែលមានកិច្ចធានា” មានន័យថា អ្នកឱ្យខ្ចី អ្នកលក់ ឬបុគ្គលដែលទទួលសិទ្ធិប្រាតិភោគ តាមកិច្ចសន្យាប្រាតិភោគ រាប់បញ្ចូលទាំងបុគ្គលដែលបានទិញគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកផ្ញើទំនិញទុកលក់ និងអ្នកជួលឱ្យដែលជួលទំនិញតាមការកំណត់នៃច្បាប់នេះ ។

២៤-“ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង” គឺជាបុគ្គលដែលដាក់ឈ្មោះជាម្ចាស់បំណុលដែលមានកិច្ចធានា ឬ តំណាងរបស់ម្ចាស់បំណុលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដំបូង ឬវិសោធនកម្មដែលបានតម្កល់ ។ បុគ្គលនេះមានឋានៈជាម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹង ក្នុងរយៈពេលតម្កល់ ឬរហូតដល់ពេលបានតម្កល់វិសោធនកម្មដែលលុបឈ្មោះម្ចាស់បំណុលនេះ ឬ រហូតដល់ពេលលិខិតសុំបញ្ចប់សិទ្ធិប្រាតិភោគ

របស់ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង ឬ រហូតដល់ពេលដែលលិខិតជូនដំណឹងទាក់ទិននឹងម្ចាស់បំណុលមានកិច្ចធានា ផុតរយៈពេលកំណត់ ។

២៥-"យានយន្តមានលេខស៊េរី" មានន័យថា យានយន្ត រថសណ្តោង អាកាសយាន កាណូត ឬទូកដែលមានម៉ាស៊ីន បើយានយន្តទាំងនេះមិនមែនជាសារពើភណ្ឌរបស់កូនបំណុល ។

២៦-"លិខិតស្នាម" គឺជាកំណត់ត្រាដែលបង្ហាញភស្តុតាងពីសិទ្ធិទទួលប្រាក់ដែលមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ ឬ កិច្ចសន្យាជួល និងការផ្ទេរមួយប្រភេទដែលកើតឡើងតាមការប្រគល់ក្នុងអាជីវកម្មធម្មតាដោយមានបិដ្ឋិលេខចំណារខ្នង ឬ អនុប្បទានសិទ្ធិ ។ ពាក្យនេះរាប់បញ្ចូលទាំងភស្តុតាងនៃសិទ្ធិប្រាតិភោគផងដែរ ។

២៧-"លិខិតជូនដំណឹង" គឺជាកំណត់ត្រាដែលបានតម្កល់ ឬ ដាក់ជូនដើម្បីតម្កល់នៅការិយាល័យតម្កល់ ។ ពាក្យនេះរាប់បញ្ចូលទាំងវិសោធនកម្ម លិខិតសុំបន្ត និងលិខិតសុំបញ្ចប់ដែលបានតម្កល់ ឬ ដាក់ជូនដើម្បីតម្កល់ ។

២៨-"វត្ថុចំណុះ" សំដៅដល់ចលនទ្រព្យដែលបានភ្ជិតបញ្ចូលជាមួយចលនវត្ថុផ្សេង តាមរបៀបដែលមិនធ្វើឱ្យបាត់បង់អត្តសញ្ញាណនៃចលនវត្ថុចម្បងនោះទេ ។

២៩-"សារពើភណ្ឌ" គឺជាទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬ ជាវត្ថុធាតុដើម គំរោងដែលកំពុងដំណើរការ សម្ភារៈដែលប្រើប្រាស់ក្នុងអាជីវកម្ម ។

៣០-"សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ" មានន័យថាសិទ្ធិប្រាតិភោគដែល:

ក-ត្រូវបានយក ឬ រក្សាទុកដោយអ្នកលក់ទំនិញដើម្បីធានាតម្លៃទំនិញនោះទាំងស្រុង ឬ មួយផ្នែក

ខ-ត្រូវបានយកដោយបុគ្គល ក្រៅពីអ្នកលក់ដែលបានបង់តម្លៃ ដើម្បីឱ្យកូនបំណុលទទួលបានសិទ្ធិ ឬការប្រើប្រាស់ទំនិញតាមរយៈការបង្កើតកាតព្វកិច្ច បើតម្លៃនោះ បានប្រើតាមគោលបំណងនេះប្រាកដមែន ។

៣១-"អនុប្បទានសិទ្ធិ" គឺជាការផ្ទេរពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់នូវសិទ្ធិទាំងស្រុង ឬមួយផ្នែកលើឥណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬសិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ។

បុគ្គលដែលផ្ទេរសិទ្ធិនេះហៅថា អនុប្បទាយី និងបុគ្គលដែលទទួលសិទ្ធិផ្ទេរហៅថា អនុប្បទានិក ។

៣២-"អ្នកជួលក្នុងអាជីវកម្មធម្មតា" គឺជាបុគ្គលដែលបានជួលទំនិញតាមប្រភេទនៃទំនិញក្នុងអាជីវកម្មពីបុគ្គលដែលមានអាជីវកម្មលក់ ឬ ជួលទំនិញធម្មតាដោយសុចរិតនិងមិនដឹងថាការជួលនេះបំពានលើសិទ្ធិកម្មសិទ្ធិ ឬ សិទ្ធិប្រាតិភោគ ឬ សិទ្ធិរបស់តតិយជនលើទំនិញនេះឡើយ ។ "កិច្ចសន្យាលក់បណ្តាក់" អាចធ្វើឡើងជាថ្នូរនឹងរូបិយវត្ថុ ឬទ្រព្យផ្សេងទៀត ។

៣៣-"ឧបករណ៍" មានន័យថា ទំនិញ លើកលែងតែកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តមានលេខស៊េរី ។

៣៤-"ឯកសារ" មានន័យថា ប័ណ្ណកម្មសិទ្ធិ ឬបង្កាន់ដៃ ជាអាទិ៍មានប័ណ្ណដឹកជញ្ជូន សក្ខីប័ត្រកំពង់ផែ បង្កាន់ដៃឃ្លាំង ដែលចេញដោយបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូន ឬ ស្តុកទំនិញ ។

**មាត្រា ៤.-**

១-សិទ្ធិប្រាតិភោគ គឺជាសិទ្ធិប្រត្យ័ក្សលើទ្រព្យធានា ដែលដាក់ធានាការបំពេញកាតព្វកិច្ច ។

២-បុគ្គលគ្រប់រូបអាចផ្តល់ ឬ ទទួលសិទ្ធិប្រាតិភោគ ដែលមានចែងក្នុងច្បាប់នេះ លើកលែងតែប្រការដែលមានចែងក្នុងចំណុចទី ៣ នៃមាត្រានេះ ។

៣-មិនអាចបង្កើតសិទ្ធិប្រាតិភោគលើទំនិញប្រើប្រាស់បានទេ លើកលែងតែសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញលើទំនិញរបស់កូនបំណុល ។

៤-មិនអាចចាត់ទុកថា សិទ្ធិប្រាតិភោគគ្មានសុពលភាពទេ បើកូនបំណុលមានសិទ្ធិប្រើប្រាស់ កាន់កាប់ លក់ ដោះដូរ បញ្ចូលេញ្ហា ឬ ជម្រះចោលទ្រព្យធានា ។

**មាត្រា ៥.-**

១-សិទ្ធិប្រាតិភោគអាចធានាកាតព្វកិច្ចមួយ ឬ ច្រើន ដែលចែងជាក់លាក់ ឬ ប្រើពាក្យទូទៅបាន ។

២-កាតព្វកិច្ចប្រាតិភោគជាកាតព្វកិច្ចជារូបិយវត្ថុ ឬ មិនមែនជារូបិយវត្ថុ ។

៣-កាតព្វកិច្ចប្រាតិភោគ ត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់របស់បរទេស ទោះបីជាក្នុងករណីណាមួយក៏ដោយ បទប្បញ្ញត្តិនៃច្បាប់នេះក៏ត្រូវអនុវត្តផងដែរ ។

៤-សិទ្ធិប្រាតិភោគអាចធានាកាតព្វកិច្ចអនាគតបាន ទោះបីជាកាតព្វកិច្ចជាក់លាក់ ឬកាតព្វកិច្ចមានលក្ខខណ្ឌ និងកាតព្វកិច្ចតាមជំរើសក៏ដោយ ។

៥-តាមការព្រមព្រៀងរបស់ភាគី សិទ្ធិប្រាតិភោគអាចធានាបុរេកាតព្វកិច្ចបាន ។

**មាត្រា ៦.-**

១-ទ្រព្យធានាអាចជាទំនិញ និងចលនវត្ថុគ្រប់ប្រភេទបាន ។

២-ទ្រព្យធានាអាចជាទ្រព្យអរូបី ជាអាទិ៍មានសិទ្ធិប្រសិ្បក្ស សិទ្ធិលើបំណុលនិងទ្រព្យអរូបីផ្សេងទៀត ។

៣-ទ្រព្យធានាអាចជាចលនវត្ថុតាំងភ្ជាប់ ។

៤-ទ្រព្យធានាអាចជាទ្រព្យដែលមានក្នុងពេលបច្ចុប្បន្ន ឬ អាចកើតឡើងនាពេលអនាគត ។

៥-ទ្រព្យធានាអាចស្ថិតនៅទីណាក៏បាន ទោះបីនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ ។

៦-ទ្រព្យធានាអាចជាគណនី និងកិច្ចសន្យាលក់ដែលមានកិច្ចធានាដែលបានលក់ ទំនិញដែលបានផ្ញើទុកលក់ ទំនិញដែលបានជួលហើយនិងផលនៃទ្រព្យធានា ។

៧-សេចក្តីអធិប្បាយពីទ្រព្យធានាត្រូវចាត់ទុកថាគ្រប់គ្រាន់ បើក្នុងសេចក្តីអធិប្បាយនោះមានបញ្ជាក់សមស្របពីអត្តសញ្ញាណទ្រព្យធានា ។ សេចក្តីអធិប្បាយពីទ្រព្យធានាអាចចែងជាពាក្យទូទៅបាន លើកលែងតែយានយន្តមានលេខស៊េរី ។ សេចក្តីអធិប្បាយថា "ទ្រព្យសកម្មទាំងអស់" ឬ "ចលនទ្រព្យទាំងអស់" របស់កូនបំណុលត្រូវចាត់ទុកជាសេចក្តីអធិប្បាយគ្រប់គ្រាន់ លើកលែងតែសេចក្តីអធិប្បាយពីទំនិញប្រើប្រាស់ ។

មាត្រា ៧.-

១-កិច្ចព្រមព្រៀងប្រាតិភោគ ត្រូវតែធ្វើឡើងតាមទម្រង់កំណត់ត្រាជាលាយលក្ខណ៍អក្សរ ។ កិច្ចព្រមព្រៀងប្រាតិភោគ អាចកើតឡើងពីកំណត់ត្រាច្រើនដែលផាក់បញ្ចូលគ្នា ។

២-កិច្ចព្រមព្រៀងប្រាតិភោគ ត្រូវមានប្រសិទ្ធភាពស្របតាមលក្ខខណ្ឌរវាងភាគី និងមានប្រសិទ្ធភាពចំពោះអ្នកទិញទ្រព្យធានានិងម្ចាស់បំណុល លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ។

៣-កិច្ចព្រមព្រៀងប្រាតិភោគអាចចែងពីសិទ្ធិប្រាតិភោគច្រើនជាងមួយបាន ។

មាត្រា ៨.-

១-ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវយកចិត្តទុកដាក់ក្នុងការឃុំគ្រង និងថែរក្សាទ្រព្យធានាដែលខ្លួនកាន់កាប់ឱ្យបានគង់វង់ ។

២-លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ បើទ្រព្យធានាស្ថិតក្នុងការកាន់កាប់របស់ម្ចាស់បំណុល :

ក-ចំណាយសមស្របត្រូវចេញដោយកូនបំណុល និងធានាដោយទ្រព្យធានារាប់បញ្ចូលទាំងថ្លៃធានារ៉ាប់រង ពន្ធអាករនិងថ្លៃចំណាយទាក់ទិននឹងទ្រព្យធានា ។

ខ-ហានិភ័យនៃការបាត់បង់ ឬ ការខូចខាតដោយគ្រោះថ្នាក់ គឺជាបន្ទុករបស់កូនបំណុលចំពោះតែប្រាក់ ដែលលើសពីថ្លៃសំណងធានារ៉ាប់រង ។

គ-ម្ចាស់បំណុលដែលមានកិច្ចធានា អាចរក្សាទុកផលនៃទ្រព្យធានាជាសិទ្ធិប្រាតិភោគបន្ថែម លើកលែងតែផលជារូបិយវត្ថុ ហើយបើមានផលជារូបិយវត្ថុ ត្រូវប្រើដើម្បីទូទាត់កាតព្វកិច្ចប្រាតិភោគ លើកលែងតែផលជារូបិយវត្ថុនោះត្រូវបានផ្ទេរឱ្យទៅកូនបំណុលរួចហើយ ។

មាត្រា ៩.-

១-សិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា ហើយអាចបង្ខំឱ្យកូនបំណុលនិងភាគីទីបីអនុវត្តបានចំពោះទ្រព្យធានា តែក្នុងករណីដែល :

ក-កូនបំណុលបានបញ្ជាក់ការឯកភាព លើកិច្ចព្រមព្រៀងប្រាតិភោគដែល

ចែងពីទ្រព្យធានា

ខ-ម្ចាស់បំណុលបានផ្តល់តម្លៃឱ្យទៅកូនបំណុល

គ-កូនបំណុលមានសិទ្ធិលើទ្រព្យធានា ឬអំណាចផ្ទេរសិទ្ធិលើទ្រព្យធានាឱ្យទៅម្ចាស់បំណុលដែលមានកិច្ចធានា ។

២-លើកលែងតែភាគីបានព្រមព្រៀងផ្សេងពីនេះ ការភ្ជាប់សិទ្ធិប្រាតិភោគទៅនឹងទ្រព្យធានាផ្តល់ឱ្យម្ចាស់បំណុល មានកិច្ចធានានូវសិទ្ធិលើផលនៃទ្រព្យធានាដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២
## សុក្រឹតកម្ម និង អាទិភាព

**មាត្រា ១០.-**

១-សិទ្ធិប្រាតិភោគមានសុក្រឹតភាព កាលណាសិទ្ធិប្រាតិភោគនេះបានភ្ជាប់ទៅនឹងទ្រព្យធានា និងបានបំពេញតាមលក្ខខណ្ឌទាំងអស់នៃមាត្រានេះ ។

២-ដើម្បីឱ្យសិទ្ធិប្រាតិភោគមានសុក្រឹតភាព ត្រូវតែតម្កល់លិខិតជូនដំណឹងតាមច្បាប់នេះ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ។

៣-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញទំនិញប្រើប្រាស់ មានសុក្រឹតភាពនៅពេលដែលសិទ្ធិប្រាតិភោគភ្ជាប់នឹងទំនិញនោះ ហើយមិនចាំបាច់តម្កល់លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹតកម្មឡើយ ។

៤-សិទ្ធិប្រាតិភោគលើទំនិញ លិខិតស្នាម ឯកសារ ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាអាចមានសុក្រឹតភាព ដោយការតម្កល់លិខិតជូនដំណឹង ឬ ដោយម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ទ្រព្យធានា ។

៥-សិទ្ធិប្រាតិភោគបន្តមានសុក្រឹតភាពដោយការកាន់កាប់ គិតចាប់ពីពេលកាន់កាប់ ហើយសុក្រឹតភាពនេះ ត្រូវបន្តអនុភាពតែក្នុងពេលមានការកាន់កាប់ប៉ុណ្ណោះ ។

៦-សិទ្ធិប្រាតិភោគលើរូបិយវត្ថុ អាចមានសុក្រឹតភាពតែក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានាបានកាន់កាប់រូបិយវត្ថុ លើកលែងតែផលទ្រព្យធានាដែលជារូបិយវត្ថុ ។

៧-សិទ្ធិប្រាតិភោគលើយានយន្តមានលេខស៊េរី អាចត្រូវធ្វើសុក្រឹតកម្មដោយការតម្កល់លិខិតជូនដំណឹងដែលពណ៌នាជាទូទៅ ឬ បញ្ជាក់ពីលេខស៊េរីនៃយានយន្តនោះ ។

៨-សិទ្ធិប្រាតិភោគក្រៅពីសិទ្ធិប្រាតិភោគលើរូបិយវត្ថុ អាចត្រូវធ្វើសុក្រឹតកម្មមុន ឬ ក្នុងពេល ឬ បន្ទាប់ពីរយៈពេលដែលម្ចាស់បំណុលដែលមានកិច្ចធានាបានកាន់កាប់ទ្រព្យធានា ។

៩-មិនចាំបាច់តម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានាឡើយ ។

១០-កាលណាទំនិញស្ថិតក្នុងការកាន់កាប់របស់អ្នកទទួលបញ្ញើ ដែលបានចេញឯកសារបញ្ជាក់ពីទំនិញនេះ សិទ្ធិប្រាតិភោគលើទំនិញអាចមានសុក្រឹតភាព ដោយការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើឯកសារនោះ ។ សិទ្ធិប្រាតិភោគដែលត្រូវបានធ្វើសុក្រឹតកម្មតាមមធ្យោបាយផ្សេង ក្នុងអំឡុងពេលដែលអ្នកទទួលបញ្ញើកាន់កាប់ទំនិញ ត្រូវមានអាទិភាពក្នុងលំដាប់ បន្ទាប់ពីសិទ្ធិប្រាតិភោគដែលត្រូវធ្វើសុក្រឹតកម្មលើឯកសារ ។

១១-ការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានា នាំឱ្យសិទ្ធិប្រាតិភោគលើកិច្ចធានាដែលគាំទ្រទ្រព្យធានានេះត្រូវមានសុក្រឹតភាពផងដែរ ។ ភាគីមិនចាំបាច់តម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹត្យកម្មសិទ្ធិប្រាតិភោគលើកិច្ចធានានេះឡើយ ។

១២-ការធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើសិទ្ធិទទួលប្រាក់ ឬ ការបំពេញកាតព្វកិច្ចនាំឱ្យសិទ្ធិប្រាតិភោគលើកិច្ចសន្យាអ៊ីប៉ូតែកស្តីពីអចលនទ្រព្យ ដែលធានាសិទ្ធិទទួលប្រាក់នោះមានសុក្រឹតភាពផងដែរ ។

**មាត្រា ១១.-**

១-សិទ្ធិប្រាតិភោគត្រូវមានសុក្រឹតភាពជាបន្ត បើដំបូងត្រូវធ្វើសុក្រឹតកម្មតាមរបៀបមួយ ហើយក្រោយមកមានសុក្រឹតភាពតាមរបៀបផ្សេង បើគ្មានចន្លោះរយៈពេលដែលគ្មានសុក្រឹតភាពរវាងចំណុចទាំងពីរនេះទេ ។

២-ក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានា ផ្ទេរសិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព មិនចាំបាច់តម្កល់លិខិតជូនដំណឹងតាមច្បាប់នេះ ដើម្បីបន្តសុក្រឹតភាពសិទ្ធិ-

ប្រាតិភោគចំពោះម្ចាស់បំណុលរបស់កូនបំណុល និងបុគ្គលដែលទទួលទ្រព្យធានាពីកូនបំណុលឡើយ ។

**មាត្រា ១២.-**

១-សិទ្ធិប្រាតិភោគច្រើនលើទ្រព្យធានាតែមួយ ត្រូវមានអាទិភាពអនុលោមតាមពេលនៃការតម្កល់ ឬ ការធ្វើសុក្រឹតកម្ម លើកលែងតែច្បាប់នេះចែងផ្សេងពីនេះ ។

២-អាទិភាពត្រូវគិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់លិខិតជូនដំណឹងពីទ្រព្យធានា ឬ ពីពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព គឺយកកាលបរិច្ឆេទណាមួយ ដែលកើតឡើងមុន បើគ្មានចន្លោះរយៈពេលដែលគ្មានការតម្កល់និងគ្មានសុក្រឹតភាពក្រោយពីនេះទេ ។

៣-សិទ្ធិប្រាតិភោគដែលត្រូវភ្ជាប់នឹងទ្រព្យធានាមុនគេ ត្រូវមានអាទិភាពលើសិទ្ធិ-ប្រាតិភោគផ្សេងទៀត ដែលមិនបានតម្កល់ ឬមិនបានធ្វើសុក្រឹត្យកម្ម ។

៤-កាលបរិច្ឆេទនៃការតម្កល់ ឬសុក្រឹតកម្មសម្រាប់ទ្រព្យធានា ត្រូវចាត់ទុកជាកាល-បរិច្ឆេទនៃការតម្កល់ ឬ សុក្រឹតកម្មសម្រាប់ផលនៃទ្រព្យធានានេះផងដែរ ។

**មាត្រា ១៣.-**

សិទ្ធិប្រាតិភោគមានអាទិភាពលើសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក លើកលែងតែគាហកនៃសិទ្ធិឃាត់ទុកបានតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់ខ្លួនតាមច្បាប់នេះ :

១-មុនពេលសិទ្ធិប្រាតិភោគមានសុក្រឹត្យភាព

២-មុនពេលម្ចាស់បំណុលតម្កល់លិខិតជូនដំណឹងពីទ្រព្យធានា ។

**មាត្រា ១៤.-**

១-បុគ្គលត្រូវទទួលទ្រព្យធានាដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើបុគ្គលបានទិញនិងផ្តល់តម្លៃដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។ ក្នុងករណីទ្រព្យធានាជាទ្រព្យរូបី បុគ្គលនឹងទទួលបានទ្រព្យធានាដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើបុគ្គលបានទិញផ្តល់តម្លៃ និងទទួលទ្រព្យធានាដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

២-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញក្នុងអាជីវកម្មធម្មតាត្រូវទទួលកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញឡើយ ទោះបីសិទ្ធិប្រាតិភោគមានសុក្រឹតភាពក៏ដោយ និងទោះបីជាអ្នកទិញបានដឹងថា មានជាប់សិទ្ធិប្រាតិភោគក៏ដោយ ។

៣-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញទំនិញប្រើប្រាស់នឹងទទួលបានកម្មសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញ ទោះបីសិទ្ធិប្រាតិភោគមាន ឬ គ្មានសុក្រឹតភាពក៏ដោយ បើអ្នកទិញបានទិញដោយមិនដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលមានការតម្កល់លិខិតជូនដំណឹងពីទំនិញប្រើប្រាស់នេះ ។

៤-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញយានយន្តមានលេខស៊េរី ត្រូវទទួលយានយន្តមានលេខស៊េរី ដោយគ្មានជាប់សិទ្ធិប្រាតិភោគ តែក្នុងករណីដែលអ្នកទិញបានទិញដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ ហើយលិខិតជូនដំណឹងដែលតម្កល់មិនបានពណ៌នាពីយានយន្តមានលេខស៊េរីនេះ ឬ លិខិតជូនដំណឹងដែលតម្កល់នោះបានចុះលេខស៊េរីមិនត្រឹមត្រូវ ។

៥-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកទិញកសិផលត្រូវទទួលបាន :

ក-កសិផលដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកទិញយកកសិផលទៅប្រើជាទំនិញប្រើប្រាស់ ។

ខ-កសិផលដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកទិញយកកសិផលទៅប្រើក្នុងគោលបំណងក្រៅពីទំនិញប្រើប្រាស់ ហើយអ្នកទិញបានផ្តល់តម្លៃ និងបានទទួលកសិផលដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

៦-អ្នកទទួលប្រាក់ផ្ទេរត្រូវទទួលប្រាក់ដោយគ្មានជាប់សិទ្ធិប្រាតិភោគ លើកលែងតែអ្នកទទួលបានសុំគ្រលំជាមួយកូនបំណុលដោយបំពានលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ។

៧-អ្នកទទួលផលនៃទ្រព្យធានាដែលជាមូលនិធិក្នុងគណនីប្រាក់បញ្ញើ គណនីមូលបត្ររូបិយវត្ថុ គណនីសញ្ជ័យ សៀវភៅធនាគារ ឬ គណនីសាច់ប្រាក់ដទៃទៀត ត្រូវទទួលបានមូលនិធិដោយគ្មានជាប់សិទ្ធិប្រាតិភោគ លើកលែងតែអ្នកទទួលបានសុំគ្រលំជាមួយកូនបំណុលដោយបំពានលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ។

**មាត្រា ១៥.-**

១-អ្នកជួលទ្រព្យធានាត្រូវទទួលបានសិទ្ធិ ដោយគ្មានជាប់សិទ្ធិប្រាតិភោគ បើអ្នកជួលបានទទួលទំនិញ ដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ និងមុនពេលដែលសិទ្ធិប្រាតិភោគមានសុក្រឹតភាព ។

២-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកជួលទំនិញក្នុងអាជីវកម្មធម្មតាត្រូវទទួលបានសិទ្ធិដោយគ្មានជាប់សិទ្ធិប្រាតិភោគលើទំនិញ ទោះបីសិទ្ធិប្រាតិភោគមានសុក្រឹតភាព និងទោះបីជាអ្នកជួលបានដឹងថាមានសិទ្ធិប្រាតិភោគក៏ដោយ ។

៣-ថ្វីបើមានចែងក្នុងចំណុចទី ១ ក្តី អ្នកជួលត្រូវទទួលបានយានយន្តមានលេខស៊េរីដោយគ្មានជាប់សិទ្ធិប្រាតិភោគ តែក្នុងករណីដែលអ្នកជួលបានជួលដោយមិនបានដឹងថាមានសិទ្ធិប្រាតិភោគ ហើយលិខិតជូនដំណឹងដែលតម្កល់មិនបានពណ៌នាត្រឹមត្រូវពីយានយន្តមានលេខស៊េរីនេះ ។

**មាត្រា ១៦.-**

បើបុគ្គលតម្កល់លិខិតជូនដំណឹងពីសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញមុនពេល ឬ ក្នុងអំឡុងពេលប្រាំ(០៥)ថ្ងៃ បន្ទាប់ពីកូនបំណុលបានទទួលទំនិញ សិទ្ធិប្រាតិភោគនេះមានអាទិភាពលើសិទ្ធិរបស់អ្នកទិញ អ្នកជួល ឬគាហកនៃសិទ្ធិឃាត់ទុកដែលកើតឡើងក្នុងចន្លោះពេលដែលសិទ្ធិប្រាតិភោគភ្ជាប់នឹងទំនិញ និងពេលនៃការតម្កល់លិខិតជូនដំណឹង ។

**មាត្រា ១៧.-**

១-សិទ្ធិប្រាតិភោគត្រូវបន្តភ្ជាប់នឹងទ្រព្យធានា ថ្វីបើមានការលក់ ការជួល ការផ្តល់អាជ្ញាប័ណ្ណ ការដូរ ឬការជម្រះចោលទ្រព្យធានាក្តី លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ឬភាគីបានព្រមព្រៀងផ្សេងពីនេះ ។

២-នៅពេលជម្រះចោលទ្រព្យធានា សិទ្ធិប្រាតិភោគត្រូវបន្តភ្ជាប់នឹងផលនៃទ្រព្យធានា លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងក្នុងច្បាប់នេះ ឬភាគីបានព្រមព្រៀងផ្សេងនេះ ។

៣-សិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានា គឺជាសិទ្ធិប្រាតិភោគមានសុក្រឹតភាពជាបន្តក្នុងករណីដែលសិទ្ធិប្រាតិភោគលើទ្រព្យធានាដើម ត្រូវបានធ្វើសុក្រឹតកម្ម ប៉ុន្តែសិទ្ធិនេះក្លាយ

ទៅជាគ្មានសុក្រឹតភាពក្នុងរយៈពេលម្ភៃ(២០)ថ្ងៃ បន្ទាប់ពីកូនបំណុលទទួលផលនៃទ្រព្យធានានេះ លើកលែងតែ :

-បានតម្កល់លិខិតជូនដំណឹងសម្រាប់ទ្រព្យធានាដើម ហើយផលនៃទ្រព្យធានាជារូបិយវត្ថុ ឬផលនៃទ្រព្យធានាមានលក្ខណៈដូចបញ្ជាក់ក្នុងលិខិតជូនដំណឹង ឬ

-សិទ្ធិប្រាតិភោគលើផលនៃទ្រព្យធានា ត្រូវបានធ្វើសុក្រឹតកម្មមុនផុតរយៈពេលម្ភៃ (២០)ថ្ងៃ ។

**មាត្រា ១៨.-**

១-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញឧបករណ៍ ដែលមានសុក្រឹតភាពត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគឯទៀតលើឧបករណ៍តែមួយ និងមានអាទិភាពលើផលនៃឧបករណ៍ផងដែរ បើសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញត្រូវបានធ្វើសុក្រឹតកម្មនៅពេលដែលកូនបំណុលបានកាន់កាប់ឧបករណ៍ ឬក្នុងរយៈពេលប្រាំ(០៥)ថ្ងៃ បន្ទាប់ពីការកាន់កាប់ ។

២-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញសារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគផ្សេងទៀតលើសារពើភណ្ឌ ឬសត្វចិញ្ចឹមប្រភេទតែមួយ ប្រសិនបើ :

ក-សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ ត្រូវបានធ្វើសុក្រឹតកម្មនៅពេលដែលកូនបំណុលបានកាន់កាប់សារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ និង

ខ-ម្ចាស់បំណុលដែលមានកិច្ចធានាពីប្រាក់ខ្ចីទិញ ជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកកាន់កាប់សិទ្ធិប្រាតិភោគផ្សេងទៀត បើអ្នកកាន់កាប់នោះបានតម្កល់លិខិតជូនដំណឹងសម្រាប់សារពើភណ្ឌ ឬ សត្វចិញ្ចឹមប្រភេទដូចគ្នា មុនពេលដែលម្ចាស់បំណុលមានកិច្ចធានាពីប្រាក់ខ្ចីទិញបានតម្កល់លិខិតជូនដំណឹង ។ លិខិតជូនដំណឹងត្រូវតែអធិប្បាយអំពីសារពើភណ្ឌ ឬសត្វចិញ្ចឹមគ្រប់ប្រភេទ និងបញ្ជាក់ថាបុគ្គលដែលផ្តល់លិខិតជូនដំណឹងបានទទួល ឬនឹងបានទទួលសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញសារពើភណ្ឌ ឬ សត្វចិញ្ចឹមរបស់កូន



មាត្រា ១៩.–

សិទ្ធិឃាត់ទុកទំនិញដែលបង្កើតឡើងដោយច្បាប់ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព ប្រសិនបើ :

១-សិទ្ធិឃាត់ទុកត្រូវបង្កើតជាផលប្រយោជន៍របស់បុគ្គល ដែលកាន់កាប់ទំនិញសម្រាប់ធានាការទូទាត់ថ្លៃសម្ភារៈ ឬសេវាកម្មដែលទាក់ទិននឹងទំនិញ និង

២-សម្ភារៈ ឬសេវាកម្មនោះត្រូវបានផ្ដល់ក្នុងដំណើរការអាជីវកម្មធម្មតា ។

មាត្រា ២០.–

១-សិទ្ធិប្រាតិភោគអាចបង្កើតលើទំនិញដែលជាចលនវត្ថុតាំងភ្ជាប់ ហើយអាចបន្តភ្ជាប់នឹងទំនិញដែលក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ។

២-សិទ្ធិប្រាតិភោគ លើសម្ភារៈសំណង់ធម្មតាត្រូវបញ្ចប់នៅពេលសម្ភារៈនោះត្រូវបានបញ្ចូលទៅក្នុងអចលនវត្ថុ ។

៣-ម៉ាស៊ីននៃរោងចក្រ ម៉ាស៊ីនប្រើក្នុងការិយាល័យដែលអាចរុះរើបានដោយងាយស្រួល បរិក្ខារក្នុងផ្ទះ ឬវត្ថុដទៃទៀត ដែលអាចយកទៅប្រើដាច់ដោយឡែកពីដី និងអាគារបាន មិនចាត់ទុកជាចលនវត្ថុតាំងភ្ជាប់ឡើយ ។ អាទិភាពលើចលនវត្ថុទាំងនេះមិនត្រូវកំណត់តាមមាត្រានេះទេ ហើយមិនរងឥទ្ធិពលពីសិទ្ធិរបស់ម្ចាស់អចលវត្ថុ ឬម្ចាស់បំណុលអ៊ីប៉ូតែកលើដីឡើយ ។

៤-សិទ្ធិប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់ ត្រូវមានអាទិភាពបន្ទាប់ពីសិទ្ធិប្រត្យក្សលើអចលនវត្ថុ លើកលែងតែសិទ្ធិដែលមានចែងក្នុងច្បាប់នេះ ។

៥-សិទ្ធិប្រាតិភោគលើចលនវត្ថុតាំងភ្ជាប់ដែលមានសុក្រឹតភាព មានអាទិភាពលើសិទ្ធិរបស់ម្ចាស់អចលនវត្ថុ គាហកនៃសិទ្ធិឃាត់ទុក ឬ ម្ចាស់បំណុលអ៊ីប៉ូតែក ទោះបីជាខបញ្ញត្តិនៃកិច្ចសន្យាអ៊ីប៉ូតែកចែងផ្សេងពីនេះក្ដី ប្រសិនបើ :

ក-លិខិតជូនដំណឹង ត្រូវបានតម្កល់មុនការតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុកដែលច្បាប់នេះតម្រូវ ឬមុនពេលចុះបញ្ជីកិច្ចសន្យាអ៊ីប៉ូតែក ឬមុនពេលចុះបញ្ជីសិទ្ធិរបស់ម្ចាស់អចលនវត្ថុ នៅការិយាល័យចុះបញ្ជីអចលនវត្ថុដែលមានសមត្ថកិច្ច

ខ-សិទ្ធិប្រាតិភោគជាសិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ ដែលកូនបំណុលបានផ្តល់មុនពេលទំនិញក្លាយទៅជាចលនវត្ថុតាំងភ្ជាប់ ហើយលិខិតជូនដំណឹងត្រូវបានតម្កល់មុនពេលទំនិញក្លាយទៅជាចលវត្ថុតាំងភ្ជាប់ ឬប្រាំ(១៥)ថ្ងៃ បន្ទាប់ពីទំនិញនេះក្លាយទៅជាចល-នវត្ថុតាំងភ្ជាប់ ។

អាទិភាពដែលបង្កើតក្នុងចំណុច ខ នៃវាក្យខណ្ឌនេះ មិនមានប្រសិទ្ធភាពលើអ៊ីប៉ូតែកធានាការសាងសង់ឡើយ ។ ត្រូវចាត់ទុកជាអ៊ីប៉ូតែកធានាការសាងសង់ រាល់អ៊ីប៉ូតែកដែលធានាកាតព្វកិច្ចបង់ប្រាក់ថ្លៃសាងសង់ ដើម្បីកែលំអលើអចលនទ្រព្យ ហើយអចលនទ្រព្យដែលបានដាក់អ៊ីប៉ូតែកធានាកាតព្វកិច្ចនេះ ត្រូវបានចុះបញ្ជីតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

៦- ម្ចាស់បំណុលមានកិច្ចធានា ដែលមានអាទិភាពតាមមាត្រានេះ អាចដក ឬរុះរើយកចលនវត្ថុតាំងភ្ជាប់វិញនៅពេលកូនបំណុលមិនសងបំណុល ។

ក-ម្ចាស់បំណុលដែលមានកិច្ចធានាដែលដក ឬរុះរើយកចលនវត្ថុតាំងភ្ជាប់ត្រូវតែចេញថ្លៃជួសជុលការខូចខាតលើអចលនទ្រព្យភ្លាមៗ ឱ្យទៅម្ចាស់បំណុលអ៊ីប៉ូតែកដែលមិនមែនជាកូនបំណុល ។

ខ-ម្ចាស់បំណុលដែលមានកិច្ចធានា មិនចាំបាច់ចេញសំណងជូនម្ចាស់បំណុលអ៊ីប៉ូតែក ឬ កម្មសិទ្ធិករចំពោះការចុះតម្លៃដោយសារគ្មានទំនិញដែលបានយកចេញ ឬដោយភាពចាំបាច់នៃការដាក់ជំនួសវិញឡើយ ។

គ-បុគ្គលដែលមានសិទ្ធិទារសំណងនេះអាចបដិសេធការយកចេញ ឬការរុះរើ រហូតទាល់តែម្ចាស់បំណុល ដែលមានកិច្ចធានាផ្តល់ការធានាគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចចេញសំណងនេះ ។

## មាត្រា ២១.-

សិទ្ធិប្រាតិភោគលើផលដំណាំដែលដាំដុះលើអចលនទ្រព្យ មានអាទិភាពលើសិទ្ធិរបស់កម្មសិទ្ធិករ ឬ ម្ចាស់បំណុលអ៊ីប៉ូតែក បើកូនបំណុលបានកាន់កាប់អចលនទ្រព្យ ឬមានសិទ្ធិលើអចលនទ្រព្យ ដែលបានចុះបញ្ជីតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រ

**មាត្រា ២២.-**

១-សិទ្ធិប្រាតិភោគអាចបង្កើតលើវត្ថុចំណុះ ហើយសិទ្ធិប្រាតិភោគនេះបន្តអានុភាពលើទ្រព្យធានាដែលក្លាយទៅជាវត្ថុចំណុះ ។ បើសិទ្ធិប្រាតិភោគត្រូវធ្វើសុក្រឹតកម្មនៅពេលដែលទ្រព្យធានាក្លាយទៅជាវត្ថុចំណុះសិទ្ធិប្រាតិភោគត្រូវបន្តសុក្រឹតភាពលើវត្ថុចំណុះនោះ ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាអាចដកយកវត្ថុចំណុះនោះចេញពីចលនវត្ថុផ្សេងនោះបាន បើសិទ្ធិប្រាតិភោគលើវត្ថុចំណុះមានអាទិភាពលើការទាមទាររបស់បុគ្គលផ្សេងទៀត ដែលមានសិទ្ធិលើចលនវត្ថុទាំងមូល ។

៣-ភាគីដែលដកយកវត្ថុចំណុះត្រូវសងថ្លៃចំណាយជួសជុល ឬ ការខូចខាតជាក់ស្តែងលើចលនវត្ថុទាំងមូលឱ្យទៅអ្នកកាន់កាប់ដែលមិនមែនជាកូនបំណុលនូវផលប្រយោជន៍លើចលនវត្ថុទាំងមូល ឬចលនវត្ថុផ្សេងនោះ ដែលសិទ្ធិនៃអ្នកកាន់កាប់នេះមានអាទិភាពលើសិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ហើយ :

ក-ម្ចាស់បំណុលដែលមានកិច្ចធានា មិនចាំបាច់ចេញសងការចុះតម្លៃចលនវត្ថុទាំងមូលដែលបណ្តាលឡើងដោយសារគ្មានវត្ថុចំណុះ ឬភាពចាំបាច់នៃការដាក់ជំនួសវិញឡើយ ។

ខ-បុគ្គលដែលមានសិទ្ធិទារសំណងនេះ អាចបដិសេធមិនអនុញ្ញាតឱ្យរុះរើយកវត្ថុចំណុះ លុះត្រាតែម្ចាស់បំណុលដែលមានកិច្ចធានាផ្តល់ការធានាច្បាស់ពីការបំពេញកាតព្វកិច្ចចេញសំណងនេះ ។

**មាត្រា ២៣.-**

១-សិទ្ធិប្រាតិភោគមិនអាចបង្កើតលើទំនិញនីមួយៗ ដែលលាយបញ្ចូលគ្នាឡើយ ។

២-ប្រសិនបើទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា សិទ្ធិប្រាតិភោគត្រូវភ្ជាប់នឹងផលិតផល ឬ សមាសធាតុរួម ។

៣-បើសិទ្ធិប្រាតិភោគមានសុក្រឹតភាព មុនពេលទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា សិទ្ធិប្រាតិភោគដែលភ្ជាប់ទៅនឹងផលិតផល ឬសមាសធាតុរួមត្រូវមានសុក្រឹតភាពដោយមិនចាំបាច់ផ្តល់លិខិតជូនដំណឹងឡើយ ។ អាទិភាពនៃសិទ្ធិប្រាតិភោគលើផលិតផល ឬ

សមាសធាតុរួម ត្រូវគិតចាប់ពីពេលធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលបាន ក្លាយទៅជាទំនិញបញ្ចូលគ្នា ។

៤- ក្នុងករណីមានសិទ្ធិប្រាតិភោគលើសពីមួយភ្ជាប់ទៅនឹងផលិតផល ឬសមាសធាតុរួម អាទិភាពត្រូវកំណត់តាមវិធានខាងក្រោមនេះ :

ក- សិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព ត្រូវមានអាទិភាពលើសិទ្ធិប្រាតិភោគដែលគ្មានសុក្រឹតភាពក្នុងពេលដែលទ្រព្យធានាក្លាយទៅជាទំនិញបញ្ចូលគ្នា ។

ខ- សិទ្ធិដែលត្រូវភ្ជាប់នឹងផលិតផល ឬសមាសធាតុរួមមុនគេត្រូវមានអាទិភាពលើសិទ្ធិដែលគ្មានសុក្រឹតភាព ។

គ- បើមានសិទ្ធិប្រាតិភោគលើសពីមួយ ត្រូវបានធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគត្រូវមានលំដាប់អាទិភាពស្មើគ្នាតាមសមាមាត្រនៃតម្លៃទ្រព្យធានា នៅពេលទ្រព្យនេះបានក្លាយទៅជាទំនិញបញ្ចូលគ្នា ។

**មាត្រា ២៤.-**

អ្នកទិញកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬ លិខិតស្នាម មានអាទិភាពលើសិទ្ធិប្រាតិភោគផ្សេងលើកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាមហើយក៏មានអាទិភាពលើផលនៃកិច្ចសន្យាលក់ ដែលមានកិច្ចធានាឬលិខិតស្នាមផងដែរ ប្រសិនបើ :

-អ្នកទិញបានផ្តល់តម្លៃថ្មីនិងកាន់កាប់កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាមក្នុងដំណើរការអាជីវកម្មធម្មតារបស់ខ្លួន និង

-កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម មិនបានបញ្ជាក់ថាបានផ្ទេរឱ្យទៅភាគីដែលកាន់កាប់សិទ្ធិប្រាតិភោគដែលប្រជែងគ្នា ។

**មាត្រា ២៥.-**

១- បុគ្គលអាចធ្វើអនុប្បទានសិទ្ធិរបស់ខ្លួនទាំងអស់ ឬ មួយផ្នែកលើគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឬលិខិតស្នាម និងសិទ្ធិលើទ្រព្យអរូបីផ្សេងៗទៀតបាន ។

២- អនុប្បទានសិទ្ធិអាចមានលក្ខណៈជាការធ្វើអនុប្បទានសិទ្ធិទូទៅ ដូចជាសិទ្ធិទទួលប្រាក់ក្នុងពេលអនាគត កិច្ចសន្យាលក់ដែលមានកិច្ចធានា លិខិតស្នាម និងទ្រព្យអរូបីដទៃ

៣-អនុប្បទានិកត្រូវគោរពតាមលក្ខខណ្ឌក្នុងកិច្ចព្រមព្រៀងរវាងកូនបំណុលគណនី និងអនុប្បទាយី ។

៤-មិនចាំបាច់ជូនដំណឹងពីការភ្ជាប់សិទ្ធិប្រាតិភោគ សុក្រឹតកម្មសិទ្ធិប្រាតិភោគ ឬការអនុវត្តសិទ្ធិប្រាតិភោគដែលកើតចេញពីអនុប្បទានសិទ្ធិដល់កូនបំណុលគណនីឡើយ ។ ការមិនបានជូនដំណឹងដល់កូនបំណុលគណនី មានអនុភាពចំពោះតែករណីដូចបានចែងក្នុងមាត្រានេះប៉ុណ្ណោះ ។

៥-ក្នុងករណីដែលតម្រូវឱ្យមានការជូនដំណឹងដល់កូនបំណុលគណនី ការផ្តល់ពត៌-មាននោះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយកំណត់ពីសិទ្ធិដែលបានផ្ទេរ ហើយត្រូវមានហត្ថលេខារបស់អនុប្បទាយី ឬអនុប្បទានិក ប៉ុន្តែមិនចាំបាច់រៀបរាប់ពីខ្លឹមសារ ឬលក្ខខណ្ឌនៃអនុប្បទានសិទ្ធិឡើយ ។

៦-កូនបំណុលគណនី ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយការបង់ប្រាក់ជូនអនុប្ប-ទាយីរហូតដល់ពេលដែលខ្លួនបានទទួលដំណឹងថាប្រាក់ដែលត្រូវបង់ ឬដល់កាលកំណត់សងត្រូវបានផ្ទេរ ហើយមានការណែនាំឱ្យបង់ជូនអនុប្បទានិក ។

៧-ក្រោយពីបានទទួលការជូនដំណឹងពីអនុប្បទានសិទ្ធិនេះ កូនបំណុលគណនីត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយបង់ប្រាក់ជូនអនុប្បទានិក ហើយមិនត្រូវបង់ប្រាក់ឱ្យអនុ-ប្បទាយីទៀតទេ ។ ប៉ុន្តែក្នុងករណីមានការស្នើសុំពីកូនបំណុលគណនី អនុប្បទានិកត្រូវផ្តល់ភស្តុតាងគ្រប់គ្រាន់និងទាន់ពេលវេលាថាគណនីនេះត្រូវបានធ្វើអនុប្បទាន ហើយបើអនុ-ប្បទានិកមិនបានធ្វើដូច្នេះទេ កូនបំណុលគណនីអាចបំពេញកាតព្វកិច្ចរបស់ខ្លួនដោយបន្តបង់ប្រាក់ជូនអនុប្បទាយី ទោះបីជាកូនបំណុលគណនីបានទទួលលិខិតជូនដំណឹងពីអនុ-ប្បទានសិទ្ធិនេះក៏ដោយ ។

**មាត្រា ២៦.-**

កិច្ចព្រមព្រៀងរវាងម្ចាស់បំណុលដែលមានកិច្ចធានា និងកូនបំណុលមិនអាចដាក់ឱ្យប្រតិបត្តិតាមបានទេ បើកិច្ចព្រមព្រៀងនេះហាមប្រាម ឬដាក់កំរិតលើការលក់ ឬការផ្ទេរគណនីនៃកិច្ចសន្យាជួល ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានា ។

**មាត្រា ២៧.–**

១-កាលណាសិទ្ធិប្រាតិភោគត្រូវបានធ្វើសុក្រឹតកម្មដើម្បីធានាកាតព្វកិច្ច ដោយម្ចាស់បំណុលដែលមានកិច្ចធានា ដើម្បីផ្តល់បុរេប្រទាននាពេលអនាគត សិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុកមានអាទិភាពលើទ្រព្យធានានេះ ចំពោះតែសិទ្ធិប្រាតិភោគធានាបុរេប្រទានដែលបានផ្តល់បន្ទាប់ពីម្ចាស់បំណុលដែលមានកិច្ចធានាបានដឹងថា មានសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក ឬលើសពីម្ភៃ(២០)ថ្ងៃ បន្ទាប់ពីគាហកនៃសិទ្ធិឃាត់ទុកបានតម្កល់លិខិតជូនដំណឹងពីសិទ្ធិរបស់ខ្លួននៅការិយាល័យតម្កល់លិខិតជូនដំណឹង គឺយកកាលបរិច្ឆេទណាមួយដែលកើតឡើងមុន ។

២-បើលិខិតជូនដំណឹងចែងពីទ្រព្យធានា ដែលកូនបំណុលនឹងមានសិទ្ធិលើទ្រព្យធានាក្នុងពេលអនាគត លិខិតជូនដំណឹងនេះមិនត្រូវមានប្រសិទ្ធភាពលើសិទ្ធិរបស់អភិបាល ឬ អភិបាលបណ្តោះអាសន្ន ដែលតែងតាំងតាមច្បាប់ក្ស័យធនទេ អាទិភាពនេះមានចំពោះតែទ្រព្យធានាដែលបានទទួលក្រោយពេលតម្កល់លិខិតជូនដំណឹង នៅការិយាល័យតម្កល់តាមបទបញ្ញត្តិច្បាប់ស្តីពីក្ស័យធន ។

**មាត្រា ២៨.–**

បុគ្គលដែលមានអាទិភាពតាមច្បាប់នេះ អាចយល់ព្រមកែប្រែ ឬលុបចោលអាទិភាពនេះបាន ។ ភាគីមិនចាំបាច់តម្កល់លិខិតជូនដំណឹងពីការព្រមព្រៀងកែប្រែ ឬ លុបចោលអាទិភាពនេះឡើយ ។

## ជំពូកទី ៣
## ការតម្កល់លិខិតជូនដំណឹង

**មាត្រា ២៩.–**

ការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការ ដែលមានកិច្ចធានាត្រូវបង្កើតនៅក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៣០.-**

ការិយាល័យនេះជាទីកន្លែងដែលត្រូវតម្កល់ :

១-លិខិតជូនដំណឹងដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលចែងក្នុងច្បាប់នេះ លើកលែងតែទ្រព្យធានាដូចបានកំណត់ក្នុងមាត្រា ៤៤ នៃច្បាប់នេះនិង

២-លិខិតជូនដំណឹងពីសិទ្ធិរបស់គាហកនៃសិទ្ធិឃាត់ទុក ។

**មាត្រា ៣១.-**

១-ក្រសួងពាណិជ្ជកម្ម មានអំណាចចេញលិខិតបទដ្ឋានទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ។

២-លិខិតបទដ្ឋានរបស់ក្រសួងពាណិជ្ជកម្ម មិនត្រូវផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់នេះ ឬគោលបំណងលើកស្ទួយសកម្មភាពពាណិជ្ជកម្មដែលចែងក្នុងច្បាប់នេះឡើយ ។

៣-លិខិតបទដ្ឋានអាចចែងពីវិធីបង់ថ្លៃសេវាកម្ម ដែលកំណត់ដោយច្បាប់នេះ ។

៤-ក្រសួងពាណិជ្ជកម្មត្រូវអនុញ្ញាតឱ្យមានការតម្កល់លិខិតជូនដំណឹង និងការស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយអេឡិចត្រូនិក ។ ប៉ុន្តែក្រសួងពាណិជ្ជកម្មអាចចេញលិខិតបទដ្ឋានសម្រាប់អនុញ្ញាតឱ្យដាក់ជូនលិខិតជូនដំណឹង និងការស្នើសុំស្រាវជ្រាវរកកំណត់ត្រាតាមមធ្យោបាយផ្សេងពីនេះ ដែលអាចបំប្លែងទៅជាកំណត់ត្រាអេឡិចត្រូនិកបាន ។ កំណត់ត្រាអេឡិចត្រូនិករបស់ការិយាល័យតម្កល់ ត្រូវចាត់ទុកជាកំណត់ត្រាផ្លូវការនៃការតម្កល់ ។

៥-បើក្រសួងពាណិជ្ជកម្មចេញលិខិតបទដ្ឋានសម្រាប់អនុញ្ញាតការដាក់ជូនលិខិតជូនដំណឹងនិងការស្នើសុំស្រាវជ្រាវរកកំណត់ត្រា តាមមធ្យោបាយផ្សេងពីមធ្យោបាយអេឡិចត្រូនិក ក្រសួងពាណិជ្ជកម្មអាចកំណត់នូវទម្រង់បែបបទសម្រាប់ដាក់ជូនលិខិតជូនដំណឹងនិងការស្នើសុំស្រាវជ្រាវរកកំណត់ត្រា ។

**មាត្រា ៣២.-**

១-ព័ត៌មានដែលចែងក្នុងលិខិតជូនដំណឹង ដែលតម្កល់តាមច្បាប់នេះជាកំណត់ត្រាសាធារណៈ ។

២-ឧបសម្ព័ន្ធ និងកំណត់ត្រាផ្សេងទៀត ដែលបង្កើតឡើងដោយការិយាល័យតម្កល់ ហើយពាក់ព័ន្ធនឹងលិខិតជូនដំណឹងនេះត្រូវចាត់ទុកជាកំណត់ត្រាសាធារណៈ ។

៣-បុគ្គលគ្រប់រូបមានសិទ្ធិពិនិត្យមើល និងថតចម្លងកំណត់ត្រាសាធារណៈដែលតម្កល់នៅការិយាល័យតម្កល់ដោយគ្មានការរើសអើងអ្វីឡើយ ។

**មាត្រា ៣៣.–**

១-ត្រូវចាត់ទុកថាលិខិតជូនដំណឹងដំបូងមានលក្ខណៈគ្រប់គ្រាន់ បើលិខិតជូនដំណឹងនេះ :

ក-កំណត់អត្តសញ្ញាណនិងចែងពីអាសយដ្ឋានរបស់កូនបំណុល ។

ខ-កំណត់អត្តសញ្ញាណម្ចាស់បំណុលដែលមានកិច្ចធានា ឬភ្នាក់ងាររបស់ម្ចាស់បំណុលដែលមានកិច្ចធានា និងអាសយដ្ឋានរបស់ម្ចាស់បំណុល ។

គ-ពណ៌នាអំពីទ្រព្យធានាដែលចុះក្នុងលិខិតជូនដំណឹងជាអក្សរខ្មែរ និងអក្សរឡាតាំង និងលេខអារ៉ាប់ ។ ក្រៅពីនេះលិខិតជូនដំណឹងត្រូវតែអធិប្បាយពីអចលនវត្ថុដែលពាក់ព័ន្ធ បើលិខិតជូនដំណឹងនេះចែងពីឈើឈរដែលត្រូវកាប់ ឬ រ៉ែដែលត្រូវជីកយក ឬ បើទ្រព្យធានាជាចលនវត្ថុតាំងភ្ជាប់ ។

២-បុគ្គលមានសិទ្ធិតម្កល់លិខិតជូនដំណឹងដំបូង តែក្នុងករណីដែលកូនបំណុលអនុញ្ញាតឱ្យតម្កល់ដូចបានបញ្ជាក់ក្នុងកំណត់ត្រា ដែលកូនបំណុលបានបញ្ជាក់ការឯកភាព ។ កំណត់ត្រាបញ្ជាក់ការឯកភាព មិនចាំបាច់ចែងក្នុងលិខិតជូនដំណឹងឡើយ ។

៣-ការដែលកូនបំណុលចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាតិភោគ មានន័យថាកូនបំណុលអនុញ្ញាតឱ្យតម្កល់លិខិតជូនដំណឹងដំបូង ឬវិសោធនកម្មដែលចែងពីទ្រព្យធានាដែលរៀបរាប់ក្នុងកិច្ចសន្យា និងផលនៃទ្រព្យធានា ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគចែងច្បាស់ ឬមិនបានចែងច្បាស់ពីផលនៃទ្រព្យធានាក្តី ។

៤-លិខិតជូនដំណឹងអាចត្រូវបានតម្កល់មុនចុះកិច្ចព្រមព្រៀងប្រាតិភោគ ឬមុនសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងទ្រព្យធានា ។

៥-លិខិតជូនដំណឹងដែលគោរពតាមលក្ខខណ្ឌតម្រូវភាគច្រើននៃមាត្រានេះត្រូវចាត់ទុកថាមានប្រសិទ្ធភាព ទោះបីជាមិនបានបំពេញលក្ខខណ្ឌទាំងស្រុងនៃមាត្រានេះក៏ដោយ

លើកលែងតែវិការៈនោះបង្កឱ្យមានការភ័ន្តច្រឡំខ្លាំង ។ លិខិតជូនដំណឹងដែលមិនបានចែងពីឈ្មោះកូនបំណុល ត្រូវចាត់ទុកថាជាលិខិតជូនដំណឹងដែលបង្កឱ្យមានការភ័ន្តច្រឡំខ្លាំង ។

មាត្រា ៣៤.-

១-ត្រូវចាត់ទុកថាលិខិតជូនដំណឹងចែងគ្រប់គ្រាន់ពីឈ្មោះ ឬនាមករណ៍របស់កូនបំណុលជាអក្សរខ្មែរ និងអក្សរឡាតាំង និងលេខអារ៉ាប់ កាលណា :

ក-កូនបំណុលជារូបវន្តបុគ្គលដែលមានឈ្មោះក្នុងកំណត់ត្រារបស់ក្រសួងមហាផ្ទៃ ហើយលិខិតជូនដំណឹងមានចុះអត្តលេខប្រាំបួនខ្ទង់ ដែលបោះពុម្ពលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់សាមីជន ។

ខ-កូនបំណុលជារូបវន្តបុគ្គល ហើយមិនមែនជាពលរដ្ឋខ្មែរ លិខិតជូនដំណឹងត្រូវចុះឈ្មោះរបស់បុគ្គល ដូចដែលបោះពុម្ពលើលិខិតឆ្លងដែនរបស់សាមីជន និងឈ្មោះប្រទេសដែលចេញលិខិតឆ្លងដែននោះ ។

គ-កូនបំណុលជានីតិបុគ្គលដែលបង្កើតឡើង ឬ ទទួលស្គាល់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា លិខិតជូនដំណឹងត្រូវចុះនាមករណ៍របស់កូនបំណុលដែលបានចុះក្នុងបញ្ជីពាណិជ្ជកម្ម ឬ នាមករណ៍ដែលច្បាប់ទទួលស្គាល់ ។

ឃ-កូនបំណុលជានីតិបុគ្គលបរទេស ដែលបង្កើតឡើងក្រៅព្រះរាជាណាចក្រកម្ពុជា ហើយមានសមត្ថភាពធ្វើអាជីវកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើលិខិតជូនដំណឹងបានចុះនាមករណ៍របស់កូនបំណុល ដូចបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

ង-កូនបំណុលជានីតិបុគ្គលបរទេស ដែលមិនបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ហើយលិខិតជូនដំណឹងនេះត្រូវចុះនាមករណ៍របស់កូនបំណុលដូចចុះក្នុងបញ្ជីពាណិជ្ជកម្មនៃប្រទេសកំណើតរបស់នីតិបុគ្គលបរទេសដែរ ។

២-លិខិតជូនដំណឹងដែលចែងគ្រប់គ្រាន់ពីឈ្មោះរបស់កូនបំណុល មិនអាចក្លាយទៅជាអាត់ប្រសិទ្ធភាពដោយសារការចែង ឬ មិនបានចែងពីពាណិជ្ជនាម ឬ ឈ្មោះផ្សេងទៀត

របស់កូនបំណុលឡើយ ។ លិខិតជូនដំណឹងដែលចែងតែពីពាណិជ្ជនាមរបស់កូនបំណុល មិនចាត់ទុកថាបានចែងគ្រប់គ្រាន់ពីឈ្មោះរបស់កូនបំណុលឡើយ ។

៣-លិខិតជូនដំណឹង អាចចែងពីឈ្មោះកូនបំណុលនិងម្ចាស់បំណុលមានកិច្ចធានា លើសពីមួយបាន ។

៤-ក្នុងករណីដែលលិខិតជូនដំណឹង មិនបានបញ្ជាក់ថាបុគ្គលជាភ្នាក់ងាររបស់ម្ចាស់បំណុលដែលមានកិច្ចធានា មិនប៉ះពាល់ដល់ភាពគ្រប់គ្រាន់នៃលិខិតជូនដំណឹងឡើយ ។

**មាត្រា ៣៥.–**

១-លិខិតជូនដំណឹងដែលបានតម្កល់ ត្រូវបន្តមានប្រសិទ្ធភាពលើទ្រព្យធានាដែលត្រូវបានលក់ ដោះដូរ ជួល ឬជម្រះចោលតាមវិធីដែលសិទ្ធិប្រាតិភោគបន្តមានអត្ថិភាព ទោះបីម្ចាស់បំណុលមានកិច្ចធានាបានដឹង ឬ យល់ព្រមនឹងការជម្រះចោលនេះក៏ដោយ ។

២-បើកូនបំណុលប្តូរឈ្មោះដែលធ្វើឱ្យលិខិតជូនដំណឹង ដែលបានតម្កល់បង្កការភ័ន្តច្រឡំខ្លាំង លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព ដើម្បីបន្តសុក្រឹតភាពសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលកូនបំណុលទទួលបានមុន ឬ ក្នុងរយៈពេលបួន(០៤)ខែ បន្ទាប់ពីការប្តូរឈ្មោះនេះ ។ លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព ដើម្បីបន្តសុក្រឹតភាពសិទ្ធិប្រាតិភោគលើទ្រព្យធានាដែលកូនបំណុលទទួលបាន ក្នុងរយៈពេលលើសពីបួន(០៤)ខែ ក្រោយពីការប្តូរឈ្មោះនេះ តែក្នុងករណីដែលបានតម្កល់វិសោធនកម្មលើលិខិតជូនដំណឹង ដើម្បីកែតម្រូវឈ្មោះក្នុងរយៈពេលបួន(០៤)ខែបន្ទាប់ពីការប្តូរឈ្មោះនេះ ។

៣-លើកលែងតែប្រការដែលចែងពីការប្តូរឈ្មោះកូនបំណុលក្នុងចំណុចទី ២ ខាងលើ លិខិតជូនដំណឹងនេះបន្តមានប្រសិទ្ធភាព ទោះបីជាកាលៈទេសៈបានកែប្រែ និងបណ្តាលឱ្យលិខិតជូនដំណឹងបង្កការភ័ន្តច្រឡំខ្លាំង បន្ទាប់ពីការតម្កល់លិខិតជូនដំណឹងក៏ដោយ ។

**មាត្រា ៣៦.–**

១-លិខិតជូនដំណឹងមានប្រសិទ្ធភាព សម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់ ។

២-លិខិតជូនដំណឹងដែលបានតម្កល់ត្រូវអស់ប្រសិទ្ធភាព នៅពេលដែលផុតរយៈពេលប្រាំ(០៥)ឆ្នាំ លើកលែងតែបុគ្គលបានតម្កល់លិខិតសុំបន្តមុនផុតរយៈពេលប្រាំ(០៥)ឆ្នាំ ។

៣-លិខិតជូនដំណឹងក្លាយទៅជាគ្មានប្រសិទ្ធភាព នៅពេលផុតរយៈពេលប្រាំ(០៥) ឆ្នាំ ហើយរាល់សិទ្ធិប្រាតិភោគដែលមានសុក្រឹតភាព តាមលិខិតជូនដំណឹងនេះក៏ក្លាយទៅជាគ្មានសុក្រឹតភាពដែរ លើកលែងតែសិទ្ធិប្រាតិភោគដែលមានប្រសិទ្ធភាពដោយមិនចាំបាច់តម្កល់លិខិតជូនដំណឹង ។

៤-បើសិទ្ធិប្រាតិភោគក្លាយទៅជាគ្មានសុក្រឹតភាពនៅពេលផុតរយៈពេល ត្រូវចាត់ទុកថាមិនដែលបានធ្វើសុក្រឹតកម្ម ចំពោះអ្នកទិញទ្រព្យធានាពីមុន ឬ អ្នកទិញទ្រព្យធានាបន្តបន្ទាប់ដែលបានបង់តម្លៃឡើយ ។

**មាត្រា ៣៧.-**

១-លិខិតជូនដំណឹងដំបូងអាចត្រូវកែប្រែដោយវិសោធនកម្មម្តង ឬ ច្រើនដង ។ វិសោធនកម្មត្រូវតែ :

ក-បញ្ជាក់ពីលិខិតជូនដំណឹងដំបូងតាមលេខតម្កល់ ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យមានវិសោធនកម្មនេះ ។

គ-បញ្ជាក់ថានេះជាវិសោធនកម្មលើលិខិតជូនដំណឹង ។

ឃ-ចែងពីព័ត៌មានចាំបាច់ទាំងអស់ ក្នុងលិខិតជូនដំណឹងដំបូងដោយចែងឆ្លុះបញ្ចាំងពីលិខិតជូនដំណឹងនេះទាំងស្រុងឡើងវិញ ។

២-បើវិសោធនកម្មដាក់បន្ថែមទ្រព្យធានា ដែលចែងក្នុងលិខិតជូនដំណឹង ឬ បន្ថែមកូនបំណុលទៅក្នុងលិខិតជូនដំណឹង លិខិតជូនដំណឹងនេះមានប្រសិទ្ធភាព បើកូនបំណុលអនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាព ។ ការដែលកូនបំណុលចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រាតិភោគមានន័យថា កូនបំណុលអនុញ្ញាតឱ្យតម្កល់វិសោធនកម្មចែងពីទ្រព្យធានាដែលចុះក្នុងកិច្ចព្រមព្រៀងប្រាតិភោគនិងផលនៃទ្រព្យធានា ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគចែងជាក់លាក់ ឬ មិនជាក់លាក់ពីផលនៃទ្រព្យធានាក៏ដោយ ។

៣-បើលិខិតជូនដំណឹងចែងពីម្ចាស់បំណុលដែលមានកិច្ចធានាលើសពីមួយ វិសោធនកម្មមានប្រសិទ្ធភាព ចំពោះតែម្ចាស់បំណុល ដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាពប៉ុណ្ណោះ ។

៤-វិសោធនកម្មបន្ថែមទ្រព្យធានា មានប្រសិទ្ធភាពលើទ្រព្យធានាដែលបន្ថែមនោះ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់វិសោធនកម្ម ។

៥-វិសោធនកម្មបន្ថែមកូនបំណុល មានប្រសិទ្ធភាពលើកូនបំណុលដែលបន្ថែមនោះ គិតចាប់ពីកាលបរិច្ឆេទនៃការតម្កល់វិសោធនកម្ម ។

៦-វិសោធនកម្មក្រៅពីវិសោធនកម្មបន្ថែមទ្រព្យធានា ឬ បន្ថែមកូនបំណុលមានប្រសិទ្ធភាពតែក្នុងករណីដែលម្ចាស់បំណុលដែលមានកិច្ចធានា អនុញ្ញាតឱ្យតម្កល់តាមកំណត់ត្រាដែលកូនបំណុលបានឯកភាព ។

៧-វិសោធនកម្មគ្មានប្រសិទ្ធភាពទេ បើវិសោធនកម្មនេះចែងលុបចោលម្ចាស់បំណុលដែលមានកិច្ចធានាទាំងអស់ ដោយមិនបានចែងពីឈ្មោះម្ចាស់បំណុល ដែលមានកិច្ចធានាថ្មី ឬ ចែងលុបឈ្មោះកូនបំណុលទាំងអស់ និងមិនបានចែងពីឈ្មោះកូនបំណុល ដែលមិនបានបញ្ជាក់ក្នុងលិខិតជូនដំណឹងពីមុន ។

៨-បើមានម្ចាស់បំណុលដែលមានកិច្ចធានាលើសពីមួយ ក្នុងលិខិតជូនដំណឹងម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ៗ អាចអនុញ្ញាតឱ្យតម្កល់វិសោធនកម្មបាន ។

៩-វិសោធនកម្មដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ មិនប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលមានឈ្មោះក្នុងលិខិតជូនដំណឹងឡើយ ។

១០-ការតម្កល់វិសោធនកម្ម មិនធ្វើឱ្យរយៈពេលប្រសិទ្ធភាពនៃលិខិតជូនដំណឹងត្រូវកើនឡើងទេ ។

**មាត្រា ៣៨.-**

១-រយៈពេលប្រសិទ្ធភាពនៃលិខិតជូនដំណឹង អាចត្រូវបន្តដោយតម្កល់លិខិតសុំបន្តដែល :

ក-បញ្ជាក់ពីលេខតម្កល់នៃលិខិតជូនដំណឹងដំបូង ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យមានលិខិតសុំបន្តនេះ ។

គ-បញ្ជាក់ថាលិខិតជូនដំណឹងត្រូវបន្តប្រសិទ្ធភាព ចំពោះម្ចាស់បំណុលដែល

LE MINISTRE DU PALAIS ROYAL

មានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់ ។

២-ភាគីអាចតម្កល់លិខិតសុំបន្តសុពលភាព ក្នុងរយៈពេលប្រាំមួយ(០៦)ខែ មុនផុតរយៈពេលប្រាំ(០៥)ឆ្នាំ ដែលលិខិតជូនដំណឹងមានសុពលភាព ។

ក-ចាប់ពីពេលតម្កល់លិខិតសុំបន្ត លិខិតជូនដំណឹងត្រូវបន្តសុពលភាពនិងមានប្រសិទ្ធភាពសម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំទៀត គិតចាប់ពីថ្ងៃដែលលិខិតជូនដំណឹងដំបូងត្រូវអស់ប្រសិទ្ធភាព ។

ខ-ប្រសិទ្ធភាពនេះត្រូវបន្តចំពោះតែម្ចាស់បំណុលដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យតម្កល់លិខិតសុំបន្តប៉ុណ្ណោះ ។

គ-នៅពេលផុតរយៈពេលប្រាំ(០៥)ឆ្នាំ លិខិតជូនដំណឹងត្រូវអស់សុពលភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានា លើកលែងតែលិខិតសុំបន្តដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាត្រូវបានតម្កល់មុនផុតរយៈពេលនេះ ។ ដើម្បីបន្តប្រសិទ្ធភាពលិខិតជូនដំណឹងតទៅទៀត ភាគីអាចតម្កល់លិខិតសុំបន្តសុពលភាពជាបន្តបន្ទាប់តាមរបៀបដូចបានចែងខាងលើនេះ ។

**មាត្រា ៣៩.-**

១-ប្រសិទ្ធភាពនៃលិខិតជូនដំណឹង អាចត្រូវបញ្ចប់ដោយការតម្កល់លិខិតសុំបញ្ចប់ដែល :

ក-បញ្ជាក់ពីលិខិតជូនដំណឹងដំបូងតាមលេខតម្កល់ ។

ខ-បញ្ជាក់ពីម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដែលអនុញ្ញាតឱ្យបញ្ចប់នេះ ។

គ-បញ្ជាក់ថាលិខិតជូនដំណឹងគ្មានប្រសិទ្ធភាព ចំពោះផលប្រយោជន៍របស់ម្ចាស់បំណុលដែលមានកិច្ចធានាដែលអនុញ្ញាតឱ្យបញ្ចប់ ។

២-ក្នុងរយៈពេលម្ភៃ(២០)ថ្ងៃ បន្ទាប់ពីម្ចាស់បំណុលដែលមានកិច្ចធានា បានទទួលការទាមទារជាលាយលក្ខណ៍អក្សរពីកូនបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវតម្កល់លិខិតសុំបញ្ចប់ ប្រសិនបើ :

ក-គ្មានជំពាក់កាតព្វកិច្ចប្រាតិភោគនិងគ្មានការសន្យាផ្ដល់បុរេប្រទាន ការបង្កើត

កាតព្វកិច្ច ឬ ការផ្តល់តម្លៃតាមវិធីក្រៅពីនេះទេ ឬ

-កូនបំណុលមិនបានអនុញ្ញាតឱ្យតម្កល់លិខិតជូនដំណឹងដំបូង ឬ

-លិខិតជូនដំណឹងដែលចែងពីគណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាដែលត្រូវបានលក់ ប៉ុន្តែកូនបំណុលគណនី ឬ បុគ្គលដែលជំពាក់កាតព្វកិច្ច បានរំលត់កាតព្វកិច្ចរបស់ខ្លួនសព្វគ្រប់អស់ហើយ ។

៣-លិខិតសុំបញ្ចប់ អាចបញ្ចប់សិទ្ធិរបស់ម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹង តែក្នុងករណីដែលម្ចាស់បំណុលមានកិច្ចធានា បានអនុញ្ញាតតាមរយៈកំណត់ត្រាដែលមានបញ្ជាក់ការឯកភាព ។ នៅពេលតម្កល់លិខិតសុំបញ្ចប់ ដែលមានប្រសិទ្ធភាព លិខិតជូនដំណឹងដែលពាក់ព័ន្ធនឹងលិខិតសុំបញ្ចប់នេះ ក្លាយទៅជាគ្មានប្រសិទ្ធភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានាដែលបានអនុញ្ញាតឱ្យតម្កល់ ។

មាត្រា ៤០.-

១-ការប្រគល់លិខិតជូនដំណឹងដំបូង វិសោធនកម្ម លិខិតសុំបន្ត ឬ លិខិតសុំបញ្ចប់ និងការស្នើសុំបង់ថ្លៃតម្កល់ ឬ ការទទួលកំណត់ត្រាដោយការិយាល័យតម្កល់ ត្រូវចាត់ទុកជាការតម្កល់ លើកលែងតែប្រការដែលមានចែងក្នុងវាក្យខណ្ឌទី ២ ខាងក្រោមនេះ ។

២-មិនចាត់ទុកថាមានការតម្កល់លិខិតជូនដំណឹងទេ បើកំណត់ត្រានេះត្រូវបានការិយាល័យតម្កល់បដិសេធ ក្នុងករណីដែល :

ក-លិខិតជូនដំណឹងដំបូងមិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវ ។

ខ-វិសោធនកម្ម មិនបានផ្តល់ព័ត៌មានតាមច្បាប់តម្រូវ ឬវិសោធនកម្មបញ្ជាក់ពីលិខិតជូនដំណឹងដំបូងដែលផុតរយៈពេលមានប្រសិទ្ធភាព ។

គ-លិខិតសុំបន្តមិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ឬ មិនបានប្រគល់ជូនក្នុងរយៈពេលប្រាំមួយ(០៦)ខែ ដែលច្បាប់នេះបានអនុញ្ញាត ឬ

ឃ-លិខិតសុំបញ្ចប់មិនបានបញ្ជាក់ពីលេខនៃលិខិតជូនដំណឹងដំបូង ។

៣-ការិយាល័យតម្កល់ មិនអាចបដិសេធមិនតម្កល់លិខិតជូនដំណឹងក្រៅពីមូលហេតុដែលមានចែងក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះឡើយ លើកលែងតែមានការស្នើសុំបង់ថ្លៃតម្កល់ដែលមិនបានបង់តាមច្បាប់កំណត់ ទើបការិយាល័យតម្កល់អាចបដិសេធបាន ។

ក-កំណត់ត្រារួមជាមួយថ្លៃសេវាតម្កល់ ដែលដាក់ជូនការិយាល័យតម្កល់ ប៉ុន្តែបើការិយាល័យតម្កល់បានបដិសេធ ដោយផ្អែកលើមូលហេតុក្រៅពីមូលហេតុដែលចែងក្នុងមាត្រានេះ ត្រូវចាត់ទុកថាកំណត់ត្រាដែលបានតម្កល់នោះមានប្រសិទ្ធភាព ប៉ុន្តែគ្មានអានុភាពលើអ្នកទិញទ្រព្យធានា ដែលបានបង់ថ្លៃដោយមានការជឿជាក់សមហេតុផលថាគ្មានកំណត់ត្រាណាតម្កល់ពីមុនទេ ។

ខ-បើការិយាល័យតម្កល់បដិសេធការទទួលតម្កល់ ការិយាល័យនេះត្រូវតែបញ្ជូនអង្គហេតុ និងមូលហេតុនៃការបដិសេធរបស់ខ្លួនភ្លាមៗជូនទៅបុគ្គលដែលបានដាក់ជូនកំណត់ត្រានេះ ។

៤-លិខិតជូនដំណឹងដែលបានតម្កល់ មានប្រសិទ្ធភាពតែក្នុងករណីដែលបានតម្កល់ដោយបុគ្គលដែលច្បាប់នេះអនុញ្ញាតឱ្យតម្កល់ ។

៥-ការជូនដំណឹងដែលអនុញ្ញាតដោយម្ចាស់បំណុលដែលមានកិច្ចធានាម្នាក់ ដែលមានឈ្មោះក្នុងលិខិតជូនដំណឹង មិនប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បំណុលមានកិច្ចធានាផ្សេងទៀត ដែលបញ្ជាក់ក្នុងលិខិតជូនដំណឹងឡើយ ។

៦-ការចម្លងនិទ្ទេសមិនបានត្រឹមត្រូវដោយការិយាល័យតម្កល់ មិនប៉ះពាល់ប្រសិទ្ធ-ភាពនៃកំណត់ត្រាឡើយ ។

**មាត្រា ៤១.-**

១-បុគ្គលពាក់ព័ន្ធនៅក្នុងការតម្កល់លិខិតជូនដំណឹង អាចតម្កល់លិខិតសុំកែតម្រូវនៅការិយាល័យតម្កល់ ដើម្បីកែតម្រូវលិខិតជូនដំណឹងដែលមានចុះឈ្មោះរបស់ខ្លួន បើខ្លួនជឿថាកំណត់ត្រានោះមានកំហុស ឬ បានតម្កល់ដោយមិនត្រឹមត្រូវ ។

២-លិខិតសុំកែតម្រូវត្រូវតែ :

ក-បញ្ជាក់ពីកំណត់ត្រាដែលត្រូវកែតម្រូវ ដោយកំណត់ពីលេខតម្កល់នៃលិខិតជូនដំណឹងដំបូង ។

ខ-បញ្ជាក់ថាលិខិតនេះជាលិខិតសុំកែតម្រូវ ។

គ-បញ្ជាក់ពីមូលហេតុដែលបុគ្គលសាមីជឿថា កំណត់ត្រានេះមិនត្រឹមត្រូវនិង ចង្អុលបង្ហាញពីវិធីដែលត្រូវកែតម្រូវកំហុស ឬបញ្ជាក់ពីមូលហេតុ ដែលខ្លួនជឿថាកំណត់ត្រានោះ បានតម្កល់ដោយមិនត្រឹមត្រូវ ។

៣-ការតម្កល់លិខិតសុំកែតម្រូវ មិនប៉ះពាល់ដល់ប្រសិទ្ធភាពនៃលិខិតជូនដំណឹង ឡើយ ។

**មាត្រា ៤២.-**

១-រាល់លិខិតជូនដំណឹងដែលខ្លួនទទួលតម្កល់ ការិយាល័យតម្កល់ត្រូវតែ :

ក-ដាក់លេខកូដពិសេសលើកំណត់ត្រាដែលបានតម្កល់ ។

ខ-បង្កើតសំណុំកំណត់ត្រាដែលមានចុះលេខកូដពិសេស កាលបរិច្ឆេទ និង ពេលវេលានៃការតម្កល់ ។

គ-រក្សាទុកកំណត់ត្រាដែលបានតម្កល់សម្រាប់សាធារណជនពិនិត្យ ។

២-ការិយាល័យតម្កល់ត្រូវតែកត់ត្រាលិខិតជូនដំណឹងដំបូង ដោយចុះឈ្មោះកូនបំណុល និងត្រូវចុះកំណត់ត្រាទាំងអស់ ដែលពាក់ព័ន្ធនឹងលិខិតជូនដំណឹងដំបូង តាមរបៀបដែលយោងទៅរកលិខិតជូនដំណឹងដំបូង ។ ចំពោះលិខិតជូនដំណឹងដែលមានចែងពីលេខសេរីនៃយានយន្តមានលេខសេរី ការិយាល័យតម្កល់ត្រូវរក្សាទុកនិទ្ទេសលេខសេរីនោះ ។

៣-ការិយាល័យតម្កល់ត្រូវសម្រួលដល់ការស្វែងរកកំណត់ត្រាដោយប្រើឈ្មោះ និងលេខកូដរបស់កូនបំណុល ដែលបានចុះលើលិខិតជូនដំណឹងដំបូង ដែលពាក់ព័ន្ធនឹងកំណត់ត្រានេះនិងឯកសារតម្កល់ទាំងអស់ ដែលទាក់ទងគ្នានឹងលិខិតជូនដំណឹងដំបូង ។ ចំពោះលិខិតជូនដំណឹងដែលមានចែងពីលេខសេរីនៃយានយន្តដែលមានលេខសេរី ការិយាល័យតម្កល់ ត្រូវផ្តល់លទ្ធភាពដល់ការទាញកំណត់ត្រាមកប្រើតាមរយៈលេខសេរីនៃយានយន្តមានលេខសេរីនោះ ។

៤-ការិយាល័យតម្កល់ត្រូវរក្សាទុកកំណត់ត្រា ដែលអស់ប្រសិទ្ធភាពក្នុងរយៈពេល ដប់(១០)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទផុតរយៈពេល ។

៥-មន្ត្រីនៃការិយាល័យតម្កល់មានអំណាចតែលើកិច្ចការរដ្ឋបាលប៉ុណ្ណោះ ។ មាតិកានៃលិខិតជូនដំណឹងត្រូវដកស្រង់ចេញពីកិច្ចព្រមព្រៀងឯកជនដែលច្បាប់នេះអនុញ្ញាតនិង

ច្បាប់ដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ដែលមិនតម្រូវឱ្យមានការឯកភាព ឬការយល់ព្រមពីបុគ្គលណាក្រៅពីភាគីនៃកិច្ចព្រមព្រៀងឡើយ ។ ការិយាល័យតម្កល់មិនមានអំណាចក្នុងការពិនិត្យលិខិតជូនដំណឹង ដើម្បីកំណត់ពីភាពគ្រប់គ្រាន់សុពលភាព ឬបញ្ជាក់ថាមានតម្លៃតាមច្បាប់ឡើយ ។

មាត្រា ៤៣.–

១-ការិយាល័យតម្កល់ត្រូវតែផ្តល់ជូនបុគ្គលដែលស្នើសុំ នូវព័ត៌មានដូចខាងក្រោមនេះ :

ក-រាល់លិខិតជូនដំណឹងដែលចែងពីកូនបំណុល នឹងនៅមានប្រសិទ្ធភាពចំពោះម្ចាស់បំណុលដែលមានកិច្ចធានាទាំងអស់ ទោះបីជាការិយាល័យនេះមាន ឬ នឹងទទួលបានព័ត៌មាននោះនាកាលបរិច្ឆេទ និងពេលវេលាដែលការិយាល័យតម្កល់បានកំណត់ក៏ដោយ ។

ខ-លេខកូដឯកសារ កាលបរិច្ឆេទ និងពេលវេលានៃការតម្កល់លិខិតជូនដំណឹងនីមួយៗ ។

គ-ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់បំណុល ដែលមានកិច្ចធានាដែលចុះលើលិខិតជូនដំណឹងនីមួយៗ ។

ឃ-សេចក្តីអធិប្បាយពីទ្រព្យធានាក្នុងលិខិតជូនដំណឹងឬវិសោធនកម្មនីមួយៗ។

ង-លេខកូដឯកសារ កាលបរិច្ឆេទ និងពេលនៃការតម្កល់កំណត់ត្រានីមួយៗ ដែលពាក់ព័ន្ធនឹងលិខិតជូនដំណឹងនីមួយៗ និងកំណត់ត្រាដែលជាលិខិតសុំបន្ត លិខិតសុំកែតម្រូវ ឬ លិខិតសុំបញ្ចប់ ។

២-បុគ្គលអាចស្នើសុំរកកំណត់ត្រានៅការិយាល័យតម្កល់ តាមលក្ខណៈវិនិច្ឆ័យណាមួយដូចខាងក្រោមនេះ :

-លេខតម្កល់នៃលិខិតជូនដំណឹង ឬ

-លេខសេរីនៃយានយន្តមានលេខសេរី ឬ

-លេខអត្តសញ្ញាណប័ណ្ណរបស់កូនបំណុលជារូបវន្តបុគ្គល ដែលមានសញ្ជាតិ

ឈ្មោះរបស់កូនបំណុលដែលជានីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ ។

៣-ការិយាល័យតម្កល់ អាចផ្តល់កំណត់ត្រាតាមគ្រប់មធ្យោបាយ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។ ប៉ុន្តែបើមានការស្នើសុំការិយាល័យតម្កល់ ត្រូវផ្តល់កំណត់ត្រាដោយចេញលិខិតបញ្ជាក់ដែលអាចប្រើជាភស្តុតាង ក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនចាំបាច់មានភស្តុតាងក្រៅពីឯកសារផ្ទាល់មកបញ្ជាក់បន្ថែមឡើយ ។

**មាត្រា ៤៤.—**

១-ថ្វីបើមានបទប្បញ្ញត្តិក្នុងមាត្រា ៣០ ក៏ដោយ បើទ្រព្យធានាជាចលនវត្ថុតាំងភ្ជាប់រ៉ែដែលនឹងត្រូវជីកយក ឬឈើឈរដែលនឹងត្រូវកាប់ ត្រូវតម្កល់លិខិតជូនដំណឹង ដើម្បីធ្វើសុក្រឹតកម្មសិទ្ធិប្រាតិភោគនៅការិយាល័យចុះបញ្ជី ដែលបានបង្កើតឡើងតាមច្បាប់ភូមិបាលជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

២-លិខិតជូនដំណឹងដែលតម្កល់តាមវាក្យខណ្ឌនេះ ត្រូវអនុលោមតាមវិធានដែលកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ៤៥.—**

១-ថ្លៃសេវាសម្រាប់ការតម្កល់លិខិតជូនដំណឹងដំបូង លិខិតសុំបន្ត លិខិតសុំបញ្ចប់ ឬ លិខិតសុំកែតម្រូវ ថ្លៃសេវារៀបចំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ ឬសេវាផ្សេងៗទៀត ត្រូវបង់តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-ទោះបីមានបញ្ញត្តិក្នុងចំណុចទី ១ ក៏ដោយ ច្បាប់នេះមិនតម្រូវឱ្យមានថ្លៃសេវាកម្មសម្រាប់របាយការណ៍ស្រាវជ្រាវរក ដែលបុគ្គលគ្រប់រូបទទួលបានពីការប្រើប្រាស់សេវាកម្មអេឡិចត្រូនិករបស់ការិយាល័យតម្កល់ឡើយ ។

៣-ច្បាប់នេះមិនតម្រូវឱ្យមានថ្លៃសេវាកម្មណាផ្សេងពីថ្លៃសេវាកម្មដែលកំណត់ខាងលើនេះឡើយ ។



## ជំពូកទី ៤

## ការអនុវត្ត

**មាត្រា ៤៦.–**

១-ភាគីនៃកិច្ចព្រមព្រៀងប្រាតិភោគ មានសេរីភាពក្នុងការកំណត់ពីការមិនសងបំណុលក្នុងកិច្ចសន្យារបស់ខ្លួន ។

២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវមាន :

ក-សិទ្ធិកាន់កាប់ ឬ គ្រប់គ្រងទ្រព្យធានាតាមសិទ្ធិរបស់ខ្លួន ទោះបីជាកិច្ចព្រមព្រៀងប្រាតិភោគគ្មានចែងពីការកាន់កាប់ ឬការត្រួតត្រាក៏ដោយ ។

ខ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងច្បាប់នេះ ។

គ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ។

ឃ-សិទ្ធិ និងដំណោះស្រាយដែលមានចែងក្នុងច្បាប់ផ្សេងទៀត ។

៣-ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិណាមួយ ឬ ទាំងអស់ដែលខ្លួនមានក្នុងពេលជាមួយគ្នាបាន ។

៤-បើទ្រព្យធានាជាគណនីឬទ្រព្យអរូបីផ្សេងទៀត ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើគណនី ឬទ្រព្យអរូបីនោះដោយមិនចាំបាច់ប្ដឹងទៅតុលាការ ប៉ុន្តែត្រូវគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ដែលចែងពីអនុប្បទានសិទ្ធិឬសិទ្ធិប្រមូលបំណុល ។

៥-បើទ្រព្យធានាជាឯកសារ ម្ចាស់បំណុលដែលមានកិច្ចធានាអាចប្រើសិទ្ធិលើឯកសារ ឬ ចំពោះទំនិញដែលបានចែងក្នុងឯកសារក៏បាន ។

៦-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាមានសិទ្ធិសុំសេចក្ដីសម្រេចកិច្ចការប្រញាប់ពីតុលាការ ដែលអនុញ្ញាតឱ្យម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ ឬ គ្រប់គ្រងលើទ្រព្យធានា ។

៧-កាលណាម្ចាស់បំណុលមានកិច្ចធានា បានទទួលសេចក្ដីសម្រេចឱ្យកាន់កាប់អាទិភាពនៃការអនុវត្តសេចក្ដីសម្រេចនេះ ត្រូវគិតចាប់ពីកាលបរិច្ឆេទតម្កល់លិខិតជូនដំណឹង ឬ សុក្រឹតកម្មនៃសិទ្ធិប្រាតិភោគ គឺយកកាលបរិច្ឆេទណាមួយដែលកើតឡើងមុន ។

៨-ម្ចាស់បំណុលដែលមានកិច្ចធានា អាចទិញទ្រព្យធានាដែលប្រកាសលក់ដេញថ្លៃបាន ។

**មាត្រា ៤៧.-**

១-នៅពេលកូនបំណុលមិនសងបំណុលក្នុងគណនី ឬ សិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ម្ចាស់បំណុលដែលមានកិច្ចធានា អាចប្រើសិទ្ធិរបស់ខ្លួនបានដោយផ្ទាល់ចំពោះគណនី ។

២-នៅពេលកូនបំណុលមិនសងបំណុលក្នុងគណនី កិច្ចសន្យាលក់ដែលមានកិច្ច-ធានា ឬសិទ្ធិទទួលការបង់ប្រាក់ផ្សេងទៀត ឬ នៅពេលដែលកូនបំណុលបានឯកភាព ម្ចាស់បំណុលដែលមានកិច្ចធានា មានសិទ្ធិជូនដំណឹងអំពីសិទ្ធិរបស់ខ្លួន ទៅកូនបំណុលនៃគណនី ឬ ភាគីកូនបំណុល ដើម្បីឱ្យបង់ប្រាក់ជូនម្ចាស់បំណុលដែលមានកិច្ចធានា និងគ្រប់គ្រងលើផលនៃទ្រព្យធានា ។

៣-បើសិទ្ធិប្រាតិភោគធានានូវបំណុល ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវប្រគល់ទឹកប្រាក់ដែលប្រមូលបានដែលលើសពីបំណុលឱ្យទៅកូនបំណុល ។ កូនបំណុលត្រូវទទួលខុសត្រូវសងប្រាក់សមតុល្យរវាងប្រាក់បំណុលនិងប្រាក់ដែលប្រមូលបាន លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ។

៤-បើប្រតិបត្តិការជាការលក់គណនី ឬ កិច្ចសន្យាលក់ដែលមានកិច្ចធានាកូនបំណុលគ្មានសិទ្ធិលើទឹកប្រាក់ដែលលើសពីបំណុល និងគ្មានការទទួលខុសត្រូវចំពោះទឹកប្រាក់ដែលនៅខ្វះទេ លើកលែងតែកិច្ចព្រមព្រៀងប្រាតិភោគចែងផ្ទុយពីនេះ ។

៥-ម្ចាស់បំណុលដែលមានកិច្ចធានា អាចអនុវត្តតាមមាត្រានេះដោយមិនចាំបាច់ប្រើនីតិវិធីតុលាការក៏បាន ។

**មាត្រា ៤៨.-**

១-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាមានសិទ្ធិកាន់កាប់ ឬគ្រប់គ្រងទ្រព្យធានាដោយមិនចាំបាច់ប្តឹងទៅតុលាការ បើកូនបំណុលបានឯកភាពជាលាយលក្ខណ៍អក្សរបន្ទាប់ពីកូនបំណុលមិនបានសងបំណុល ។



២-នៅពេលកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាមានសិទ្ធិប្តឹងសុំសេចក្តីសម្រេចកិច្ចការប្រញាប់ ឬ ការបញ្ជាពិសេសពីតុលាការដែលអនុញ្ញាតឱ្យម្ចាស់បំណុលមានកិច្ចធានាកាន់កាប់ ឬ គ្រប់គ្រងទ្រព្យធានា ។

ក-សវនាការត្រូវផ្តោតតែលើបញ្ហាដែលពាក់ព័ន្ធ នឹងកិច្ចព្រមព្រៀងប្រាតិភោគដែលចែងពីទ្រព្យធានា ហើយត្រូវមានការខកខានមិនបានសងបំណុលយ៉ាងតិចមួយលើក ។

ខ-ក្នុងករណីដែលត្រូវការសេវាកម្មរបស់អាជ្ញាសាលា ឬ មន្ត្រីដទៃទៀតជាចាំបាច់ ដើម្បីដកហូតទ្រព្យធានាពីកូនបំណុល ម្ចាស់បំណុលត្រូវបង់ថ្លៃសេវាជាប្រាក់រៀលតាមការកំណត់រួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ ។

៣-បើមានចែងក្នុងកិច្ចព្រមព្រៀងប្រាតិភោគ ម្ចាស់បំណុលមានកិច្ចធានាអាចតម្រូវឱ្យកូនបំណុលផ្តុំតម្លើងទ្រព្យធានា និងរៀបចំឱ្យហើយស្រេចសម្រាប់ម្ចាស់បំណុលមានកិច្ចធានានៅកន្លែងដែលសមស្រប និងងាយស្រួលដល់ភាគីទាំងពីរដែលម្ចាស់បំណុលមានកិច្ចធានាជាអ្នកកំណត់ ។

៤-ម្ចាស់បំណុលមានកិច្ចធានា អាចទុកដាក់ឧបករណ៍មិនឱ្យអ្នកផ្សេងប្រើប្រាស់បានដោយគ្មានផ្លាស់ប្តូរទីតាំងរបស់វា ហើយអាចជម្រះចោលទ្រព្យធានានេះនៅមណ្ឌលអាជីវកម្ម ឬ លំនៅស្ថានរបស់កូនបំណុល ឬទីកន្លែងផ្សេងទៀតដែលរកឃើញទ្រព្យធានា ។

មាត្រា ៤៩.-

១-បន្ទាប់ពីកូនបំណុលមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានាអាចលក់ ជួល ផ្តល់តាមអាជ្ញាប័ណ្ណ ឬ ជម្រះចោលទ្រព្យធានាណាមួយ ឬ ទាំងអស់ក៏បាន ។

២-ការជម្រះចោលទ្រព្យធានា អាចធ្វើឡើងជាសាធារណៈ ឬ ជាឯកជន ហើយអាចធ្វើឡើងតាមកិច្ចសន្យាមួយ ឬ ច្រើនក៏បាន ។

៣-ការជម្រះចោលនេះអាចធ្វើឡើងតាមឯកតា ឬ ជាកញ្ចប់ និងនៅពេលវេលា ទីកន្លែង និងតាមលក្ខខណ្ឌដែលស្របតាមកាតព្វកិច្ចរបស់ម្ចាស់បំណុលមានកិច្ចធានាដែលកំណត់ក្នុងច្បាប់នេះ ។

៤- ម្ចាស់បំណុលមានកិច្ចធានា ត្រូវផ្តល់ជូនកូនបំណុលនូវដំណឹងសមស្របអំពីពេលវេលា និងទីកន្លែងនៃការលក់ឡាយឡុងជាសាធារណៈ ឬ ពេលវេលាដែលត្រូវលក់ជាឯកជន ឬការជម្រះចោលដែលបានគ្រោងទុក លើកលែងតែទ្រព្យធានាដែលងាយពុយរលួយ ឬ បង្ហាញពីការធ្លាក់ចុះតម្លៃយ៉ាងឆាប់រហ័ស ។ កូនបំណុលអាចលះបង់សិទ្ធិក្នុងការទទួលព័ត៌មាននេះបាន ។

៥- ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវជូនដំណឹងដល់ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលបានធ្វើកំណត់ត្រាជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់ពីសិទ្ធិរបស់គេលើទ្រព្យធានាមកឱ្យម្ចាស់បំណុលដែលមានកិច្ចធានា ។

៦- ម្ចាស់បំណុលដែលមានកិច្ចធានា អាចទិញទ្រព្យធានាដែលលក់ឡាយឡុងជាសាធារណៈ ឬ ជាឯកជនបាន ។

មាត្រា ៥០.-

១- ផលនៃការជម្រះទ្រព្យធានា ត្រូវយកមកប្រើប្រាស់តាមលំដាប់ដូចខាងក្រោមនេះ :

ក- សងថ្លៃចំណាយសមស្រប ដែលកើតឡើងពីការទទួលយកការកាន់កាប់ ការរៀបចំជម្រះទ្រព្យធានា និងការជម្រះទ្រព្យធានា រាប់បញ្ចូលទាំងថ្លៃចំណាយសមស្របសម្រាប់មេធាវី និងថ្លៃចំណាយរឿងក្តី ដែលម្ចាស់បំណុលមានកិច្ចធានាបានចំណាយ ។

ខ- ទូទាត់បំណុលដែលធានាដោយសិទ្ធិប្រាតិភោគ ។

គ- ទូទាត់បំណុលដែលធានាដោយសិទ្ធិប្រាតិភោគ ក្នុងលំដាប់បន្ទាប់លើទ្រព្យធានា បើមានការទាមទារជាលាយលក្ខណ៍អក្សរ មុនពេលបញ្ចប់ការបែងចែកផលនៃទ្រព្យធានា ហើយអ្នកកាន់កាប់សិទ្ធិប្រាតិភោគបន្ទាប់នេះ បានផ្តល់ភស្តុតាងសមស្របពីផលប្រយោជន៍របស់ខ្លួន ។

ឃ- ទូទាត់បំណុលគ្មានទ្រព្យធានាដែលបានទទួលស្គាល់ ។

២- ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវប្រគល់ទឹកប្រាក់ដែលលើសពីបំណុលទៅឱ្យកូនបំណុល ហើយកូនបំណុលត្រូវទទួលខុសត្រូវសងទឹកប្រាក់ដែលខ្វះ លើកលែងតែមានកិច្ចព្រមព្រៀងផ្សេងពីនេះ ។

៣-កាលណាទ្រព្យធានា ត្រូវបានជម្រះចោលដោយម្ចាស់បំណុលដែលមានកិច្ចធានា បន្ទាប់ពីកូនបំណុលមិនសងបំណុល :

ក-ការជម្រះចោលនេះជាការផ្ទេរសិទ្ធិទាំងអស់ លើទ្រព្យធានាឱ្យទៅអ្នកទិញ ដែលបានបង់ថ្លៃ ហើយរំលត់សិទ្ធិប្រាតិភោគ និងសិទ្ធិប្រាតិភោគបន្ទាប់ ឬ ឯកសិទ្ធិផ្សេងទៀត បើអ្នកទិញបានទិញដោយសុចរិត និង

ខ-មន្ត្រីចុះបញ្ជីនៃការិយាល័យចុះបញ្ជី ដែលរក្សាទុកកំណត់ត្រាកម្មសិទ្ធិលើទ្រព្យធានាដូចជាមន្ត្រីចុះបញ្ជីសិទ្ធិកម្ម សិទ្ធិយានយន្តដែលមានលេខសេរី ត្រូវចេញប័ណ្ណកម្មសិទ្ធិថ្មីជូនអ្នកទិញដែលបានបង់តម្លៃ ហើយបើមានការស្នើសុំពីមន្ត្រីចុះបញ្ជី ម្ចាស់បំណុលដែលមានកិច្ចធានា ត្រូវផ្ដល់ការអនុញ្ញាតឱ្យចេញប័ណ្ណកម្មសិទ្ធិថ្មី តាមរយៈសេចក្ដីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យម្ចាស់បំណុលកាន់កាប់ ឬកិច្ចព្រមព្រៀងលាយលក្ខណ៍អក្សររបស់កូនបំណុលដែលប្រគល់ ទ្រព្យធានាឱ្យម្ចាស់បំណុលកាន់កាប់ ដែលកូនបំណុលចុះហត្ថលេខា បន្ទាប់ពីការមិនសងបំណុល ។

**មាត្រា ៥១.-**

១-បន្ទាប់ពីការមិនសងបំណុល ម្ចាស់បំណុលមានកិច្ចធានា អាចស្នើសុំឃាត់ទុកទ្រព្យធានា ដើម្បីឱ្យមានការទូទាត់កាតព្វកិច្ចមួយផ្នែក ឬ ទាំងស្រុងបាន ។

២-ម្ចាស់បំណុលមានកិច្ចធានាត្រូវធ្វើការស្នើសុំនេះទៅកូនបំណុល និង ម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត ដែលបានធ្វើការទាមទារជាលាយលក្ខណ៍អក្សរមកម្ចាស់បំណុលដែលមានកិច្ចធានា ហើយបញ្ជាក់ថាខ្លួនមានផលប្រយោជន៍ក្នុងទ្រព្យធានានេះ ។

៣-បើម្ចាស់បំណុលដែលមានកិច្ចធានា បានទទួលការជំទាស់ជាលាយលក្ខណ៍អក្សរពីបុគ្គលដែលមានសិទ្ធិទទួលលិខិតជូនដំណឹងក្នុងរយៈពេលម្ភៃ(២០)ថ្ងៃបន្ទាប់ពីបានផ្ញើលិខិតជូនដំណឹង ម្ចាស់បំណុលដែលមានកិច្ចធានាត្រូវតែជម្រះចោលទ្រព្យធានាតាមបទ-ប្បញ្ញត្តិនៃជំពូកនេះ ។

៤-បើគ្មានការជំទាស់ក្នុងរយៈពេលម្ភៃ(២០)ថ្ងៃទេ ម្ចាស់បំណុលដែលមានកិច្ចធានាអាចរក្សាទុកទ្រព្យធានា ដើម្បីទូទាត់កាតព្វកិច្ចរបស់កូនបំណុលស្របតាមការស្នើសុំ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

មាត្រា ៥២.-

១-លើកលែងតែមានការព្រមព្រៀងលាយលក្ខណ៍អក្សរផ្ទុយពីនេះ បន្ទាប់ពីការមិនសងបំណុល កូនបំណុលឬម្ចាស់បំណុលដែលមានកិច្ចធានាផ្សេងទៀត អាចលោះយកទ្រព្យធានាដោយអនុវត្តកាតព្វកិច្ចទាំងអស់ ដែលធានាដោយទ្រព្យធានានេះ និងចេញថ្លៃចំណាយសមស្របដែលម្ចាស់បំណុលដែលមានកិច្ចធានាបានចាយក្នុងការកាន់កាប់ និង ថ្លុសថុលទ្រព្យធានាសម្រាប់ជម្រះចោល រួមបញ្ចូលទាំងថ្លៃសេវាមេធាវី និងចំណាយសមស្របក្នុងរឿងក្តី ។

២-ការលោះយកទ្រព្យធានា ត្រូវតែធ្វើឡើងមុនពេលម្ចាស់បំណុលដែលមានកិច្ចធានាជម្រះចោលទ្រព្យធានា ឬ មុនពេលម្ចាស់បំណុលដែលមានកិច្ចធានាចុះកិច្ចសន្យាដើម្បីជម្រះចោលទ្រព្យធានា ឬ មុនពេលដែលកាតព្វកិច្ចត្រូវបានរំលត់ ។

មាត្រា ៥៣.-

១-បើម្ចាស់បំណុលមានកិច្ចធានា មិនគោរពតាមលក្ខខណ្ឌតម្រូវនៃជំពូកនេះ តុលាការអាចបង្គាប់ ឬ ហាមឃាត់ការជម្រះចោលទ្រព្យធានាដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌសមស្រប ។

២-ម្ចាស់បំណុលមានកិច្ចធានាត្រូវតែអនុវត្តតាមគោលការណ៍ពាណិជ្ជកម្ម ដែលសមស្របជានិច្ចក្នុងការជម្រះចោលទ្រព្យធានា ។

៣-បើទ្រព្យធានាត្រូវបានជម្រះចោលរួចហើយ កូនបំណុល ឬ បុគ្គលដែលមានសិទ្ធិទទួលព័ត៌មាន ឬបុគ្គលដែលបានជូនដំណឹងពីសិទ្ធិប្រាតិភោគរបស់ខ្លួនទៅម្ចាស់បំណុលដែលមានកិច្ចធានាមុនការជម្រះចោលទ្រព្យនេះ មានសិទ្ធិទារសំណងពីម្ចាស់បំណុលដែលមានកិច្ចធានាចំពោះការខាតបង់ ដែលបណ្តាលមកពីការមិនគោរពច្បាប់នេះ ។

៤-មិនត្រូវចាត់ទុកថា ការលក់មិនស្របតាមគោលការណ៍ពាណិជ្ជកម្មឡើយ បើគ្រាន់តែដោយសារការលក់នេះអាចនឹងទទួលតម្លៃខ្ពស់ជាង បើលក់នៅពេលវេលាផ្សេង ឬតាមវិធីផ្សេងពីវិធីដែលកំណត់ដោយម្ចាស់បំណុលដែលមានកិច្ចធានា ។

ROYAUME DU CAMBODGE
ព្រះរាជវាំង
REGISTRE DU PALAIS ROYAL

៥- ការលក់នឹងត្រូវចាត់ទុកថាស្របតាមគោលការណ៍ពាណិជ្ជកម្ម បើម្ចាស់បំណុលដែលមានកិច្ចធានា បានជម្រះចោលទ្រព្យធានាស្របតាមទម្លាប់ពាណិជ្ជកម្មរវាងពាណិជ្ជករ ដែលធ្វើអាជីវកម្មទ្រព្យដែលមានប្រភេទដូចគ្នានឹងទ្រព្យធានា ។

៦- បើវិធីជម្រះចោលទ្រព្យធានាត្រូវបានឯកភាពដោយតុលាការ ការជម្រះចោលត្រូវចាត់ទុកថា ស្របតាមគោលការណ៍ពាណិជ្ជកម្មទាំងស្រុង ប៉ុន្តែច្បាប់នេះមិនតម្រូវឱ្យមានការឯកភាពនេះជាចាំបាច់ឡើយ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៥៤.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥៥.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម/០៥០៧/០២១ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
**ហត្ថលេខា**
**ចម ប្រសិទ្ធ**

លេខ: ២០៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០០៧
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល
ស៊ុន ជិនភេន

៤៧/៥៥

# ឧបសម្ព័ន្ធ ២

# តារាងពន្យល់ពាក្យគន្លឹះ

ដកស្រង់ពីមាត្រា ៣ នៃច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា

| ពាក្យ | និយមន័យ |
|---|---|
| កសិកម្ម | ទំនិញរបស់កូនបំណុលដែលបានមកពីមុខរបរកសិកម្ម លើកលែងតែឈើឈរ ហើយកសិផលរួមមាន<br>ក. ផលដំណាំដែលដាំដុះ កំពុងដុះលូតលាស់ ឬផលដំណាំដែលត្រូវដាំដុះ<br>ខ. ទំនិញជលផលដែលផលិតក្នុងប្រតិកម្មការវារីវប្បកម្ម<br>គ. សត្វពាហនៈ រាប់ទាំងកូនសត្វដែលសំរាលហើយ ឬមិនទាន់សំរាលផងដែរ<br>ឃ. ទំនិញផ្គត់ផ្គង់ដែលប្រើ ឬផលិតក្នុងប្រតិកម្មការកសិកម្ម<br>ង. ផលដំណាំដែលប្រមូលបាន ឬផលដែលបានមកពីសត្វពាហនៈ ហើយមិនទាន់កែច្នៃ |
| ការជួលទំនិញសំរាប់រយៈពេលលើសពីមួយ (០១) ឆ្នាំ | ក. ការជួលទំនិញដែលកំណត់រយៈពេលលើសពីមួយ (០១) ឆ្នាំ។<br>ខ. ការជួលទំនិញដែលគ្មានកំណត់រយៈពេល ទោះបីជារយៈពេលអាចត្រូវបានកំណត់ថាតិចជាងមួយឆ្នាំក៏ដោយ<br>គ. ការជួលទំនិញដែលកំណត់រយៈពេលដំបូងមួយឆ្នាំ ឬតិចជាមួយឆ្នាំបើអ្នកជួលបន្តកាន់កាប់ទំនិញ ដោយបានការឯកភាពពីអ្នកជួលឱ្យនិងគ្មានការអាក់ខាន ឬគ្មានការអាក់ខានជាសារវន្ត ក្នុង<br>រយៈពេលមួយ (០១) ឆ្នាំ បន្ទាប់ពីអ្នកជួលបានទទួលចលនវត្ថុនោះមក ប៉ុន្តែកិច្ចសន្យាជួលនេះ មិនក្លាយទៅជាមានរយៈពាលមួយ(០១) ឆ្នាំទេ លើកលែងតែអ្នកជួលបន្តការកាន់កាប់លើសពីមួយ (០១) ឆ្នាំ។<br>ឃ. ការជួលទំនិញដែលកំណត់រយៈពេលមួយ (០១)ឆ្នាំ ឬតិចជាងមួយ (០១) ឆ្នាំ កាលណាកិច្ចាសន្យាជួលចែងថាអាចបន្តរយៈពេលដែលលើសពីមួយ (០១)ឆ្នាំ។ |
| ការទិញ | កិរិយាបានវត្ថុក្នុងឋានៈជាអ្នកទិញរាប់បញ្ចូល ទាំងអ្នកទទួលអំណោយ អ្នកទទួលទ្រព្យធានាម្ចាស់បំណុលដែលមានកិច្ចធានា ឬម្ចាស់បំណុលហ៊ីប៉ូតែក ឬតាមប្រតិបត្តិការស្ម័គ្រចិត្តដែលបង្កើតសិទ្ធិលើទ្រព្យ។ បុគ្គលដែលទទួលចលនវត្ថុដោយការទិញ ឬហោះថា អ្នកទិញ។ |

| | |
|---|---|
| បញ្ជាក់ការឯកភាព | ការចុះហត្ថលេខា ឬការឯកភាពលើឈ្មោះ ឬនិមិត្តសញ្ញាផ្សេងៗដែលធ្វើឡើងដោយផ្ទាល់ដៃ ឬតាមវិធីផ្សេងៗ ហើយមានគោលបំណងបញ្ជាក់ពីអត្តសញ្ញាណ របស់ភាគីដែលឯកភាព ឬផ្តល់ការឯកភាព ឬបញ្ជាក់ឱ្យកំណត់ត្រាមានតម្លៃតាមច្បាប់។ |
| កិច្ចធានា | កាតព្វកិច្ចគាំទ្រ ជាអាទិ៍មានកាតព្វកិច្ចបង់ប្រាក់ ឬកាតព្វកិច្ចបង់ប្រាក់របស់អ្នកចេញ លិខិតឥណទាននិងដែលគាំទ្រការបង់ប្រាក់ ឬការបំពេញកាតព្វកិច្ចលើគណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬទ្រព្យអរូបីដទៃទៀត។ |
| កិច្ចសន្យាលក់ដែលមានកិច្ចធានា | កំណត់ត្រាដែលបង្កើតកាតព្វកិច្ចបង់ប្រាក់ និងសិទ្ធិប្រាតិភោគលើទំនិញ ឬការជួលទំនិញ។ |
| កិច្ចព្រមព្រៀងប្រាតិភោគ | កិច្ចព្រមព្រៀងដែលបង្កើត ឬចែងពីសិទ្ធិប្រាតិភោគ។ |
| កូនបំណុល | បុគ្គលដែលជំពាក់ប្រាក់ ឬកាតព្វកិច្ច ទោះពីបុគ្គលនេះជាកម្មសិទ្ធិករ ឬបុគ្គលដែលមានសិទ្ធិលើទ្រព្យធានាក៏ដោយ និងរាប់បញ្ចូលទាំងអ្នកលក់គណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកទទួល ទំនិញទុកលក់ អ្នកជួលចលនវត្ថុតាមកិច្ចសន្យាជួលដែលកំណត់ក្នុងច្បាប់នេះ។ |
| កូនបំណុលគណនី | បុគ្គលដែលជំពាក់កាតព្វកិច្ចក្នុងគណនី ក្នុងកិច្ចសន្យាលក់ដែលមានកិច្ចធានា ឬទ្រព្យអរូបីដទៃទៀត។ |
| កំណត់ត្រា | ព័ត៌មានដែលកត់ត្រាតាមមធ្យោបាយទំនាក់ទំនងអរូបី ឬព័ត៌មានដែលរក្សាទុកក្នុង ប្រព័ន្ធអេឡិចត្រូនិក ឬមធ្យោបាយទាក់ទងផ្សេងទៀត និងអាចយកមកប្រើបានក្នុងទម្រង់ដែលអាចយល់ ឬដឹងខ្លឹមសារបាន។ លិខិតជូនដំណឹងវិសោធនកម្ម លិខិតសុំបន្ត ឬលិខិតសុំបញ្ចប់ត្រូវចាត់ទុកជាកំណត់ត្រា បើបានប្រគល់ ជូនការិយាល័យតម្កល់តាមមធ្យោបាយ ដែលការិយាល័យតម្កល់បានកំណត់។ |
| គណនី | សិទ្ធិទទួលការទូទាត់ថ្លៃទំនិញដែលបានលក់ ឬបានជួល ឬថ្លៃសេវាកម្មដែលមិនមែនជាលិខិតស្នាម ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា។ |

| | |
|---|---|
| គាហកនៃសិទ្ធិឃាត់ទុក | ក. បុគ្គលដែលទទួលបាននូវសិទ្ធិលើទ្រព្យធានារបស់ម្ចាស់បំណុលដែលមានកិច្ចធានា ឬមានសិទ្ធិរឹបអូសទ្រព្យធានារបស់ម្ចាស់បំណុល ដែលមានកិច្ចធានាតាមវិធីប្តឹងទៅមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដូចជាមន្ត្រីតុលាការ អភិបាល ឬអភិបាលបណ្តោះអាសន្នក្នុងរឿងក្តីក្ស័យធនជាដើម។<br>ខ. បុគ្គលដែលមានឯកសិទ្ធិទូទៅ ឬឯកសិទ្ធិលើចលនវត្ថុពិសេសតាមច្បាប់ផ្សេងទៀត។ |
| ចលនវត្ថុតាំងភ្ជាប់ | ទំនិញដែលត្រូវបានភ្ជាប់ទៅនឹងអចលនវត្ថុ ឬមានគោលបំណងតាំងភ្ជាប់ទៅនឹងអចលនវត្ថុតាមរបៀប មួយដែលនាំឱ្យមានសិទ្ធិប្រត្យក្សកើតឡើងតាមច្បាប់ភូមិបាល។ |
| តម្លៃ | តម្លៃដែលបានផ្តល់សំរាប់សិទ្ធិ ក្នុងករណីដែលបុគ្គលបានទទួលសិទ្ធិ<br>ក. ជាថ្នូរនឹងមានសន្យាសុពលភាពក្នុងការផ្តល់ឥណទាន ទោះបីជាការសន្យាដែលអាចដកវិញបាន ឬមិនអាចដកវិញបានក៏ដោយ។<br>ខ. ជាទ្រព្យធានា ឬការទូទាត់ទាំងស្រុង ឬមួយភាគចំពោះការទាមទារពីមុន។<br>គ. ដោយការទទួលការប្រគល់ អនុលោមតាមកិច្ចសន្យាទិញដែលមានស្រាប់។<br>ឃ. ជាថ្នូរនឹងអ្វីដែលត្រូវបានផ្តល់ឱ្យក្នុងការដោះដូរ ឬជាថ្នូរនឹងការសន្យា។ |
| ទំនិញ | ចលនវត្ថុក្នុងពេល ដែលសិទ្ធិប្រាតិភោគភ្ជាប់ទៅនឹងវត្ថុនេះ។ ក្នុងនេះពាក្យថាទំនិញសំដៅដល់ ផលិតផលរ៉ែដែលត្រូវភ្ជាប់សិទ្ធិប្រាតិភោគនៅពេលជីកបាន ឈើឈរដែលត្រូវបានកាប់ កូនសត្វពាហនៈមិនទាន់សំរាល និងផលដំណាំដែលបានដាំដុះ កំពុងលូតលាស់ ឬដែលត្រូវដាំដុះ រាប់បញ្ចូលទាំងផលដំណាំនៅជាប់នឹងដើម ប្រេង ជ័រ ឬរុក្ខជាតិផងដែរ។ ពាក្យថាទំនិញនេះមិនរាប់បញ្ចូលនូវគណនី កិច្ចសន្យា លក់ដែលមានកិច្ចធានា រូបិយប័ណ្ណ ឯកសារ ឬលិខិតស្នាមឡើយ។ |
| ទំនិញប្រើប្រាស់ | ទំនិញដែលត្រូវបានប្រើប្រាស់ ឬទំនិញសម្រាប់ប្រើប្រាស់ជាចម្បងសម្រាបគោលបំណងផ្ទាល់ខ្លួន សមាជិកគ្រួសារ ឬសម្រាប់គោលបំណងគ្រួសារទំនិញទាំងនេះមិនអាចជាកម្មវត្ថុ នៃសិទ្ធិប្រាតិភោគបានទេ លើកលែងតែយានយន្តដែលមានលេខសេរី។ |

| | |
|---|---|
| ទំនិញបញ្ចូលគ្នា | ទំនិញដែលបានលាយបញ្ចូលជាមួយ ទំនិញតាមរបៀបមួយដែលអត្តសញ្ញាណនៃទំនិញនេះត្រូវបាត់បង់និងចូលក្នុងទំនិញថ្មី ឬក្នុងសមាសធាតុរួម។ |
| ទ្រព្យអរូបីយដទៃទៀត | រាល់ចលនវត្ថុ ឬសិទ្ធិដែលក្រៅពីទំនិញ គណនី កិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារលិខិតស្នាម និងរូបិយ។ |
| បញ្ញើទុកលក់ | ប្រតិបត្តិការដែលបុគ្គលម្នាក់ (អ្នកផ្ញើទំនិញទុកលក់) ប្រគល់ទំនិញឱ្យទៅពាណិជ្ជករ (អ្នកទទួលទំនិញទុលលក់) ដើម្បីលក់ដោយមិនគិតពីទម្រង់នៃកិច្ចសន្យា ឬពាក្យពេចន៍ដែលប្រើក្នុងកិច្ចសន្យាហើយះ<br>ក. ពាណិជ្ជករទិញនិងលក់ទំនិញប្រភេទនេះ ប្រើឈ្មោះផ្សេងពីឈ្មោះអ្នកផ្ញើទំនិញទុលលក់។<br>ខ. ពាណិជ្ជករមិនមែនជាអ្នកដេញថ្លៃ។<br>គ. ទំនិញមិនមែនជាទំនិញប្រើប្រាស់ មុនពេលប្រគល់ឱ្យទៅពាណិជ្ជករ។<br>ឃ. ប្រតិបត្តិការនេះមិនបង្កើតសិទ្ធិប្រាតិភោគ ដែលធានាកាតព្វកិច្ចនោះទេ។ |
| បុគ្គល | រូបវន្តបុគ្គល ឬនីតិបុគ្គលដែលច្បាប់កម្ពុជាទទួលស្គាល់។ |
| អ្នកទិញក្នុងអាជីវកម្មធម្មតា | បុគ្គលដែលទិញទំនិញពីបុគ្គលដែលប្រកបអាជីវកម្មលក់ទំនិញក្នុងប្រភេទទំនិញដែលបានទិញ បើអ្នកទិញបានទិញដោយសុចរិត ហើយមិនបានដឹងថាការលក់នេះបំពានលើសិទ្ធិរបស់បុគ្គលផ្សេងទេ។ |
| ផលនៃទ្រព្យធានា | អ្វីដែលទទួលបាននៅពេលលក់ ជួល ឬផ្តល់អាជ្ញាប័ណ្ណ ដោះដូរ ឬការជម្រះចោលទ្រព្យ ធានាតាមវិធីផ្សេងពីនេះ។ គឺអ្វីៗដែលប្រមូលបានពីទ្រព្យធានាអ្វីៗត្រូវបែងចែកពីទ្រព្យធានា ដូចជាសិទ្ធិដែលផុសចេញពីទ្រព្យធានាអ្វីៗត្រូវបែងចែកពីទ្រព្យធានា បណ្តឹងទាមទារដែលកើតចេញពីទ្រព្យខាតបង់ការមិនគោរពតាមវិការៈ ឬការខូតខាតទ្រព្យធានា ទៅតាមកំរិតតម្លៃនៃទ្រព្យធានា ថ្លៃធានារ៉ាប់រងដែលត្រូវសងដោយសារ ការខាតបង់ ឬការមិនគោរពតាមវិការៈ ឬការខូចខាតទ្រព្យធានាទៅតាមកំរិតតម្លៃទ្រព្យធានា និងតាមកំរិតដែលត្រូវចេញសងកូនបំណុល ឬម្ចាស់បំណុលដែលមានកិច្ចធានា។ ផលជារូបិយវត្ថុ មានន័យថា ផលជាសាច់ប្រាក់មូលប្បទានប័ត្រ មូលនិធិដែលផ្ញើក្នុងធនាគា និងផលនៃទ្រព្យធានា ដែលមានលក្ខណៈដូចគ្នា។ |

| | |
|---|---|
| ម្ចាស់បំណុលដែលមានកិច្ចធានា | អ្នកឱ្យខ្ចី អ្នកលក់ ឬបុគ្គលដែលទទួលសិទ្ធិប្រាតិភោគ តាមកិច្ចសន្យាប្រាតិភោគ រាប់បញ្ចូលទាំងបុគ្គលដែលបានទិញគណនី ឬកិច្ចសន្យាលក់ដែលមានកិច្ចធានា អ្នកផ្ញើទំនិញទុកលក់ និងអ្នកជួលឱ្យដែលជួលទំនិញតាមការកំណត់របស់ច្បាប់នេះ។ |
| ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង | បុគ្គលដែលដាក់ឈ្មោះជាម្ចាស់បំណុល ដែលមានកិច្ចធានា ឬតំណាងរបស់ម្ចាស់បំណុលដែលមានកិច្ចធានា ក្នុងលិខិតជូនដំណឹងដំបូងឬវិសោធនកម្មដែលបានតម្កល់។ បុគ្គលនេះមានឋានៈ ជាម្ចាស់បំណុលដែលមានកិច្ចធានាក្នុងលិខិតជូនដំណឹងក្នុងរយៈពេលតម្កល់ ឬរហូតដល់ពេលបានតម្កល់វិសោធនកម្ម ដែលលុបឈ្មោះម្ចាស់បំណុលនេះ ឬរហូតដល់ពេលលិខិតសុំបញ្ចប់សិទ្ធិប្រាតិភោគ របស់ម្ចាស់បំណុលក្នុងលិខិតជូនដំណឹង ឬរហូតដល់ពេលដែលលិខិតជូនដំណឹងទាក់ទិនទៅនឹងម្ចាស់បំណុលមានកិច្ចធានា ផុតកំណត់រយៈពេល។ |
| យានយន្តមានលេខសេរី | យានយន្ត រថសណ្ដោង អាកាសយាន កាណូត ឬទូកដែលមានលេខម៉ាស៊ីន បើយានយន្តទាងនេះមិនមែនជាសារពើភណ្ឌរបស់កូនបំណុល។ |
| លិខិតស្នាម | កំណត់ត្រាដែលបង្ហាញភស្តុតាងពីសិទ្ធិទទួលប្រាក់ ដែលមិនមែនជាកិច្ចព្រមព្រៀងប្រាតិភោគ ឬកិច្ចសន្យាជួល និងការផ្ទេរមួយប្រភេទដែលកើតឡើងតាមការប្រគល់ក្នុងអាជីវកម្ម ធម្មតាដោយមានបិដ្ឋិលេខចំណារខ្នងឬអនុប្បទានសិទ្ធិ។ ពាក្យនេះរាប់បញ្ចូលទាំងភស្តុតាងនៃសិទ្ធិប្រាតិភោគផងដែរ។ |
| លិខិតជូនដំណឹង | កំណត់ត្រាដែលបានតម្កល់ ឬដាក់ជូនដើម្បីតម្កល់នៅការិយាល័យតម្កល់។ ពាក្យនេះរាប់បញ្ចូលទាំងវិសោធនកម្ម លិខិតសុំបន្ត និងលិខិតសុំបញ្ចប់ដែលបានតម្កល់។ |
| វត្ថុចំណុះ | ចលនវត្ថុដែលបានផ្គុំបញ្ចូលជាមួយចលនវត្ថុផ្សេង តាមរបៀបដែលមិនធ្វើឱ្យបាត់បង់អត្តសញ្ញាណនៃចលនវត្ថុចម្បងនោះទេ។ |
| សារពើភ័ណ្ឌ | ទំនិញដែលបុគ្គលកាន់កាប់សម្រាប់លក់ ជួល ឬជាវត្ថុធាតុដើម គម្រោងដែលកំពុងដំណើរការសម្ភារៈដែលប្រើប្រាស់ក្នុងអាជីវកម្ម។ |
| សិទ្ធិប្រាតិភោគលើប្រាក់ខ្ចីទិញ | សិទ្ធិប្រាតិភោគដែល៖ |

| | |
|---|---|
| | ក. ត្រូវបានយក ឬក៏រក្សាទុកដោយអ្នកទិញទំនិញដើម្បីធានាតម្លៃនោះទាំងស្រុង ឬមួយផ្នែក<br>ខ. ត្រូវបានយកដោយបុគ្គល ក្រៅពីអ្នកលក់ដែលបានបង់តម្លៃ ដើម្បីឱ្យកូនបំណុលទទួលបានសិទ្ធិ ឬការប្រើប្រាស់ទំនិញតាមរយៈការបង្កើតកាតព្វកិច្ចបើតម្លៃនោះបានប្រើតាមគោលបំណងនេះប្រាកដមែន។ |
| អនុប្បទានសិទ្ធិ | ការផ្ទេរពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់នូវសិទ្ធិទាំងស្រុង ឬមួយផ្នែកលើគណនីកិច្ចសន្យាលក់ដែលមានកិច្ចធានា ឯកសារ លិខិតស្នាម ឬសិទ្ធិទទួលបានការបង់ប្រាក់ផ្សេងទៀត។ បុគ្គលដែលផ្ទេរសិទ្ធិនេះហៅថា អនុប្បទាយី និងបុគ្គលដែលទទួលសិទ្ធិផ្ទេរហៅថាអនុប្បទានិក។ |
| អ្នកជួលក្នុងអាជីវកម្មធម្មតា | បុគ្គលដែលបានជួលទំនិញតាមប្រភេទនៃទំនិញក្នុងអាជីវកម្មពីបុគ្គលដែលមានអាជីវកម្មលក់ ឬជួលទំនិញធម្មតាដោយសុចរិត និងមិនដឹងថាការជួលនេះបំពានលើសិទ្ធិកម្មសិទ្ធិ ឬសិទ្ធិប្រាតិភោគ ឬសិទ្ធិរបស់តតិយជនលើទំនិញនេះឡើយ។ "កិច្ចសន្យាលក់បណ្ដាក់" អាចធ្វើឡើងជាថ្នូរនឹងវូបិយវត្ថុ ឬទ្រព្យផ្សេងទៀត។ |
| ឧបករណ៍ | ទំនិញលើកលែងតែកសិផល សារពើភណ្ឌ ទំនិញប្រើប្រាស់ ឬយានយន្តដែលមានលេខសេរី។ |
| ឯកសារកម្មសិទ្ធិ | ប័ណ្ណកម្មសិទ្ធិ ឬបង្កាន់ដៃ ជាអាទិ៍មានប័ណ្ណដឹកជញ្ជូន សក្ខីប័ត្រកំពង់ផែ បង្កាន់ដៃឃ្លាំង ដែលចេញដោយបុគ្គលដែលធ្វើអាជីវកម្មដឹកជញ្ជូន ឬស្តុកទំនិញ។ |

# ឧបសម្ព័ន្ធ ៣
# លំហូរនីតិវិធី
# នៃការបង្កើតប្រតិបត្តិការដែលមានកិច្ចធានា


បង្កើតប្រតិបត្តិការ
1. កិច្ចព្រមព្រៀងប្រាតិភោគ
2. កូនបំណុលត្រូវទទួលបានតម្លៃតប
3. កូនបំណុលមានសិទ្ធិលើទ្រព្យធានា
សុក្រឹត្យកម្ម
1. សុក្រឹតកម្មតាមរយៈការតម្កល់លិខិតជូនដំណឹង
2. សុក្រឹតកម្មតាមរយៈការកាន់កាប់
3. សុក្រឹតកម្មដោយស្វ័យប្រវត្តិ
អាទិភាពនៃសុក្រឹតកម្មត្រូវយកមកពិចារណាក្នុងករណីមានការប្រជែងសិទ្ធិ
កូនបំណុលអនុវត្តកាតព្វកិច្ច
កាតព្វកិច្ចបានរលត់
កូនបំណុលមិនអនុវត្តកាតព្វកិច្ច
ម្ចាស់បំណុលឃាត់ទុកធានា
ម្ចាស់បំណុលកាន់កាប់ទ្រព្យធានា
ម្ចាស់បំណុលប្រមូលទ្រព្យធានា
ម្ចាស់បំណុលជម្រះទ្រព្យធានា

# ឧបសម្ព័ន្ធ ៤

# តារាងនៃប្រតិបត្តិការដែលត្រូវធ្វើសុក្រឹតកម្ម

| កម្មវត្ថុនៃកិច្ចសន្យា | វិធីក្នុងការធ្វើឱ្យកិច្ចសន្យាប្រាតិភោគនៃប្រតិបត្តិការដែលមានកិច្ចធានាមានសុក្រិតភាព | | |
|---|---|---|---|
| | ដោយការតម្កល់លិខិតជូនដំណឹង | ដោយការកាន់កាប់ | ដោយស្វ័យប្រវត្តិ |
| ទំនិញ | ✓ | ✓ | |
| លិខិតស្នាម | ✓ | ✓ | |
| ឯកសារកម្មសិទ្ធ | ✓ | ✓ | |
| ប័ណ្ណភាគហ៊ុន | ✓ | ✓ | |
| កិច្ចសន្យាលក់ដែលមានកិច្ចធានា | ✓ | ✓ | |
| ទំនិញប្រើប្រាស់ | | | ✓ |
| ផលនៃទ្រព្យ | | | ✓ |
| យានយន្តដែលមានលេខសេរី | ✓ | | |
| សិទ្ធិប្រាតិភោគលើរូបិយវត្ថុ | | ✓ | |

# ឧបសម្ព័ន្ធ ៥

# តារាងតម្លៃសេវា

# ពាក់ព័ន្ធនឹងការតម្កល់លិខិតជូនដំណឹង

ដកស្រង់ចេញពីគេហទំព័ររបស់ការិយាល័យតម្កល់ស្តីពីតម្លៃនៃការប្រតិបត្តិការ

| **ប្រតិបត្តិការ** | **តម្លៃ** |
|---|---|
| តំលៃសំរាប់ការតម្កល់លិខិតជូនដំណឹងនៃសិទ្ធិប្រាតិភោគ។ | ១០០០០ រៀល |
| តំលៃសំរាប់ការតម្កល់ការកែប្រែលិខិតជូនដំណឹង លិខិតសុំបន្ត រឺ លិខិតសុំបញ្ចប់ | ១០០០០ រៀល |
| តំលៃសំរាប់ការស្នើសុំរបាយការណ៍ដែលមានការបញ្ជាក់នៃព័ត៌មានដែលបានរកឃើញ | ១០០០០ រៀល |
| ការស្រាវជ្រាវរក ក្នុងការិយាល័យតម្កល់។ | មិនគិតកម្រៃ |
| ការតម្កល់លិខិតជូនដំណឹង នៃសិទ្ធិឃាត់ទុកតាមរយះមន្ត្រីរដ្ឋាភិបាល រឺ តុលាការ។ | មិនគិតកម្រៃ |

# ឧបសម្ព័ន្ធ ៦
# គំរូលិខិតជូនដំណឹង

# NOTICE OF SECURED TRANSACTIONS

Secured Interest Type: Security Interest
Party Size: The transaction secures the securing party's purchase of personal or household items
Expired Date: 21 Feb 2016 00:00:00

## Initial Registration

| NOTICE NUMBER | CREATED DATE |
| --- | --- |
| 1000181019 | 21 Feb 2011 15:00:37 |

## Securing Parties

| PARTY TYPE | IDENTIFIER | ADDRESS |
| --- | --- | --- |
| Registered Legal Entity (Company) | | No.33, St.294 Corner St.29, Sangkat Tonle Basac - Khan Chamkar Morn - Phnom Penh - Cambodia |

## Secured Parties

| NAME | ADDRESS |
| --- | --- |
| ANZ ROYAL BANK (CAMBODIA) LTD. | 20 KRAMUON SAR & CORNER OF STREET 67, PO BOX 624 - DAUN PENH - PHNOM PENH - CAMBODIA |

## Collateral categories

Vehicle

## Collateral Description

Commercial Enterprise Mortgage all over present and future assets of DFDL MEKONG (CAMBODIA) CO., LTD.

# ឧបសម្ព័ន្ធ ៧

# គម្រូលិខិតសុំបញ្ឈប់លិខិតជូនដំណឹង

## Termination

| TERMINATION NOTICE NUMBER | CREATED DATE |
|---|---|
| 10011501 | 27 Jan 2015 19:10:09 |

## Securing Parties

| PARTY TYPE | IDENTIFIER | ADDRESS |
|---|---|---|

## Secured Parties

## Collateral categories

Vehicle

## Collateral Description

## Authorizing Parties

| AUTHORIZER | PARTY TYPE | NAME | ADDRESS |
|---|---|---|---|
| ✓ | | ANZ ROYAL BANK (CAMBODIA) LTD. | 20 KRAMUON SAR & CORNER OF STREET 67, PO BOX 624 - DAUN PENH - PHNOM PENH - CAMBODIA |

# ឧបសម្ព័ន្ធ ៨
# អាស័យដ្ឋានទំនាក់ទំនង
# ការិយាល័យតម្កល់លិខិតជូនដំណឹង

- **ទូរស័ព្ទ:** អ្នកអាចទូរស័ព្ទមកកាន់ការិយាល័យតម្កល់ ប្រតិបត្តិការមានកិច្ចធានាតាមរយៈ លេខ (855) 23 866 043។
- **អ៊ីមែល:** អ្នកអាចផ្ញើអ៊ីមែលមកកាន់ការិយាល័យតម្កល់តាមរយៈ setfomoc.info@gmail.com
- **ទីតាំង:** ការិយាល័យរដ្ឋបាលនៃការិយាល័យតម្កល់ ប្រតិបត្តិការមានកិច្ចធានាមានទីតាំងស្ថិតនៅជាន់ទីបីនៃអាគារB ក្នុង ក្រសួងពាណិជ្ជកម្ម ឡូត៍លេខ 19-61 វិថីក្រសួងពាណិជ្ជកម្ម (113B) ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។.
- លោកស្រី គឹម សារឿង ប្រធាននាយកដ្ឋាននីតិកម្ម ទូរស័ព្ទលេខ (855) 12 831 769។
- ការិយាល័យតម្កល់ គឺ លោក សៀង កុមិរ៉ា ទូរស័ព្ទលេខ # (855) 12 723 645។